
PRIMERICA
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554
- Life Insurance — ធានារ៉ាប់រងជីវិត
- Car Insurance — ធានារ៉ាប់រងរថយន្ត
- Refinance Your Debts — រៀបចំសងប្រាក់ជំពាក់ឡើងវិញ
- Investments — វិនិយោគទុន
- Office or Home Appointment. — ជួបនៅការិយាល័យយើង ឬនៅផ្ទះលោកអ្នកក៏បាន

We also provide translation and interpretation services.
យើងផ្ដល់ការបកប្រែភាសា តាមក្រដាស ឬផ្ទាល់មាត់
E-mail: 8665823172@primerica.gosolo.com
Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034

# ខ្មែរប៉ុស្ដិ៍ The Khmer Post

ហាងមាសរស្មី
SUNSHINE JEWELRY INC

- Fine Jewelry
- Certified Diamonds & Custom Design

មានលក់គ្រឿង អលង្ការ យ៉ាងប្រណិតបំផុត ចេញសញ្ញាបត្រឈើពេជ្រអាច ផ្លាក់ ឬ ថ្លៃ មាស ប្រាក់ ពេជ្រ ជូនតាមបំណង ។
យើងមានបទពិសោធន៍ ១៥ឆ្នាំ ហើយមាន កេរ្តិ៍ឈ្មោះល្អក្នុងការបំរើសេវាអលង្ការនេះ
702 Washington Avenue Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com

KHMER BILINGUAL BIWEEKLY NEWSPAPER
VOLUME 02 ISSUE 25 November 15th-30th 2008 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM

## សន្ធិសីទទីក្រុងប៉ារីស 23តុលា បញ្ចប់សង្គ្រាមបង្ហូរឈាមខ្មែរ និងខ្មែរ

**ភ្នំពេញ, ខ្មែរប៉ុស្ដិ៍ : ចាន់ កុសល**

•••បន្ទាប់ពីរបប ប៉ុល ពត បានដួលរលំផុតទៅ ខ្មែរក្នុងស្រុក និងក្រៅស្រុកមានការខ្វែងគំនិតគ្នាចំពោះការឈ្លានពានរបស់ទ័ពយួន ហើយបានបង្កបង្កើនជាកងទ័ពប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញអស់រយៈពេលជាច្រើនឆ្នាំ ។ (តទៅទំព័រទី០៧)


អតីតព្រះមហាក្សត្រនរោត្តមសីហនុ ជួបជាមួយ ហ៊ុន សែន នៅទីក្រុងប៉ារីស

## មរណភាព ហុក ឡុងឌី ក្លាយរឿងអាថ៌កំបាំងពីអតីតកាល

**ស្វាយរៀង, ខ្មែរប៉ុស្ដិ៍ : ស៊ឹម សុភាបុទ្ធិ**

•••ក្នុងឧបទ្ទវហេតុធ្លាក់ឧទ្ធម្ភាគចក្រ កាលពីយប់ថ្ងៃទី៩ ខែវិច្ឆិកា បានបណ្ដាលឱ្យនាយប៉ូលិសជាន់ខ្ពស់២រូប និងអ្នកបើកបរពីរនាក់ទៀត ស្លាប់យ៉ាងអណោចអធម ។ ក្នុងហេតុការណ៍នេះ ធ្វើឱ្យមជ្ឈដ្ឋាននានាធ្វើការ (តទៅទំព័រទី០៣)



## ការស្រមៃក្លាយជាការពិតនៅ សហរដ្ឋអាមេរិក



**ដោយ : ពិន សំខុន**

•••មនុស្សប្រមាណ ២០ម៉ឺននាក់ នៅ ឈីកាហ្គោ បានរង់ចាំលោក បារ៉ាក់ អូបាម៉ា ចេញមកទទួលលទ្ធផលនៃការបោះឆ្នោតប្រធានាធិបតីនៃសសហរដ្ឋអាមេរិក ដែលទើបនឹងបញ្ចប់ទៅនៅម៉ោង៩យប់ នារាត្រីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

នៅម៉ោង១០គត់ បន្ទាប់ពីលោក ចន ម៉ាកេន សម្ដែងការជូនពរដល់អ្នកឈ្នះឆ្នោត ហើយទទួលយកលទ្ធផលរបស់លោករួចមក ទូរទស្សន៍គ្រប់ឆាណល បានបង្ហាញរូបភាពបេក្ខជនជាប់ឆ្នោតក្នុងឋានៈថ្មី ដែលសហរដ្ឋអាមេរិក ពុំដែលជួបប្រទះ គឺប្រធានាធិបតីសម្បុរស្បែកខ្មៅ ជាមួយវីរៈនារីទី១ ស្បែកខ្មៅដូចគ្នា គឺ បារ៉ាក់ និង មីសែល អូបាម៉ា ដែលនឹងចូលទៅកាន់កាប់សេដ្ឋវិមាន នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ខាងមុខនេះ ។

សហរដ្ឋអាមេរិកពេលនោះ ទើបនឹងបង្កើតព្រឹត្តការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀត ដែលគេស្មានមិនដល់ ថាប្រជាពលរដ្ឋអាមេរិកាំងអាចនឹងទទួលយកពលរដ្ឋខ្មែរស្បែកខ្មៅ ដែលជិតប្រវត្តិនឹងទាសករឱ្យឡើងជាប្រធានាធិបតីរបស់ខ្លួន បាននាពេលនេះទេ ។ ក៏ប៉ុន្តែសម្លេងឆ្នោតនៃពលរដ្ឋបានសម្រេចផ្សេងពីនោះ ។

ម៉ាតាំង លូវទ័រឃីង នៅមុនពេលត្រូវគេលបបាញ់សម្លាប់ នាឆ្នាំ ១៩៦៨ បានទាមទារសិទ្ធិឱ្យពលរដ្ឋស្បែកខ្មៅមានសិទ្ធិស្មើគ្នានឹងពលរដ្ឋស្បែកសឯទៀតនៅគ្រប់វិស័យ ។ សន្ទរកថារបស់លោកនិយាយអំពី " ខ្ញុំស្រមៃឃើញ... " បានដាស់នូវស្មារតីមិនត្រឹមតែពួកស្បែកខ្មៅទេ គឺអាមេរិកាំងស្បែកសកាន់តែច្រើនឡើងប្រទេសសេរីទាំងសកលលោកឱ្យការពារសេរីភាពរបស់មនុស្សឱ្យខ្ពស់ ដោយគ្មានការប្រកាន់ពណ៌សម្បុរ ។ នៅមុខទីស្នាក់ការឈីកាហ្គោ របស់លោក អូបាម៉ា ទូរទស្សន៍បានបង្ហាញទឹកមុខប្រកបដោយក្ដីរំភើបរបស់ហ្វូង (តទៅទំព័រទី១៤)

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ_អង្គរ
Angkor International Travel Agency
World Wide Travel & Tour Services
Cambodia – Vietnam – Laos – Thailand
(Since 1991)
ទទួលផ្ញើប្រាក់ទៅស្រុកខ្មែរ
សេវាលិខិតឆ្លងដែន
សេវាអន្តោប្រវេសន៍
កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO

Cambodia: Victory Travel
No. 96 Eo Street. 148, Phsar Kandal
Phnom Penh, Cambodia
Tel: 011-892329
Manager SIN PO
CHENDA: 023-221069

Serving all Major air lines :
. SINGAPOR
. EVA AIR
. KOREAN AIRLINES
. MALAYSIA etc...

## ជម្លោះវត្ត IRAP ឈានដល់ការចាប់មនុស្សដាក់គុកជាបណ្ដើរៗ

**ឡុងប៊ិច, ខ្មែរប៉ុស្ដិ៍ : មាជ សុវណ្ណារ៉ា**



•••ទិត្យ ស៊ីផាន់ ដែលអះអាងថា ខ្លួនជានាយកប្រតិបត្តិនៃពុទ្ធិកសមាគមខ្មែរវត្តវិបស្សនារាម ត្រូវបានតុលាការចេញ (តទៅទំព័រទី១៧)

សូមអញ្ជើញស្ដាប់វិទ្យុសម្លេងខ្មែរអាមេរិកាំង នៅ ហ្វីឡាដែលហ្វីយ៉ា AM1540 នៅរៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង ៣ ដល់ ៤ រសៀល

# ឱកាសសំរាប់ជាម្ចាស់ការលើមុខរបរ សំអាតការិយាល័យ

STRATUS BUILDING SOLUTIONS
Rapid Growing Commercial Clearing Industry





មុខរបរដែលនរណាក៏អាចធ្វើបានឱ្យតែមានការព្យាយាម ហើយចង់បានប្រាក់ច្រើន ។ "ស្ត្រាតឹស" គឺជាឱ្យស្សាហកម្មមួយដែលកំពុងរីកចំរើន នៅ ស.រ.អា មានបទពិសោធន៍ ២០ ឆ្នាំហើយ ក្នុងការធ្វើឱ្យលោកអ្នកក្លាយជាម្ចាស់ការក្នុងមុខរបរសំអាតការិយាល័យ ។ យើងធានាថា លោកអ្នកនឹងមានគណនីយមួយដែលមានប្រាក់ចំណូលពីមុខរបរដែលលោកអ្នកបានជ្រើសយក ពីព្រោះយើងនឹងផ្តល់ជូននូវ :

- ការហាត់ហ្វឹកហ្វឺនពីមុខរបរនោះ
- យើងជួយឱ្យមុខរបរនោះឱ្យដំណើរការ
- យើងជួយរកទីផ្សារនឹងគ្រប់គ្រងមុខរបរជូន

លោកអ្នកអាចផ្តើមមុខរបរ ដោយមានភ្ញៀវរួចជាស្រេចជាមួយនឹងការងារដែល-លោកអ្នក ធ្វើបានយ៉ាងងាយស្រួល ដោយ :

- យើងផ្តល់ឱកាសំរាប់ផ្តើមការងារ-លោកអ្នកត្រូវដាក់ទុនតិចតួចសំរាប់កក់
- ធ្វើការតាមពេលដែលលោកអ្នកមាន
- មានទាំងផ្តល់ការធានារ៉ាប់រងឱ្យភ្ញៀវតម្លៃ ២ លានដុល្លារជូន
- យើងមានកុងត្រាជាមួយភ្ញៀវរួចហើយ ចំនួន ៣ លានដុល្លារទៀតផង ។

**បើចង់ជ្រាបច្បាស់លើសពីនេះ សូមទាក់ទងទូរស័ព្ទ**
**ទៅ ចន ខនម៉ាន់ (២១៥)២៧២ ៥៥៣៦**
**ឬហៅរក សុបិន (២៦៧) ២៥៣_៣៩៤៧**

120 BIBRALTAR RD. STE. 109. HORSHAM, PA 19044
OFFICE: 215-957-5830 FAX: 215-957-5835

# ការិយាល័យច្បាប់របស់ ជេហ្វ្រី អិន ខែល



Law Offices of
**Jeffrey N. Kale**
Attorney at Law



ពិគ្រោះករណីច្បាប់ដោយមិនគិតកំរៃ យើងបានបំរើសេវាច្បាប់ជូនដល់សហគមន៍ខ្មែរជាង ២០ ឆ្នាំហើយ .
ការិយាល័យ "ច្បាប់ទូទៅ" ដែលមានជំនាញផ្លូវច្បាប់ដូចតទៅ :

- គ្រោះថ្នាក់រថយន្ត
- បើកបរក្រោមឥទ្ធិពលស្រវឹង ឬពុល
- មានរបួសនៅកន្លែងធ្វើការ
- ទិញលក់អចលនវត្ថុ
- ច្បាប់បើកក្រុមហ៊ុន
- ច្បាប់ឧក្រិដ្ឋកម្ម
- គ្រោះថ្នាក់ដោយរអិល ឬដួល
- រំលោភច្បាប់លើផ្លូវចរាចរ
- ការទារឱ្យសងប្រាក់ជំពាក់ ។ល។

**New Jersey : 856-216-7171**
**1236 Brace Road, Suite K, Cherry Hill, NJ 08034**
**Pennsylvania/Philadelphia: 215-564-6900**
**1700 Sansom St., 3rd Floor, Street, Philadelphia, PA 19103**

**FREE CONSULTATIONS**

Providing legal services to the Cambodian community for 20 years
General Law Office specializing in the following areas of law:

- Car Accidents
- DUI/DWI
- Workplace Injury
- Real Estate
- Corporate Law
- Criminal Law
- Slip & Fall Accidents
- Traffic Violations
- Collections

**សេវាច្បាប់ប្រកបដោយវិជ្ជាជីវៈ នឹងតម្លៃគួរសម**
**អាចមានអ្នកបកប្រែជូនបាន**



# ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300





សូមអញ្ជើញមកមជ្ឈមណ្ឌលធ្វើធ្មេញ "អាដាប" យើងធ្វើចុនពីដើមដល់ចប់បានយើងមានក្រុមទន្តបណ្ឌិត៤រូប ដែលមានជំនាញគ្រប់ជ្រុងជ្រោយនៃវិជ្ជាធ្វើធ្មេញ ។

**មណ្ឌលធ្មេញឯកទេសខាងការទារលំអរ**

**ឯកទេសខាង**

- ✓ Crowns,
- ✓ Braces,
- ✓ Bridges,
- ✓ Veneers,
- ✓ Inlay,
- ✓ Gold Caps,
- ✓ Implants,
- ✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅហ្វីឡាដែលហៀតែមួយ ដែលមានបន្ទប់ពិសោធន៍នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចប្តូរធ្មេញថ្មីស ដែលផលិតឡើងតាមគុណភាព ដែលលោកអ្នកចង់បានទាំងអស់សុទ្ធតែដំណើរការណ៍ដោយបច្ចេកទេសវិជ្ជាជាន់ខ្ពស់ ហើយប្រើលំនាំប្រព័ន្ធ OSHA ជាក្បួន ។

**ទន្តសាស្ត្រទូទៅ**

- -ដកធ្មេញ
- -បំពេញធ្មេញប្រហោង
- -ព្យាបាលប្រហោងដល់ឫសធ្មេញ
- -ផ្ទិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
- **-សំអាតធ្មេញឱ្យសស្អាត:** ដោយធ្វើដោយឡេស័រមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
- -យើងក៏មានធ្វើការសំអាតដោយ "អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

**បើកមជ្ឈមណ្ឌល**

| | |
|---|---|
| ថ្ងៃ ច័ន្ទ | : 10am-6pm |
| ថ្ងៃ អង្គារ | : 10am-6pm |
| ថ្ងៃ ពុធ | : 10am-7pm. |
| ថ្ងៃ ព្រហស្បតិ៍ | : 10am-6pm |
| ថ្ងៃ សុក្រ | : 10am-6pm. |
| ថ្ងៃ សៅរ៍ | : 10am-7pm |

**យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់**

Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

**ចុះថ្លៃ 10%**
ដល់អ្នកគ្មានប័ណ្ណសុខភាព

**អាចធ្វើផែនការណ៍បេញថ្លៃរាល់ខែ**

(តមកពីទំព័រទី០១)

## មរណភាព ហុក ឡុងឌី ស្ថិត...


លោកនាយឧត្តមសេនីយ៍ ហុក ឡុងឌី


លោកឧត្តមសេនីយ៍ឯក សុខ សាឯម


លោកវរសេនីយ៍ឯក ហ៊ិន រដ្ឋា


លោកវរសេនីយ៍ទោ ទេព សេដ្ឋា

សន្និដ្ឋានខុសៗគ្នា ដោយអ្នកខ្លះថា បណ្តាលមកពីអាកាសធាតុ និងឧទ្ធម្ភាគចក្រមានដំណើរការមិនល្អ ។ ពេលនេះខាងជំនាញ និងអាជ្ញាធរបានដុតដៃដុតជើងតាមដានរឿងនេះ ដើម្បីស្វែងរកការពិត ។

បើតាមសេចក្តីរាយការណ៍នៅកន្លែងកើតហេតុវេលាម៉ោង៨ យប់ ថ្ងៃទី៩ វិច្ឆិកា គេឃើញឧទ្ធម្ភាគចក្រធុនតូចមួយគ្រឿងបានធ្លាក់នៅចំណុចភូមិព្រៃគាវ ឃុំកំពង់ចក ស្រុករំដួល ខណៈពេលដែលមេឃកំពុងតែភ្លៀងយ៉ាងខ្លាំង ។

ប្រជាពលរដ្ឋដែលបានឃើញហេតុកាណ៍នោះបានឱ្យដឹងថា នៅមុនពេលកើតហេតុគេឃើញមានឧទ្ធម្ភាគចក្រមួយគ្រឿងបើកមកពីទិសខាងលិចឆ្ពោះទៅទិសខាងកើតដែលមានភ្លើងឆេះនៅផ្នែកកន្ទុយ ហើយឧទ្ធម្ភាគចក្រនោះបានព្យាយាមរកកន្លែងចុះចត ប៉ុន្តែពេលសំយ៉ុងដល់ដីស្រាប់តែឧទ្ធម្ភាគចក្រនោះ ផ្ទុះបោកខ្ទប់នឹងដីបណ្តាលឱ្យអ្នកជិះក្នុងនោះ រងរបួសរហូតដល់ស្លាប់បាត់បង់ជីវិត ។

ប្រភពព័ត៌មានពីសមត្ថកិច្ចដែលទៅដល់កន្លែងកើតហេតុបានឱ្យដឹងថា ពេលនោះរថយន្តសាមុយ៤គ្រឿង បានព្យាយាមទៅសង្គ្រោះ ប៉ុន្តែពេលទៅដល់ទាំងអ្នកជិះ និងអ្នកបើកបរបានស្លាប់បាត់បង់ជីវិតទៅហើយ ។

ប្រភពខាងលើបានបញ្ជាក់ថា ជនរងគ្រោះដែលជិះក្នុងឧទ្ធម្ភាគចក្ររួមមាន : លោកនាយឧត្តមសេនីយ៍ ហុក ឡុងឌី អគ្គស្នងការប៉ូលិសជាតិបានខ្ទាត់ចេញពីបំណែកយន្តហោះចំងាយ ២ម៉ែត្រ លោកឧត្តមសេនីយ៍ឯក សុខ សាឯម មេបញ្ជាការកងទ័ពជើងគោកខ្ទាត់ចេញពីកន្លែងគ្រោះថ្នាក់ចំងាយ៥ម៉ែត្រ លោកវរសេនីយ៍ឯក ហ៊ិន រដ្ឋា និងលោកវរសេនីយ៍ទោ ទេព សេដ្ឋា ជាអ្នកបើកបរក៏បានស្លាប់បាត់បង់ជីវិតដែរ ។

បន្ទាប់ពីមានគ្រោះមហន្តរាយធ្លាក់ឧទ្ធម្ភាគ-ចក្រភ្លាមអាជ្ញាធរ និងសមត្ថកិច្ចបានដឹកសពជនរងគ្រោះមកកាន់ទីក្រុងភ្នំពេញទាំងកណ្តាលយប់ ដើម្បីធ្វើបុណ្យនៅតាមគេហដ្ឋានរៀងៗខ្លួន ។

លោក ជៀង អំ អភិបាលខេត្តស្វាយរៀង បានប្រាប់ក្រុមអ្នកកាសែតនៅកន្លែងកើតហេតុថា មុនពេលកើតហេតុ លោក ហុក ឡុងឌី និងសហការីបានចូលរួមប្រារព្ធពិធីបុណ្យឯករាជ្យជាតិលើកទី៥៥ នៅទីក្រុងភ្នំពេញ រួចក៏បន្តដំណើរមកកាន់ខេត្តស្វាយរៀងវេលាម៉ោង៧យប់ ហើយលោកមិនដឹងថា លោក ហុក ឡុងឌី មានបេសក-កម្មអ្វីទេ ។

លោក ជៀង អំ បានបញ្ជាក់ថា លោកមានអា-រម្មណ៍តក់ស្លុតយ៉ាងខ្លាំង នៅពេលទទួលបានដំណឹងអកុសលបែបនេះ ជានិច្ចកាលលោក ហុក ឡុងឌី តែងធ្វើដំណើរមកខេត្តស្វាយរៀង ពីព្រោះលោកមានលំនៅដ្ឋាននៅទីនេះ ។

បើតាមព័ត៌មានប្រភពច្បាស់ការណ៍ពីអ្នកបើករថយន្តរបស់សពលោក ហុក ឡុងឌី បានឱ្យដឹងថា មុនពេលកើតហេតុ លោក ហុក ឡុងឌី បានទទួលទានអាហាររួមគ្នាជាមួយលោកឧកញ៉ា គិត ម៉េង បន្ទាប់ពីស្រស់ស្រូបរួចហើយ លោក ហុក ឡុងឌី បានធ្វើដំណើរតាមឧទ្ធម្ភាគចក្រទៅខេត្តស្វាយរៀង ប៉ុន្តែលោកមិនដឹងថា មានបេសកកម្មអ្វីនោះទេ ។

ទាក់ទិនទៅនឹងការធ្លាក់ឧទ្ធម្ភាគចក្ររបស់នាយប៉ូលិសជាន់ខ្ពស់រូបនេះ ត្រូវបានលោក សុខ ផល នាយប៉ូលិសជាន់ខ្ពស់បានសំដែងនូវការសោកស្តាយ និងមានការសោកសៅចំពោះការបាត់បង់មេកើយរបស់ខ្លួនក្នុងឧបទ្ទវហេតុនេះ ហើយលោកមានការសង្ស័យទៅលើគ្រឿងចក្រ ។



ចំណែកលោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានញ្ជាក់យ៉ាងខ្លីថា បើយោងទៅលើការស្រាវជ្រាវជាជំហានដំបូង លោកអាចសន្និដ្ឋានបានថា គ្រោះថ្នាក់នេះ បណ្តាលមកពីអាកាសធាតុអាក្រក់ ទើបធ្វើឱ្យគ្រឿងចក្រមានបញ្ហា ហើយអ្នកបើកបរបានព្យាយាមគេចពី-គ្រោះថ្នាក់ដែរ ប៉ុន្តែនៅតែមិនអាចរួចខ្លួនទៀត ។

លោក ខៀវ សុភ័គ បានបន្តថា ពេលនេះសមត្ថកិច្ច និងមន្ត្រីជំនាញកំពុងតែធ្វើការស៊ើបអង្កេតបន្តទៀត ទៅលើក្រុមហ៊ុនឧទ្ធម្ភាគចក្រដែលលោក ហុក ឡុងឌី ជិះបណ្តាលឱ្យគ្រោះថ្នាក់នោះ ។

ចំពោះមរណភាពរបស់លោក ហុក ឡុងឌី នេះ មជ្ឈដ្ឋាននានាបានបញ្ចេញទស្សនៈខុសៗគ្នា ហើយអ្នកខ្លះទៀត ហាក់បីដូចជាមិនបានសំដែងនូវការសោកស្តាយ ឬអាណិតអាសូរសោះឡើយ ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវជាន់ខ្ពស់សិទ្ធិមនុស្សអាស៊ីប្រចាំទីក្រុងហុងកុង បានប្រាប់អ្នកកាសែតថា មរណភាពរបស់លោក ហុក ឡុងឌី នេះ វាជាការបាត់បង់ដ៏ធំធេងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពីព្រោះកន្លងមកលោក ហុក ឡុងឌី បានធ្វើការរារាំងសកម្មជនសិទ្ធិមនុស្ស និងបញ្ហាសិទ្ធិ

(តទៅទំព័រទី២០)


# BALDI FUNERAL HOME

1331 S. Broad St.
Philadelphia, Pa 19147
Cell: 267-934-9888

**ឈាបណកិច្ចតាមប្រពៃណី**

ឈាបណដ្ឋានមានផ្តល់ជូននូវក្តារមឈូស ទីធ្លាសំរាប់បញ្ចុះ រៀបកំរងផ្កា និងសេវាឈាបណកិច្ចច្រើនប្រភេទ តម្លៃទៅតាមប្រភេទដែលត្រូវការ សេវាឈាបណកិច្ចតាមវប្បធម៌ និងតាមសាសនា និងបំពេញជូនជាកិត្តិយស យើងនឹងខំឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញសេចក្តីត្រូវការ និងបំពេញប្រាថ្នារបស់លោកអ្នក ។

**ពិធីបូជាសព**

"បាល់ឌី" ផ្តល់ជូននូវពិធីបូជាសពគ្រប់បែបជម្រើសរាប់ទាំងឱ្យភ្លើង ក្តារមឈូសសំរាប់សពទន្ទឹមនោះមានសេវាពិធីបុណ្យតាមវប្បធម៌ ការតម្កល់អដ្ឋិ-ធាតុជាចុងបញ្ចប់ ។ មានជួយធ្វើលិខិតក្នុងករណីចង់នាំអដ្ឋិធាតុទៅកាន់ប្រទេសមួយទៀត មានចារឈ្មោះសពនៅលើទំព័រ "ខ្មែរប៉ុស្តិ៍" ជូនផង ។

**សូមសួររកលោក សេង**





(Locates in South Philly, convenience traffic, and free parking)

**Traditional Funeral**

Funeral Home provides caskets, cemetery space, floral arrangements, and funeral service options in various price ranges. Cultural and Religious funeral service is honored. We put full efforts to meet your needs and fulfill your wishes.

**Cremation**

Baldi offers complete cremation options including a combustible casket for the body, on site performing cultural memorial service, final placement of the cremated remains, paperwork assistance in case that need to transport the cremated remains to another country, and the Khmer Post newspaper notices.

# អ្នកច្បាប់មិនយល់ស្របសំដី ហ៊ុន សែន ថាUNTAC អាក្រក់

**ខ្មែរប៉ុស្តិ៍ : មាជ សុវណ្ណារ៉ា**


លោកបណ្ឌិត ឡៅ ម៉ុងហៃ


ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា


លោក នៅ អាកាស៊ី នាឆ្នាំ 1993

•••អ្នកស្រាវជ្រាវច្បាប់ និងសិទ្ធិមនុស្ស របស់អង្គការសិទ្ធិមនុស្សអាស៊ី បានសំដែងការសោកស្ដាយ និងមិនយល់ស្របចំពោះសំដីអំពាវនាវរបស់លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន នូវការអំពាវនាវឱ្យប្រទេសនានាពេលជួបវិបត្តិសូមកុំពឹងអង្គការសហប្រជាជាតិក្នុងការរៀបចំការបោះឆ្នោតឱ្យសោះ ។ ដោយអ្នកច្បាប់រូបនោះបានបញ្ជាក់ថា វាជាបញ្ហាផ្ទាល់ខ្លួន និងជារឿងគណបក្សនយោបាយតែប៉ុណ្ណោះ ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ បានមានប្រសាសន៍ប្រាប់ខ្មែរប៉ុស្តិ៍ថា អង្គការសហប្រជាជាតិបានកែទម្រង់ច្បាប់ប្រព័ន្ធគ្រប់គ្រងល្អណាស់ ហើយថែមទាំងបានជួយរកដំណោះស្រាយរាល់ទំនាស់ក្នុងវិបត្តិបង្ហូរឈាមរវាងខ្មែរ និងខ្មែរ ដោយសន្តិវិធីបានល្អណាស់ ក្នុងការឆ្លងកាត់តាមរយៈការរៀបចំការបោះឆ្នោត នៅឆ្នាំ1993 ដែលអនុលោមទៅតាមកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ឆ្នាំ 1991 ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ បានបន្តថា អ្វីដែលយើងគួរឱ្យចាប់អារម្មណ៍ គឺកម្ពុជា ក្នុងនាមជាប្រទេសសមាជិកអង្គការសហប្រជាជាតិមួយដែរ មិនគួរប្រកូកប្រកាសមិនទទួលស្គាល់អន្តរជាតិនោះទេ ។

ដោយលោកបណ្ឌិត ម៉ុងហៃ បានបញ្ជាក់ថា កន្លងមកអង្គការសហប្រជាជាតិមិនបានទទួលស្គាល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ដែលគ្រប់គ្រងអំណាចដោយលោក ហ៊ុន សែន តាមបែបប្រទេសកាន់របបកុម្មុយនិស្តដែលជារឿងរបស់គេ ហើយអង្គការសហប្រជាជាតិមានសិទ្ធិសើរើនូវអ្វីដែលខុសឆ្គងពីមុនបានគ្រប់ពេលទាំងអស់ ។

លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បានធ្វើការអំពាវនាវជាសាធារណៈកន្លងទៅថ្មីៗនេះឱ្យបណ្ដាប្រទេសដែលកំពុងមានវិបត្តិទាំងអស់កុំឱ្យពឹងអង្គការសហប្រជាជាតិឱ្យជួយរៀបចំការបោះឆ្នោតឱ្យសោះ ។ ដោយបុរសដ៏មានអំណាចខ្លាំងមួយនេះ បានរំលឹកពីអនុស្សាវរីយ៍កាលពីឆ្នាំ1993 ដែលអង្គការសហប្រជាជាតិ (UNTAC) បានចូលមករៀបចំការបោះឆ្នោតនៅកម្ពុជាថា "ជារឿងអាក្រក់" ដោយពួកគេចង់ឱ្យនរណាឈ្នះក៏បាន ហើយមនុស្សម្នាក់អាចបោះឆ្នោតបាន4ទៅ5ដងទៀត ពីព្រោះទឹកខ្មៅជ្រលក់ចង្អុលដៃងាយស្រួលនឹងរលុបខ្លាំងណាស់ ។

លោក ហ៊ុន សែន ថា UNTAC នោះអាក្រក់ខ្លាំងណាស់ មានភាពលំអៀង មិនយុត្តិធម៌ ដោយលោកសូមផ្ដាំទៅបណ្ដាប្រទេសទាំងឡាយដែលមានវិបត្តិសូមកុំទៅពឹងអង្គការសហប្រជាជាតិឱ្យរៀបចំការបោះឆ្នោតឱ្យសោះ ពីព្រោះគេស្មោគគ្រោកណាស់ចង់ឱ្យបក្សណាឈ្នះស្រេចតែគេ ។

ការលើកឡើងរបស់លោក ហ៊ុន សែន គឺបំណងចង់ដាស់តឿនដល់បណ្ដាប្រទេសទាំងអស់កុំឱ្យជឿលើ UNTAC ឱ្យសោះ ពីព្រោះគណបក្សប្រជាជនកម្ពុជាបានចាញ់ឆ្នោតនៅឆ្នាំ1993 ហើយគណបក្សហ៊្វុនស៊ិនប៉ិច បានឈ្នះឆ្នោតលំដាប់ទី1 បាន58អាសនៈ ។ ប៉ុន្តែក្រោយពីគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន បានគ្រប់គ្រងអំណាចបានវិញ នៅឆ្នាំ1998 ដែលរៀបចំដោយក្រុមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (NEC) ភាគច្រើនជាមនុស្សរបស់គណបក្សប្រជាជនកម្ពុជា ធ្វើឱ្យគណបក្សអតីតកុម្មុយនិស្តមួយនេះបានផ្លូវរំលំដៃគូចម្រុះពីការរៀបចំរដ្ឋាភិបាលពីរភាគបី ទៅ50%+1 ក្ដោបអំណាចតែបក្សមួយខ្លួនឯងនៅទីបញ្ចប់ជាស្ថាពរ ។ គណបក្សប្រជាជនកម្ពុជា (CPP) របស់លោក ហ៊ុន សែន បានឡាំបាមិនសុខចិត្ត

(តទៅទំព័រទី១៩)


ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)
Nam Vang Restaurant
571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market)
(215) 742-9488
Open 7 days a week from 9 a.m. – 9 p.m.
បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 យប់

១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ទាំង ឆារសាច់គោ
- មីកន្ទាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ



ទៅណាទៀត ?
បន្ទាប់ពីជួបវេជ្ជបណ្ឌិតរួចហើយ
ឱសថស្ថានWASHINGTON AVENUE
នឹងជួយដល់តម្លៃទិញថ្នាំពេទ្យ ជាពិសេសចំពោះគ្រួសារ ដែលមានប្រាក់ចំណូលតិចតួច

កុំភ្លេចយក
រង្វាន់ដោយឥតគិតថ្លៃ
៣០ សីហា


កាតាបធ្វើដំណើរ

នៅមានរង្វាន់ទីពីរទៀត


ដបវីតាមីនមួយ
វីតាមីន D
វីតាមីន C
វីតាមីនសំរាប់ស្ត្រី
វីតាមីនសំរាប់បុរស

ពិសេសសំរាប់អ្នកមានជំងឺទឹកនោមផ្អែម
ប្រដាប់វាស់ស្ករចំណាមដោយឥតគិតថ្លៃ



* ស្រួលប្រើ
* លឿន
* ត្រឹមត្រូវ
* ឥតឈឺ

Washington Ave
ឱសថស្ថាន
215-755-5100
* សំរាប់តែអ្នកមានធានារ៉ាប់រងខ្លះ
600 Washington ave, Unit 18E Phila, PA - phone: 215-755-5100

# ទស្សនៈ: លោក ម៉ម យិន : រំលឹកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣

•••ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺជាថ្ងៃនៃប្រវត្តិសាស្ត្រខ្មែរមួយ ដែលជនជាតិខ្មែរបានឃើញ និងដឹងពិតដោយផ្ទាល់ភ្នែក ថែមទាំងបានចូលរួមបំពេញបុជនីយកិច្ចនៅក្នុងការតវ៉ាទាមទារឯករាជ្យពេញបរិបូរសំរាប់មាតុភូមិ និងជនជាតិខ្មែរ ឱ្យបានចេញផុតពីអំណាចអាណានិគមនិយមបារាំងសែស ។

ឯករាជ្យពេញបរិបូរ មិនមែនបានមកដោយសារតែមេដឹកនាំតែម្នាក់នោះទេ ។ ឈាមស្រស់ និងជីវិតជនជាតិខ្មែរស្នេហាជាតិ មាតុភូមិរាប់ម៉ឺនសែននាក់បានពលី ចាប់តាំងពីដើមទសវត្សឆ្នាំ១៩៤៥ ប្រឆាំងនឹងការត្រួតត្រានៃអាណានិគមរបស់បារាំង ។

កម្លាំងកងទ័ពប្រដាប់អាវុធខ្មែរឥស្សរៈ បានរត់ចូលព្រៃភ្នំក្រាំង ដើម្បីវាយអុកឡុកកងទ័ពខ្មែរក្រោមការបញ្ជាការរបស់នាយទាហានបារាំងយ៉ាងអង់អាចក្លាហានបំផុត រួមគ្នាជាមួយការក្រោកឈរឡើងនៃប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេស ។ ដោយសារតែទឹកចិត្ត គោលជំហរ សតិស្មារតី មនសិការ ឆន្ទៈប្តេជ្ញាស៊ូលះបង់ប្តូរផ្តាច់នេះហើយ ទើបបណ្តាលឱ្យព្រះរាជាខ្មែរត្រូវតែស្តេច ចេញទៅចរចាតវ៉ាទាមទារឯករាជ្យពេញបរិបូរ ក្នុងព្រះនាមព្រះអង្គជាស្តេចម្ចាស់ផែនដី ដោយមានវីរជនសំខាន់១ មួយចំនួនជាក្រុមទីប្រឹក្សាអមព្រះអង្គផង ។

អាណានិគមបារាំង ក្រោយពីបានដឹង និងឃើញសន្ទុះទឹកចិត្តនៃជនជាតិខ្មែរទូទាំងប្រទេសហើយ ទើបសម្រេចចិត្តថា ត្រូវតែយល់ព្រមប្រគល់ឯករាជ្យពេញបរិបូរដល់ប្រទេស និងជនជាតិខ្មែរ នាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ។ ជនជាតិ ខ្មែរបានចាត់ទុកថ្ងៃនេះ ជាថ្ងៃរំលឹកពិធីបុណ្យខួបឯករាជ្យជារៀងរាល់ឆ្នាំ ហើយចារឹកទុកជាថ្ងៃប្រវត្តិសាស្ត្រនៃជោគជ័យដ៏ឧត្តមខ្ពង់ខ្ពស់បំផុត ហើយមានតម្លៃដ៏ខ្ពស់បំផុតរបស់មាតុភូមិ និងជាតិសាសន៍ខ្មែរ ។

ពីមួយឆ្នាំទៅមួយឆ្នាំ ឱ្យតែដល់ថ្ងៃទី៩ វិច្ឆិកា ជនជាតិខ្មែរទូទាំងប្រទេស រួមជាមួយមេដឹកនាំ និងរដ្ឋាភិបាល តែងតែប្រារព្ធធ្វើបុណ្យ ទិវារំលឹកថ្ងៃខួបកំណើតឯករាជ្យពេញបរិបូររបស់មាតុភូមិជាតិខ្មែរ ដោយអធិកអធម ។

- តើរយៈពេលប៉ុន្មានឆ្នាំ ដែលមាតុភូមិ និងជនជាតិខ្មែរ បានទទួលសេចក្តីសប្បាយរីករាយ និងសេចក្តីសង្ឃឹមនេះ ?

- តើមានព្រឹត្តិការណ៍អ្វីកើតឡើង ដែលបានបណ្តាលឱ្យមាតុភូមិ និងជនជាតិខ្មែរមានទុកសោកហើយរលាយអស់សេចក្តីសង្ឃឹម ?

ប្រមាណជាង ១៧ឆ្នាំប៉ុណ្ណោះ មកដល់ឆ្នាំ១៩៦៨-៧០ មាតុភូមិ និងជនជាតិខ្មែរ បានចាប់ផ្តើមមានអសន្តិសុខ ផ្ទុះចេញជាភ្លើងសង្គ្រាមក្នុងស្រុកមួយកើតចេញមកពីកងទ័ពវៀតកុង យៀកកុង ពួកកុម្មុយនិស្តខាងជើង ចូលមកជ្រកកូនទៅក្នុងប្រទេសខ្មែរ អនុញ្ញាតដោយប្រមុខរដ្ឋខ្មែរ ដើម្បីចេញទៅវាយប្រយុទ្ធរំដោះដែនដីយួនខាងត្បូង។ រដ្ឋសភាជាតិ បានបោះឆ្នោតអនុម័តដកតំណែងជាសម្តេចប្រមុខរដ្ឋកម្ពុជា កាលពីថ្ងៃទី១៨ មិនា ឆ្នាំ១៩៧០ ។


លោក ម៉ម យិន

ព្រឹត្តការណ៍កើតជាភ្លើងសង្គ្រាមឆាបឆេះឡើង ក្រោយពីថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ នោះហើយ ដែលចាប់ផ្តើមឱ្យជនជាតិខ្មែរយល់ដឹងថា ឯករាជ្យពេញបរិបូរថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ត្រូវបានបាត់បង់ជាពិតប្រាកដ បើសិនណាជាកងទ័ពជាតិ និងជនជាតិខ្មែរទ្រទ្រង់ការពារទប់ទល់ នឹងការវាយប្រហាររបស់យួនព្រៃ យៀកកុង នោះពុំបានទេ ។

គួរអនិច្ចា និងសង្វេគដល់ជីវិតយុទ្ធជននៃកងទ័ពជាតិ និងជនជាតិខ្មែរ បានបាត់បង់ជីវិតអស់ប្រមាណ ៥០ម៉ឺននាក់ ។ បន្ទាប់មកថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម គាំទ្រដោយយួនក្រហម ចិនក្រហម និងកូរ៉េក្រហម បានយកជ័យជំនះបាន ដោយចុងកាណុង ក្រោមទង់ជ័យដ៏ក្រហមឆ្អិនឆ្អៅនៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា ។

ចាប់តាំងពីឆ្នាំ១៩៧០ នោះហើយ ដែលទិវាថ្ងៃបុណ្យខួបឯករាជ្យខ្មែរ ត្រូវបានបាត់បង់ទៅហើយ បានក្លាយទៅជាប្រទេស និងជនជាតិរស់នៅក្រោមអំណាចផ្តាច់ការកាប់សម្លាប់ជនជាតិខ្មែរ អស់ប្រមាណជាងបី(៣)លាននាក់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

លុះមកដល់ឆ្នាំ១៩៧៩ មានព្រឹត្តិការណ៍មួយទៀត បានបង្កើតឡើងដោយកងទ័ពយួន វៀតណាមសង្គមនិយម ប្រមាណពីរសែននាក់ និងទីប្រឹក្សា អ្នកជំនាញការពីរពាន់នាក់ បានលើកទ័ពចូលវាយលុកលុយ ដេញកំចាត់ខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យ ដោយយកលេសថា ជួយ សង្គ្រោះជីវិតខ្មែរឱ្យរួចពីខ្មែរក្រហម ។

រួចហើយកងទ័ពយួន បានតែងតាំងក្រុមមេដឹកនាំថ្មីមួយ ដែលនៅក្រោមបញ្ជាការកងទ័ពជំនួញការយួន យៀកណាម រហូតមកដល់សព្វថ្ងៃនេះ ។

ក្រុមមេដឹកនាំថ្មីនេះ បានកំណត់យកថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃជោគជ័យ ជាថ្ងៃធ្វើឱ្យប្រទេសកម្ពុជា មានសន្តិភាព រីកចំរើន លូតលាស់គ្រប់វិស័យ និងមានមេដឹកនាំមានប្រាជ្ញាឈ្លៀវឆ្លាត មានឧត្តមគតិ និងគតិបណ្ឌិតមិលជាងមេដឹកនាំខ្មែរពីសម័យមុន១ទាំងអស់ ។

ទោះបីជាមានជនជាតិខ្មែរជាច្រើន ដែលមានទស្សនៈយល់ឃើញថា ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលមាតុភូមិ និងជនជាតិខ្មែរ ត្រូវបាត់បង់ឯករាជ្យពេញបរិបូរយ៉ាងណាក៏ដោយ ក៏មេដឹកនាំខ្មែរសម័យនេះ បានថ្លែងប្រកាសជាផ្លូវការថា ប្រទេសកម្ពុជា នៅតែប្រារព្ធពិធីបុណ្យរំលឹកឯករាជ្យខួបគំរប់ ៥៥ឆ្នាំ ចាត់ទុកជាឯករាជ្យនៅតែមានជីវិតគង់វង្សនៅរហូតមកដែរ ។ គ្មានវិស័យណាមួយ ដែលគេមើលឃើញថា ប្រទេសខ្មែរ ជាប្រទេសឯករាជ្យពេញបរិបូរនោះទេ ដូចជាសេដ្ឋកិច្ចជាតិ កងទ័ពជាតិ សិក្សាធិការអប់រំជាតិ រដ្ឋបាលជាតិ ជាពិសេស វិស័យជនជាតិ និងអន្តោប្រវេសន៍ជាតិយួន បានចូលមករស់នៅក្នុងស្រុកខ្មែរ រាប់លាននាក់ដោយសេរី ព្រមទាំងបញ្ហាព្រំដែន ដែលជនជាតិខ្មែរជាច្រើនមើលឃើញថា ជនជាតិយួន និងសៀមរំលោភបំពានយកបានស្រេចតាមតែអំពើចិត្ត ។ មេដឹកនាំខ្មែរគ្មានសិទ្ធិ សេរីភាពក្នុងការចូលរួមការពារផ្ទៃក្បាលបានទេ ។

ប្រទេសជាតិឯករាជ្យពិតប្រាកដ លុះត្រាតែប្រទេស និងជនជាតិមានសិទ្ធិសេរីភាពពេញបរិបូរ មានឧត្តមភាពពេញបរិបូរ មានឥស្សរភាពពេញបរិបូរ ក្នុងការដឹកនាំគ្រប់គ្រង និងការចាត់ចែងរៀបចំវាសនាប្រទេសជាតិ ដោយស្ថិតនៅក្រោមគោលជំហរជាសមភាព កិត្តិយស និងអង់អាចក្លាហាន ដោយគ្មានការគាបសង្កត់ពីជនជាតិដទៃណាមួយឡើយ ។

បើសិនណាជាប្រទេសណាមួយ ត្រូវបានប្រទេសដទៃណាមួយលើកទ័ពចូលឈ្លានពានហើយត្រួតត្រា រួចហើយតែងតាំងក្រុមមេដឹកនាំមួយឱ្យដឹកនាំជំនួស ក្រោមការបង្គាប់បញ្ជានៃកងទ័ព និងទីប្រឹក្សា អ្នកជំនាញការប្រទេសនោះ ដូច្នេះពុំអាចចាត់ទុកក្រុមដឹកនាំប្រទេសនោះ ជាឯករាជ្យពេញបរិបូរទៅបានទេ ។

ដូច្នេះហើយក្រុមមេដឹកនាំតែងតាំងនេះ ត្រូវតែប្រើប្រាស់គ្រប់វិធានការ ដើម្បីតម្រូវចិត្តរបស់ចៅហ្វាយនាយ ឱ្យតែខ្លួនឯងបានកាន់អំណាចជារៀងរហូតអស់មួយជីវិត ។ ទោះបីជាការដឹកនាំនោះប្រកបដោយអគតិ អយុត្តិធម៌ ប៉ះពាល់ដល់អាយុជីវិតប្រជាជាតិ និងប្រទេសយ៉ាងណាក៏ដោយ ក៏មេដឹកនាំតែងតាំងនោះ ពុំអាចឈរនៅក្នុងជួរជាមួយជនជាតិរបស់ខ្លួនបានឡើយ ។

សរុបសេចក្តីទៅ ឯករាជ្យរបស់ប្រទេសកម្ពុជា នាសព្វថ្ងៃនេះ ពុំអាចចាត់ទុកថា ជាឯករាជ្យពិតប្រាកដបានទេ ដូចគ្នាប្រទេសខ្មែរ កាលពីនៅក្រោមអំណាចអាណានិគម កាលពី ៥៥ឆ្នាំមុននោះទេវិញទេ ពីព្រោះប្រទេស និងជនជាតិខ្មែរសព្វថ្ងៃកំពុងរស់នៅក្រោមអំណាចត្រួតត្រារបស់អាណានិគមថ្មី យួនវៀតណាមសង្គមនិយម ដែលបានប្រើកលល្បិចស្របច្បាប់មួយ អាចបន្លំក្លែងខ្លួនឱ្យដូចជាជនជាតិខ្មែរបេះបិត និងប្រើវិធីចិត្តសាស្ត្រដ៏ល្អប្រពៃ បានបញ្ឆោតមតិជាតិ និងអន្តរជាតិ ៕



# ខ្មែរ_អាមេរិកាំងនៅហ្វីឡា ចេញទៅបោះឆ្នោតច្រើន

**ដោយ : អ៊ុម ឈឿម**

•••ថ្ងៃទី០៤ ខែវិច្ឆិកា កន្លងមកនេះ ជាទិវាដ៏មានសារប្រយោជន៍បំផុតសម្រាប់ពលរដ្ឋអាមេរិកាំង ដែលមានសិទ្ធិបោះឆ្នោតបានបំពេញនូវកាតព្វកិច្ច និងសិទ្ធិរបស់ខ្លួនក្នុងការសម្រេចយ៉ាខាងត្បូង និងទើបបានបោះឆ្នោតជាលើកដំបូងបានប្រាប់ខ្មែរប៉ុស្តិ៍ថា : លោកបានចេញពីធ្វើការមុនម៉ោង ដើម្បីប្រញាប់ទៅបោះឆ្នោត ពីព្រោះថ្ងៃនេះ (០៤ វិច្ឆិកា ) ក្រុមហ៊ុនពុំបានអនុញ្ញាតិឱ្យឈប់ឡើយ ។



លោក ប៊ុរ៉ា



លោក ចាន់ សាវ៉ាន



លោក ហ៊ូ តេង

ជ្រើសរើសយកប្រមុខដឹកនាំប្រទេស ដែលពោរពេញទៅដោយសក្តានុពលស្មើរគ្រប់វិស័យមួយនេះ ។

ចាប់តាំងពីព្រលឹមអរុណោទ័យម៉ោង៧រហូតដល់រាត្រីម៉ោង៨ គេសង្កេតឃើញមនុស្សប្រុស-ស្រីម៉ឺដេដាសគ្រប់ពណ៌សម្បុរប្រមាណជា១៣០លាននាក់ បានបំពេញនូវភារកិច្ចដ៏ចម្បងរបស់ខ្លួន ក្នុងនាមជាប្រជាពលរដ្ឋអាមេរិកាំងប្រកបដោយទឹកមុខស្រស់ស្រាយ ។

ពលរដ្ឋខ្មែរ-អាមេរិកាំង នៅតំបន់ហ្វីឡា-ដែលហ្វីយ៉ា នាឆ្នាំនេះ បានបំពេញនូវភារកិច្ច និងសិទ្ធិរបស់ខ្លួនបានយ៉ាងច្រើនគួរគត់សំគាល់ ។

លោក ហ៊ូ តេង និងលោក ចាន់ សាវ៉ាន់ ជាខ្មែរ-អាមេរិកាំង រស់នៅតំបន់ហ្វីឡាដែលហ្វី

រីឯលោក ធន់ គូ មានទីលំនៅនាតំបន់ហ្វីឡាខាងជើង ដែលតែងតែបោះឆ្នោតជាប្រចាំនោះ បានឱ្យខ្មែរប៉ុស្តិ៍ដឹងដែរថា : លោកសុខចិត្តខាតធ្វើការចំនួនពីរម៉ោង ដើម្បីប្រញាប់មកបោះឆ្នោត ពីព្រោះខ្លាចមានការស្ទះចរាចរ និងម្យ៉ាងខ្លាចមានការឈរតម្រង់ជួរយូរ ទើបលោកចេញមកមុខម៉ោងដូច្នេះ ។ ហើយនៅឆ្នាំនេះ ពលរដ្ឋខ្មែរ-អាមេរិកាំង នៅតំបន់ហ្វីឡាដែលហ្វីយ៉ាទាំងមូលហាក់មានការចាប់អា-រម្មណ៍ និងយល់ដឹងកាន់តែច្រើនអំពីតម្លៃនៃការបោះឆ្នោត ។

អ្នកស្រី រ៉ង ស៊ិន នាយិកាប្រតិបត្តិស្តីទីរបស់សមាគមន៍ប្រចាំតំបន់ហ្វីឡាដែលហ្វីយ៉ា បាន

(តទៅទំព័រទី១២)




**Authentic Chinese & Vietnamese Cuisine**
**Very Delicious and Nutritious**

-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ

***ពិសេសនៅពេលរាត្រី :*** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)

***ពិសេសដោយម្ចាស់ហាង:*** មានចុះតម្លៃ **10%** លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement



Manager Special :
-10% OFF
LUNCH & DINNER
Present This Coupon

## ចង់ចេញពីភាពទ្រុឌទ្រោម? RELIV អាចប្តូររូបរាងកាយឱ្យមាំទាំបាន



Dr. Earleen Ong, Fellow of Geriatric Medicine, Certified Family Physician
Dr. John Harold Ong, Orthomolecular Medicine, Associate of Geriatric Medicine

**Reliv: Nutrition for the 21st Century**

Today's modern processing techniques rob essential nutrients from much of our food. Reliv restores the balance by delivering a unique blend of the vitamins, antioxidants, minerals, proteins, amino acids and phytonutrients the body needs to restore energy, fight off infections and feel great — every day.




WWW.RELIV.COM

☞ ពិសារ Reliv រាល់ថ្ងៃ គឺនាំឱ្យមានកម្លាំងកាយ រូបរាងមាំមួនសម្ផស្សស្រស់បស់ឡើងបាន

☞ Reliv អាចទប់ស្កាត់នូវជំងឺមួយចំនួនធំ ដែលកើតមកពីការពិសារចំណីអាហារខ្វះជីវជាតិ ធ្វើឱ្យសរីរាង្គគាំងដំណើរ

☞ ពិសារ Reliv លោក-អ្នកនឹងដឹងពីប្រសិទ្ធភាពចាប់តាំងពីថ្ងៃដំបូង ដែលលោក-អ្នកប្រើ Reliv នេះភ្លាម ។

សូមទូរស័ព្ទជាវនៅលេខ : (636) 537 9715
. ដោយផ្តល់លេខសំគាល់ : RNC .7070 438001
បញ្ជាទិញ 1. RELIV CLAASIC មួយកំប៉ុង
2. Reliv INNERGINE មួយកំប៉ុង ដែលជាចំណីជីវជាតិ
លាយ RELIV 1 និង RELIV 2 ម្នាងមួយស្លាបព្រាក្នុងទឹកផ្លែឈើហើយពិសារម្តង ឬពីរដងក្នុងមួយថ្ងៃ ទៅតាមភាពទ្រុឌទ្រោមនៃរូបរាងកាយ
" ភាពរឹងមាំកើតឡើងស្មើរជឿមិនបាន "

ម្យ៉ាងទិញទៀត : នៅពេលឃើញប្រសិទ្ធភាពនៃ Reliv លោកអ្នកនឹងមានជំនឿថាអាចចែកចាយឱ្យមនុស្សច្រើនទៀតបាន

សូមទាក់ទងមកយើងខ្ញុំ ដើម្បីចុះឈ្មោះជា RELIV DISTRIBUTOR បន្តទៅទៀត លោកអ្នកអាចនឹងចំណេញប្រាក់ច្រើន ដោយសារតែបានជួយអ្នកដទៃឱ្យមានសុខភាពល្អដូចលោកអ្នកបាន

ទូរស័ព្ទនៅ Philadelphia :(267) 254 8758 នៅ VIRGINIA 703 415- 6257

# សន្ធិសីទទីក្រុងប៉ារីស 23តុលា...

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល**

ការបង្ហូរឈាមខ្មែរមិនឈប់ឈរនេះ ក៏បានលេចចេញនូវការចរចារវាង ហ៊ុន សែន នាយករដ្ឋមន្ត្រីខ្មែរ និងសម្តេចនរោត្តម សីហនុ រហូតសំរេចបានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១ ។

តាមរយៈកិច្ចព្រមព្រៀងដែលមានប្រទេសហត្ថលេខីចំនួន១៨ប្រទេសចូលរួមនេះ បានបង្កើតជាក្រុមអង្គការបណ្តោះអាសន្នសហប្រជាជាតិចូលមករៀបចំការបោះឆ្នោតនៅកម្ពុជានៅឆ្នាំ ១៩៩៣ ។ ការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការបណ្តោះអាសន្នអង្គការសហប្រជាជាតិនេះធ្វើឱ្យគណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបាននូវជ័យជំនះ ប៉ុន្តែគណបក្សប្រជាជនកម្ពុជាបានច្រានចោលលទ្ធផលនេះ ។

លទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីដែលបានសាបព្រួសលើប្រទេសកុម្មុយនីស្តមួយនេះ បានជួបប្រទះនូវអំពើហិង្សា ការមិនសូវគោរពច្បាប់ និងអំពើពុករលួយគួរឱ្យស្អប់ខ្ពើម ។

ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ចាប់តាំងពីមានកិច្ចព្រមព្រៀង ២៣ តុលា ១៩៩១ មក ប្រទេសកម្ពុជាបានបញ្ចប់នូវភ្លក់ភ្លើងសង្គ្រាមទាំងក្តៅ និងត្រជាក់គ្រប់ទិសទី ហើយការអភិវឌ្ឍក៏កើតមានមួយចំនួនផងដែរ ។

ទាក់ទិនទៅនឹងកិច្ចព្រមព្រៀងថ្ងៃទី២៣ តុលា ១៩៩១ រហូតមកដល់ពេលនេះមានរយៈពេល ១៧ ឆ្នាំហើយ ត្រូវបានអង្គការសង្គមស៊ីវិលបញ្ចេញនូវទស្សនៈប្រហាក់ប្រហែលគ្នាថា "ធ្វើឱ្យមានសន្តិភាពគ្រប់ទិសទី និងការអភិវឌ្ឍកើតមានជាបន្តបន្ទាប់ "។

ក្នុងកម្មវិធីជជែកពិភាក្សាមួយដែលរៀបចំឡើងដោយសមាគមសិទ្ធិមនុស្សអាដហុក កាលពីថ្ងៃទី២២ ខែតុលា នោះ លោកស្រី ធីតា ឃឹះ នាយិកាប្រតិបត្តិអង្គការសីលការបានឱ្យដឹងថា កិច្ចព្រមព្រៀង ២៣ តុលា នៅទីក្រុងប៉ារីសនេះ បានជួយដល់សង្គមខ្មែរច្រើនណាស់ ដូចជាបង្កលក្ខណៈឱ្យមានការបញ្ចេញមតិរបស់អង្គការសមាគមគណបក្សនយោបាយ និងការអភិវឌ្ឍនូវរាល់ហេដ្ឋារចនាសម្ព័ន្ធរបស់ជាតិ បើទោះបីជាមានការយឺតយ៉ាវក៏ដោយ ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ អ្នកស្រាវជ្រាវជាន់ខ្ពស់សិទ្ធិមនុស្សអាស៊ី បានមានប្រសាសន៍ថា តាមរយៈកិច្ចព្រមព្រៀងបាននាំមកនូវដំណោះស្រាយសំរាប់កម្ពុជា គឺបញ្ចប់ភ្លក់ភ្លើងសង្គ្រាមផ្ទៃក្នុងរវាងខ្មែរ នឹងខ្មែរ ដែលកើតមានជាយូរឆ្នាំមកហើយ ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ បានបន្តថា សន្ធិសីទ នេះវាផ្តើមចេញពីភាពធូរស្រាលរបស់លោកខាងលិច ដែលបានជួយជំរុញឱ្យបរិយាកាសនៅកម្ពុជាកាន់តែល្អ ហើយសង្គ្រាមនៅកម្ពុជាក៏បានចប់ដែរ ។ ម្យ៉ាងទៀត ប្រទេសចិនជាមេខ្លោងរបស់ខ្មែរក្រហមក៏មានការធូរស្រាលផ្នែកទំនាស់វិបត្តិ និងសហភាពសូវៀត ជាមេខ្លោងរបស់ប្រទេសយួនបានកាត់បន្ថយទំនាក់ទំនងជាមួយនិងប្រទេសចិនផងដែរ ។

លោកបណ្ឌិត ឡៅ ម៉ុងហៃ បន្តថា កិច្ចព្រមព្រៀងនោះបានបង្ខំឱ្យកម្ពុជាលប់ចោលនូវរបបកុម្មុយនីស្តគោរពនូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សគោរពច្បាប់ជាមូលដ្ឋាន ។ ជាពិសេសកំណត់នយោបាយសំរាប់ប្រទេសកម្ពុជាដែលមានប្រទេសហត្ថលេខី១៨ ដឹងឮ ។

លោកបណ្ឌិតបញ្ជាក់ថា កិច្ចព្រមព្រៀងនោះតំរូវឱ្យកម្ពុជា គោរពនូវច្បាប់អន្តរជាតិ គោរពបូរណភាពទឹកដី សន្តិសុខ ឯករាជ្យ និងប្រជាពលរដ្ឋដោយគ្មានការរំលោភបំពានពីប្រទេសជិតខាង ។

ចំណែកលោក ធន សារាយ ប្រធានសមាគមសិទ្ធិមនុស្សអាដហុកបានឱ្យដឹងថា កិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃ២៣ តុលា នោះមានសារសំខាន់ជាប្រវត្តិសាស្ត្រសំរាប់ប្រទេសកម្ពុជា ប៉ុន្តែលោកក៏បានសោកស្តាយណាស់ដែរ ដែលត្រូវរដ្ឋាភិបាលលប់ថ្ងៃចេញពីបុណ្យជាតិ ។ ទិវានេះ បានបង្កើត



លោកបណ្ឌិត ឡៅ ម៉ុងហៃ

ឱ្យមានសន្តិភាពសំរាប់កម្ពុជារហូតដល់សព្វថ្ងៃ ហើយបាននាំមកនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញសេរីពហុបក្ស ដែលប្រទេសយើងធ្លាប់មានរយៈពេលខ្លីក្នុងឆ្នាំ ១៩៤៧, ១៩៥៦, ១៩៧០-១៩៧៥ និងចាប់ពីមានកិច្ចព្រមព្រៀងនេះ គឺអំឡុងឆ្នាំ ១៩៩៨ មក ។

លោក ធន សារាយ បានបន្តថា ទោះបីជាយ៉ាងណាបន្ទាប់ពីមានកិច្ចព្រមព្រៀងនេះរួចមក គេឃើញមានការអភិវឌ្ឍសេដ្ឋកិច្ចជាបន្តបន្ទាប់ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនផងដែរ ។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សំគាល់នោះ គឺការខ្វះខាតនូវយន្តការដោះស្រាយជំលោះនៅខ្សោយ ការគោរពសិទ្ធិមនុស្សនៅមានកំរិត និងគម្លាតភាពរវាងអ្នកមាន និងអ្នកក្រកាន់តែខ្លាំង ។

លោក សុន ម៉េង ប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញ បានបញ្ចេញទស្សនៈផ្ទាល់ខ្លួនថា សន្ធិសីទនេះបានជួយឱ្យប្រទេសកម្ពុជាមានសន្តិភាព និងការរីកចំរើនមួយចំនួនផងដែរ ហើយលោកក៏បានស្នើសុំឱ្យប្រទេសហត្ថលេខីជួយដោះស្រាយបញ្ហាជំលោះនៅតាមព្រំដែនខ្មែរ-សៀមផង ។ បើសិនជាគ្មានដំណោះស្រាយឱ្យបានឆាប់នោះទេ ការបង្ហូរឈាមអាចនឹងកើតមានទៀតរវាងទ័ពខ្មែរ-សៀម ។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨ គឺជាខួបលើកទី១៧ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលជាប្រវត្តិសាស្ត្រជូនប្រជាពលរដ្ឋខ្មែរនូវសុខសន្តិភាព ដែលជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស និងធានានូវបូរណភាពឯករាជ្យនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ តាមបែបប្រជាធិបតេយ្យ ។

ទាក់ទិននឹងបញ្ហានេះ គណបក្សសិទ្ធិមនុស្សបានចេញនូវសេចក្តីថ្លែងការណ៍ថា ការអនុវត្តកិច្ចព្រមព្រៀងប៉ារីស មិនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់គោរពតាមស្មារតីនៃកិច្ចព្រមព្រៀងនេះត្រឹមត្រូវនៅឡើយទេ ។

ផ្ទុយទៅវិញរាជរដ្ឋាភិបាលបានលុបបំបាត់ថ្ងៃបុណ្យខួបនៃកិច្ចព្រមព្រៀងជាប្រវត្តិសាស្ត្រនេះ ហើយបែរជាមកលើកតំកើងថ្ងៃ៧មករា ឆ្នាំ១៩៧៩ ទៅវិញ ។

ដោយមើលឃើញនូវគ្រោះថ្នាក់របស់ប្រទេសជាតិចំពោះមុខ និងទៅអនាគតគណបក្សសិទ្ធិមនុស្ស ដែលមានឥស្សរជនមួយចំនួនចេញមកពីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដែលជាហត្ថលេខីមួយនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ទទូចយ៉ាងហ្មឹងហ្មាត់ឱ្យរាជរដ្ឋាភិបាលបច្ចុប្បន្នអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និងម៉ត់ចត់បំផុតនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីនាំគ្នាកសាងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សពិតប្រាកដ ការគោរពសិទ្ធិមនុស្ស ហើយនិងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចេរភាពស្របតាមឆន្ទៈ និងប្រយោជន៍ប្រជាពលរដ្ឋខ្មែរយើង ។

ម្យ៉ាងវិញទៀត គណបក្សសិទ្ធិមនុស្ស សូមអំពាវនាវដល់ប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសទាំងអស់គោរព និងអនុវត្តនូវស្មារតីនៃកិច្ចព្រមព្រៀងនេះ ឱ្យបានម៉ត់ចត់រួមទាំងគោរពនូវអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹត្យភាព ឯកភាពជាតិនៃកម្ពុជា ។

ជាពិសេស ប្រទេសហត្ថលេខី ដែលមានព្រំដែនជាប់នឹងព្រះរាជាណាចក្រកម្ពុជាដកកងទ័ពរបស់ខ្លួនចេញពីទឹកដីខ្មែរជាបន្ទាន់ស្របតាមមាត្រា១៨ ស្តីពីការធានាអន្តរជាតិនៃកិច្ចព្រមព្រៀង ក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។

ចំណែកខ្មែរម្ចាស់ស្រុកបានចេញសេចក្តីថ្លែងការណ៍ ក្នុងឱកាសខួបឆ្នាំទី១៧ នៃសន្ធិសីទសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ ថា បើរដ្ឋាភិបាលខ្មែរនៅតែបំភ្លេចកិច្ចព្រមព្រៀងទីក្រុងប៉ារីសទេនោះ គឺរដ្ឋាភិបាលខ្មែរបាននាំ "នាំត្រីខ្មែរដើរចូលជុចយួនហើយ " ។

ពាក្យសំដីរបស់ "ប្រិយមិត្តជិតខាងដ៏ល្អរបស់ខ្មែរ " ដែលពោលថា "សាមគ្គីជាប្រពៃណី និងសហប្រតិបត្តិការជានិរន្តរ៍ និងដោយស្មោះស្ម័គ្រ" ជាករណីកិច្ចស្ម័យប្រវត្តិមួយ ដែលស្ថិតនៅក្រោមការដឹកនាំរបស់យួន ជាពិសេសពីសំណាក់អ្នកទទួលខុសត្រូវខាងកងទ័ពការពារជាតិនៃប្រទេសទាំងពីរ ដែលត្រូវតែអនុវត្តជាដាច់ខាត ។

កាលពីថ្ងៃទី ១៧ មករា ឆ្នាំ ១៩៧៩ " ប្រិយមិត្តជិតខាងដ៏ល្អរបស់ខ្មែរ " នេះ បានមកស្រោចស្រង់ខ្មែរឱ្យចេញផុតពីរបប ប៉ុល ពត ម្តងហើយ តែមិនមែនមកកំទេចតែកងកម្លាំង ប៉ុល ពត ទេ បែរជាមកកំទេចទាំងប្រជាពលរដ្ឋខ្មែរ ដូចជាតាមរយៈ "កម្មវិធី ក៥ " ជាដើម ។

មិនមត្រឹមតែប៉ុណ្ណោះ នៅក្នុងឱកាសរដ្ឋប្រហារ កាលពីខែកក្កដា ឆ្នាំ១៩៩៧ " ប្រិយមិត្តជិតខាងដ៏ល្អរបស់ខ្មែរ "នេះ ថែមទាំងបានឆ្លៀតកំទេចអ្នកស្នេហាជាតិខ្មែរមួយចំនួនធំទៀតផង គេនៅតែបន្តកំទេចគណបក្សនយោបាយខ្មែរ ដែលមានសក្តានុភាពអាចដណ្តើមយកអំណាចពីគណបក្សប្រជាជនកម្ពុជាបានទៀតផង ។

ខ្មែរយើងនៅចាំបានថា កាលពីថ្ងៃទី១៥មីនា ឆ្នាំ២០០៨ ឧត្តមសេនីយ ផុង កាងថាញ់ រដ្ឋមន្ត្រីការពារប្រទេសយួនបានអញ្ជើញលោក ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិនៃប្រទេសកម្ពុជា ដើម្បីមកជជែកពិភាក្សា ។ នៅក្នុងឱកាសពិភាក្សានោះ លោក ទៀ បាញ់ បានអួសប្រទេសកម្ពុជាឱ្យដើរចូលជុចរបស់យួន ព្រោះហ៊ានធ្វើការសុំថា ឱ្យយួនមកជួយការពារសន្តិសុខនៅកម្ពុជា បើសិនជាកម្ពុជាមានបញ្ហាក្នុងពេលបោះឆ្នោតខែកក្កដា ឆ្នាំ២០០៨កន្លងមកនេះ។ ចៃដន្យអ្វីស្រាប់តែវិបត្តិព្រះវិហារ បានកើតមានឡើង នៅថ្ងៃទី១៥ កក្កដា ២០០៨ ដោយកងទ័ពសៀម បានចូលមកលុកលុយក្នុងដីខ្មែរទីវាលឥន្ទ្រីនៅជុំវិញតំបន់ប្រាសាទព្រះវិហារ ។

ក្រោយពីប្រទេសកម្ពុជាបានប្រកាសថានឹងប្តឹងទៅក្រុមប្រឹក្សាសន្តិសុខអចិន្ត្រៃយ៍នៃអង្គការសហប្រជាជាតិ អំពីកិច្ចរំលោភមកលើបូរណភាពទឹកដីនៅនៃប្រទេសកម្ពុជាពីសំណាក់ប្រទេសសៀម កាលពីថ្ងៃទី២០ កក្កដា ២០០៨ នោះមក ស្រាប់តែ "ប្រិយមិត្តជិតខាងដ៏ល្អរបស់ខ្មែរ" គឺយួន ដែលជាសមាជិកមួយនៅក្នុងក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ក៏បានខិតខំធ្វើការទូតរបស់ខ្លួន ហើយបានប្រកាសពីអង្គការសហប្រជាជាតិ មកថាឱ្យកម្ពុជា និងសៀម ធ្វើការចរចាជា ទ្វេភាគីតទល់ផ្ទាល់តែពីរនាក់សិន ក្នុងការរកដំណោះស្រាយអំពីវិបត្តិព្រះវិហារនេះ។

នៅក្នុងន័យនេះ "ប្រិយមិត្តជិត ខាងដ៏ល្អរបស់ខ្មែរ " បានដឹងមុនច្បាស់ណាស់ថា ការចរចារកដំណោះស្រាយទ្វេភាគីរវាងកម្ពុជា និងសៀមរបៀបនេះ គឺច្បាស់ជាមានលទ្ធផលមួយ គឺការផ្ទុះអាវុធជាប្រាកដ ដោយសារតែសៀមមានកម្លាំងដ៏មហិមា ចំណែកឯខ្មែរយើងវិញ ក៏មិនអាចបោះបង់សិទ្ធិរបស់ខ្លួនដោយសារតែការឈ្លានពានទាំងកំរោលរបស់សៀមនោះបានដែរ ។

(តទៅទំព័រទី១៩)

From :Philadelphia

"Happy Thanksgiving"

ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe`s Auto Service

State and Emission
Inspection General
Repairs and Maintenance




MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកំរិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬផុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

ទស្សនៈ លោក គីម កៀន :

# អ្វីទៅជាវប្បធម៌កង់រទេះគោ ?

•••ចាប់ពីពេល Untac ចូលរៀបចំស្រុកខ្មែរមកទល់នឹងពេលនេះ យើងសង្កេតឃើញវប្បធម៌ប្លែកៗ ចូលមកវាតទីនៅក្នុងជីវភាពរស់នៅរាល់ថ្ងៃរបស់បងប្អូនខ្មែរយើង ជំនួសវប្បធម៌យួនកំពុងតែចង់ចាក់ឫសនៅលើដែនដីដ៏កំសត់នេះ ដូចជាភាសាពាក្យបច្ចេកទេសខ្លះៗ ក្នុងបច្ចេកវិជ្ជានៃចម្រៀង ។ល។ ជាពិសេស ភាសានយោបាយ ។ ការរើសយកវប្បធម៌របស់គេមកប្រើប្រាស់យ៉ាងនេះ ច្រើនតែចាប់ផ្ដើមឡើងពីអស់លោកអ្នកធំ អស់លោកអ្នកមានកិត្តិយសក្នុងសង្គម អស់លោកមានលុយ អស់លោកអន្តោប្រវេសន៍ត្រឡប់ចូលស្រុកវិញ ។ វាមិនអាក្រក់អីទេការរើសយកនូវវប្បធម៌របស់គេមកប្រើប្រាស់សំរាប់ការខ្វះខាតរបស់យើង តែអស់លោកអ្នកចេះដឹងជ្រៅជ្រះគួរជួយបង្ហាញប្រាប់ផង ប្រសិនបើរើសយកនូវអ្វីដែលអន់ជាងរបស់យើងមានហើយមកប្រើប្រាស់ជាជំនួយ ហើយធ្វើឱ្យរបស់ដ៏មានតំលៃរបស់យើងបាត់បង់អស់ទៅវិញ ។ គួរបង្ហាញឧទាហរណ៍ខ្លះដើម្បីងាយយល់ : តាំងនាមនៃប្រជាពលរដ្ឋខ្មែរ ឬក្នុងនាមនៃប្រជាពលរដ្ឋខ្មែរ បែរជាប្រើពាក្យៈ ជំនួសឱ្យប្រជាពលរដ្ឋខ្មែរ ឬជួសឱ្យប្រជាពលរដ្ឋខ្មែរទៅវិញ ។ ពាក្យដែលយើងយកមកប្រើជំនួសនេះ ពិបាកស្ដាប់សូសៀងក៏ឮធ្ងន់អណ្ដូកៗ ថែមទាំងទៅប្រែពីស័ព្ទអ្នកជិតខាងទៀតផង ។ គួរឱ្យស្ដាយមែនទែន ដូចជាខំទូលអង្ករទៅដូរយកអង្កាមមកវិញ ។ តែនៅមានរបៀបរើសយកនូវវប្បធម៌ដែលយើងមិនច្បាស់នូវប្រភពឬសគល់របស់វាមកប្រើ អាចនាំមកនូវលទ្ធផលអាក្រក់ឱ្យខ្លួនយើង ឬប្រទេសជាតិឯងទៅវិញទេ ។ ក្នុងចំណោមនោះ មានវប្បធម៌តាំងកង់រទេះគោនៅមុខភូមិគ្រឹះនេះជាដើម ។

ខ្ញុំសុំមិនមានយោបល់ចំពោះកង់រទេះគោចាស់ៗកំបាក់កំបែក ដែលបងប្អូនអ្នកស្រុកស្រែចំការយើងបោះបង់ចោលនៅក្បែររបងនោះទេ។ កង់រទេះគោអស់ទាំងនោះ មិនមែនតាំងលំអអីទេ តែគាត់ទុកបម្រុងជួសជុល ឬបម្រុងទុកសម្រាប់ជាចំណីភ្លើងក្នុងខែពិបាករកអុស ភ្លើងសម្រាប់ចំអិនចំណីអាហារតែប៉ណ្ណោះ មិនមែនតាំងយកល្អមើលអីនោះទេ! ។ ចំណែកអស់លោកមានភូមិគ្រឹះស្កុកស្កម្ភវិញ ការតាំងកង់រទេះគោនៅមុខភូមិគ្រឹះរបស់អស់លោកនោះមានន័យយ៉ាងណាដែរ? ចំលើយមិនដូចគ្នាសោះ ខ្លះទៀតនិយាយតាមយោបល់របស់អ្នកស្រឡាញ់វត្ថុបុរាណ ចូលចិត្តរក្សាទុករបស់ចាស់ៗសំណល់បាក់បែកនៃសំណង់ចាស់ ៗ ដូចសរសរមួយកំណាត់ គ្រោងទ្វារ ឬបង្អួច ឬភាគតូចណាមួយនៃសំណង់បុរាណដែលគេមានសំណាងបានជួបប្រទះ គេរើសយកមកជូតលាងដុសខាត់យ៉ាងស្អាត ហើយដាក់តាំងលំអនៅក្នុងគេហដ្ឋានរបស់គេ ដោយមានកត់ត្រាថ្ងៃខែ ដែលគេរើសបាន ឬបានពីណាមក អ្នកណាឱ្យ ឬក៏ទិញពីណាមកដោយតម្លៃប៉ុន្មាន ។ល។ តែប្រសិនបើរបស់នោះធំចង្រ្កាង មិនអាចតាំងក្នុងគេហដ្ឋានបានទេ គេតាំងនៅក្បែរផ្ទះ ឬក៏សង់រោងទុកការពារភ្លៀងខ្យល់អាកាសធាតុជាដើម ដើម្បីរក្សារបស់នោះទុកឱ្យបានយូរ ។ មានមនុស្សមួយចំនួនពុំបានយល់ពីអត្ថន័យ ពុំមានការចូលចិត្តរបស់បុរាណអ្វីនោះប៉ុន្មានទេ តែឃើញអ្នកតាំងវត្ថុទាំងនោះ ច្រើនតែជាមនុស្សកាលីពខ្ពស់ អ្នកមានមុខមានមាត់ មានលុយចាយមិនអស់ជាដើម ហេតុនេះហើយគាត់ក៏ចង់ឱ្យខ្លួនគាត់តម្រង់ចូលក្នុងជួរនៃពួកអភិជននេះដែរ ក៏ចំណាយប្រាក់កាសមួយចំនួន ដើររកទិញរបស់កញ្ចាស់កញ្ចាស់តាំងនឹងគេលេងទៅ ! ឧទាហរណ៍ ដូចនៅអឺរ៉ុប មនុស្សមួយចំនួនគ្មានយល់ពីស្នាដៃរបស់ ប៊ីកាស់សូ ទាល់តែសោះ តែហ៊ានចំណាយប្រាក់ទិញលានៗ ដើម្បីទិញរូបគំនូររបស់ ប៊ី-កាស់សូ ក្នុងឱកាសដេញថ្លៃម្ដងៗ ព្រោះតែមុខមាត់តែប៉ណ្ណោះ មិនមែនដោយកោតសរសើរស្នាដៃរបស់ ប៊ីកាស់សូ នោះឡើយ ។

ខ្ញុំអ្នកសរសេរអត្ថបទនេះ គ្មានបំណងចង់ទិទៀនរិះគន់បងប្អូនយើងជាអ្នកចូលចិត្ត ឬមិនចូលចិត្តរបស់ដែលគាត់យកមកតាំងលំអគេហដ្ឋានរបស់គាត់នោះទេ តែចង់សុំឱ្យគាត់បានយល់ច្បាស់សិននូវរបស់ដែលគាត់បានយកមកតាំងនោះមានន័យយ៉ាងណា ឬតំណាងឱ្យអ្វី ដើម្បីកុំឱ្យមានទោសមកលើខ្លួន ឬធំជាងនេះទៅទៀត គឺនាំក្ដីអាម៉ាស់មកលើជាតិខ្លួន ដោយពុំបានដឹងខ្លួនទាល់តែសោះ ។ ហ្នឹងហើយជាបញ្ហាវប្ប-ធម៌កង់រទេះគោនោះឯង ! វាមិនមែនតំណាងឱ្យកងចក្រ កង់ធម្ម ឬកង់វាលវដ្តសង្សារអ្វីនោះទេ រិតតែមិនមែនជារបស់តំណាងឱ្យវត្ថុបុរាណអីនោះទេ ពីព្រោះយើងសង្កេតឃើញថា មានអស់លោកខ្លះ ជួលគេឱ្យក្រឡឹងកង់រទេះគោថ្មីៗ ហើយដុសខាត់ពណ៌យ៉ាងស្អាតទៀតផង ។

ចុះកង់រទេះគោនោះ តំណាងឱ្យអ្វីទេ ?យើងត្រូវស្វែងយល់មើលថា គេចាប់ផ្ដើមតាំងកង់រទេះគោនេះ ចាប់ពីណាមកនៅស្រុកខ្មែរយើង ? គឺចាប់ពីពេលដែល អ៊ុនតាក់ ចូលមករៀបចំស្រុកខ្មែរ តែការិយាល័យទាំងឡាយរបស់ អ៊ុន-តាក់ គ្មានតាំងកង់រទេះគោទេ គេឃើញកង់រទេះគោនេះ បានតាំងនៅមុខអាហារដ្ឋានទាំងឡាយរបស់ជនជាតិថៃ ដែលហូរចូលមកតាំងទីរកស៊ីនៅភ្នំពេញ និងទីក្រុងនានា តាមចំហាយរបស់ អ៊ុនតាក់ ។ តាំងពីពេលនោះមក វប្បធម៌កង់រទេះគោ បានផ្សាយពីអាហារដ្ឋានថៃ ហូរចេញតាមច្រកនានា ទៅសំចតនៅមុខភូមិគ្រឹះទាំងឡាយរបស់អស់លោកអ្នកឧកញ៉ា អភិជនខ្មែរទេវិញ ។ ហើយបើយើងដើរត្រេតត្រតកំសាន្តតាមដងវិថីនានា នៃទីក្រុងបាងកក យើងឃើញគេតាំងកង់រទេះគោតាមភូមិគ្រឹះនានា ក្បែររូបចំលាក់ព្រះនរាយ ឬព្រះឥសូ ឬក្បែររូបចំលាក់ផ្សេងៗក្នុងសាសនាព្រហ្មញ ។ ដូច្នេះថៃគេមានវប្បធម៌តាំងកង់រទេះគោនេះ តាំងពីយូរមកហើយ គេមានឱកាសយកមកតាំងបង្ហាញខ្មែរយើងនៅពេល អ៊ុនតាក់ ចូលស្រុកខ្មែរ នាឆ្នាំ១៩៩៣ នេះឯង ។

ចុះវប្បធម៌កង់រទេះគោមានន័យយ៉ាងណាទើបថៃគេស៊ូទ្រាំដឹកនាំមកតាំងនៅស្រុកយើង ? ចុះខ្មែរយើងវិញ ហេតុអ្វីបានជាមិនគួរតាំងលំអ ឬលើកដំកើងនូវវប្បធម៌កង់រទេះគោនេះ ? អស់លោកនឹងបានជ្រាបនៅលេខក្រោយ សូមរង់ចាំអានបន្តទៀត ! ។

**Washington Wellness Care** **មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"**

Medical & Rehab.

ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

**Medical & Rehab.**
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

**Dr. Scott C. Tran, D.C. Dr. Michael Barno, D.C. Dr. Zohar Stark, M.D.**

***We are specialized in treating:***

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

**យើងមានជំនាញក្នុងការព្យាបាល :**

☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

**យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ**
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ **រីគី សុន (215) 380-1350**
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ **(215) 551-6838**

# ឥទ្ធិពលអន្តរជាតិនាំឱ្យខ្មែរឈ្នះប្រៀប សៀមជាជាងប្រើកម្លាំងអាវុធ

**+សៀមចង់ប្រើកម្លាំងយោធាប្រយុទ្ធ :**

**California, ខ្មែរប៉ុស្តិ៍ : មាជ សុវណ្ណារ៉ា**





គ្រឿងក្ដោះពាសដែកខ្មែរ ត្រៀមប្រយុទ្ធនៅលើរទេះគង់



•••អ្នកច្បាប់អន្តរជាតិមួយចំនួនតាមកិច្ចសំភាសន៍របស់ខ្មែរប៉ុស្តិ៍សុទ្ធតែអះអាងថា បញ្ហាជម្លោះព្រំដែនរវាងខ្មែរ និងសៀម វាអាចរកដំណោះស្រាយទៅបានដោយសន្តិវិធីនៃផ្លូវនយោបាយការទូតនូវឥទ្ធិពល3យ៉ាង គឺច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ,សាលក្រមតុលាការក្រុងឡាអេ ប្រទេសហូឡង់ ដែលប្រទេសទាំងពីរយល់ព្រមតាមការសំរេច នាថ្ងៃទី15 ខែមិថុនា ឆ្នាំ១៩៦២ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ ។ ឥទ្ធិពលទាំង3យ៉ាងនេះ គឺរកដំណោះស្រាយតាមផ្លូវច្បាប់ដែលប្រទេសសៀមមិនអាចប្រកែកបាន ប្រសិនបើរដ្ឋាភិបាលកម្ពុជាមានសុឆន្ទៈក្នុងការដោះស្រាយ ។

ក្រុមអ្នកច្បាប់ទាំងនោះនិយាយបន្តថា ភាគីកម្ពុជាក៏ដូចភាគីសៀម មិនត្រូវនិយាយពីការប្រើកម្លាំងយោធាដើម្បីប្រឈមមុខក្នុងការប្រយុទ្ធគ្នានោះទេ ដោយចោទសំណួរថា បើភាគីទាំងពីរប្រើកម្លាំងយោធាប្រយុទ្ធគ្នា "តើកម្ពុជាអាចទប់ទល់ជាមួយសៀមបានទេ បើសង្រ្គាមព្រំដែនផ្ទុះឡើង ?"

លោកបណ្ឌិតច្បាប់ ឡៅ ម៉ុងហៃ បានប្រាប់ខ្មែរប៉ុស្តិ៍ឱ្យដឹងថា បើយើងដោះស្រាយបញ្ហាបូរណភាពដែនដីជាមួយប្រទេសជិតខាងដោយសង្រ្គាមជាងការដោះស្រាយដោយនយោបាយការទូត ដែលពឹងផ្អែកលើផ្លូវច្បាប់អន្តរជាតិនោះ កម្ពុជាគួរត្រូវសម្លឹងមើលពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅតំបន់មជ្ឈឹមបូព៌ានៃជម្លោះកាន់កាប់ទឹកដីរវាងអ៊ីស្រាអែលជាមួយប៉ាឡេស្ទីន និងប្រទេសស៊ីរីយ៉ា ជាឧទាហរណ៍ដែលអ្នកណាមួយមានកម្លាំងយោធាខ្លាំង គឺត្រូវបានគេកាន់កាប់ជាកម្មសិទ្ធិ ទោះបីមិនជាដែនដីរបស់គេក៏ដោយ ។





ក្រុមទាហានខ្មែរ និងរថពាសដែក, រថក្រោះ ត្រៀមប្រយុទ្ធ


# ឱសថស្ថាន ផ្លូវលេខ 8
## វេជ្ជបណ្ឌិត អាឡិច លឿង

## 8th Street Pharmacy
Alex. N. Luong, RPh.
OPEN HOURS:
Mon. – Fri.: 9:00AM – 7:00PM
Sat.: 9:00AM – 5:00PM
Sun.: 9:00AM – 3:00PM

បើចង់បានសេវាថ្នាំពេទ្យឆាប់ សូមអញ្ជើញមករកអ្នកភូមិរបស់អ្នក គឺ ឱសថស្ថាន ផ្លូវលេខ ៨ ( ជ្រុងផ្លូវលេខ៨ និង CHRISTIAN ហ្វីឡា-ខាងត្បូង)

☛ យើងទទួលប័ណ្ណមេឌីឃែរ នឹងមេឌីខេត

▸ **We Do accept Medicare & Medicaid**

▸ **We Do Offer Alternative Natural Medicines Including:**

☛ យើងមានផ្តល់ជូននូវឱសថធម្មជាតិ មានដូចជា :



▸ Prostate -7 – ជួយដល់សុខភាព "ប្រស្តេដ" ដលបុរស
▸ Pure Fresh Royal Jelly – ជួយលើកដំកើងនូវរសជាតិនៃជីវិត
▸ Fe-mon-9 – ជួយដល់ស្ត្រីនៅពេលមានអ័រម៉ូន
▸ Super Cross – ជួយបន្ថយការគាំងបេះដូង,ការលើសឈាម ឬកូឡេស្តេរ៉ូលច្រើន
▸ Gold Medal Swiss Placenta "សុកពពែស្វីស" មេដាយមាស សំរាប់កែសម្ផស្ស

819 S. 8th St.
Philadelphia, Pa 19147
Phone: 215-592-8888
Fax: 215-592-9888


បណ្ឌិត ឡៅ ម៉ុងហៃ បានបញ្ជាក់ថា ការចរចាក្នុងកិច្ចការព្រមព្រៀងណាមួយដែលយើងយកច្បាប់អន្តរជាតិជាគោល ពិសេសច្បាប់អង្គការសហប្រជាជាតិកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃ២៣ តុលា ឆ្នាំ១៩៩១ ដែលសៀមជាប្រទេសចុះហត្ថលេខីដឹងឮ និងយល់ព្រមគោរពតាមកិច្ចព្រមព្រៀងនោះដែរ ។

នៅក្នុងកិច្ចព្រមព្រៀងទី២ ស្តីអំពីកិច្ចព្រមព្រៀងទាក់ទិនទៅនឹងអធិបតេយ្យភាព, បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដីអព្យាក្រិតភាព និងឯកភាពជាតិកម្ពុជានោះ បណ្ឌិត ឡៅ ម៉ុងហៃ បានអះអាងថា សៀមកំពុងតែរំលោភនូវកិច្ចព្រមព្រៀងនេះ ទាំងស្រុងហើយ ព្រោះសៀមរំលោភចូលមកកាន់កាប់ទឹកដីខ្មែរ ។ ដូច្នេះភាគីនានាតាមរយៈកិច្ចព្រមព្រៀងសន្យា និងទទួលខុសត្រូវ ដោយគោរពគ្រប់បែបយ៉ាងទាំងអស់ក្នុងយន្តការដោះស្រាយតាមមាត្រាទី៥ នៃកិច្ចព្រមព្រៀងទី២ ដែលចែងក្នុងករណីមានការរំលោភ ឬការគំរាមកំហែងរំលោភមកលើអធិបតេយ្យភាព, ឯករាជ្យភាព និងបូរណភាព និងភាពមិនអាចរំលោភបាននៃដែនដីអព្យាក្រិត និងឯកភាពជាតិកម្ពុជាទៅលើការប្តេជ្ញា,អនុវត្តន៍នៃការវិវាទនៃកិច្ចព្រមព្រៀងបណ្តាភាគីត្រូវធ្វើការពិគ្រោះគ្នាជាបន្ទាន់ ដើម្បីអនុម័តនូវរាល់វិធានការណ៍សមស្របក្នុងការធានាការសម្រេចដល់ការដោះស្រាយដោយសន្តិវិធី រហូតដល់មានសេចក្តីរាយការណ៍ទៅដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្នុងការប្រើប្រាស់គ្រប់មធ្យោបាយដែលអនុលោមតាមមាត្រា43របស់អង្គការសហប្រជាជាតិទៀតផង និងរួមទាំងការស្នើសុំឱ្យមានការកោះប្រជុំសើរើពីការរកដំណោះស្រាយបញ្ហា ដោយសហប្រធាននៃកិច្ចព្រមព្រៀង ដែលមានប្រទេសបារាំង និងឥណ្ឌូនេស៊ីជាសហប្រធាននោះ ។

+ប្រទេសសៀម និងកម្ពុជា បានប្រឈមមុខដាក់គ្នាដោយចុងអាវុធតាមបណ្តោយព្រំដែន រហូតដល់មានបន្ទុះអាវុធចំនួនពីរលើក កាលពីដើមខែ និងពាក់កណ្តាលនៃខែតុលាបណ្តាលឱ្យភាគីខ្មែរ៣នាក់ស្លាប់ និងរបួស៣នាក់ ចំណែកភាគីសៀមតាមការអះអាងថា រហូតមកដល់ពេលនេះបានស្លាប់ចំនួន៧នាក់ របួស៧៤នាក់ ។ ការបង្កជម្លោះនេះកើតឡើង បន្ទាប់ពីកម្ពុជាត្រូវបានយល់ព្រមពីអង្គការ UNESCO ដាក់បញ្ចូលប្រាសាទព្រះវិហារទៅជាបេតិកភណ្ឌពិភពលោកនាថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ ដែលក្រោយមកនៅថ្ងៃទី១៥ កក្កដា សៀមបានបញ្ជូនកងទ័ពចូលមករំលោភបំពានទឹកដីខ្មែរនៅតំបន់ប្រាសាទព្រះវិហារ និងតំបន់ផ្សេង១ទៀត រហូតដល់ថ្ងៃនេះ ដែលតំណតរៀងមកជាង3ខែ ភាគីទាំងពីរបានបើកយុទ្ធនាការណ៍ចរចាជាទ្វេភាគី ប៉ុន្តែការចរចានៃរដ្ឋាភិបាលទាំងពីរមិនមានប្រសិទ្ធិភាពឈានទៅរកការត្រូវរ៉ូវគ្នានៅឡើយទេដែរ ។

បើទោះបីជាការចរចាទ្វេភាគីពុំទាន់ឃើញចេញលទ្ធផលជាវិជ្ជមានក៏ដោយ គេសង្កេតឃើញថា តាមការអះអាងរបស់អ្នកដឹកនាំខ្មែរនៅតែបន្តការអត់ធ្មត់ដើម្បីព្យាយាមទៅរកការចរចាជាបន្តបន្ទាប់ទៀត ដោយលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បានបញ្ជាក់ជំហរថា កម្ពុជាមិនទាន់ត្រូវការពឹងពាក់អន្តរជាតិនៅឡើយទេ ជុំវិញជម្លោះព្រំដែនជាមួយសៀម Sic ។

+ប្រធានគណៈកម្មាធិការប្រព្រឹត្តិកម្មខ្មែរដើម្បីយុត្តិធម៌ និងសមធម៌ លោក សួន សេរីរដ្ឋា បានប្រាប់ខ្មែរប៉ុស្តិ៍ថា រដ្ឋាភិបាលលោក ហ៊ុន សែន កំពុងតែយកបញ្ហាជាតិមកលេង សើចយើងយល់ថា វាមិនគប្បីធ្វើឡើយ ព្រោះជោគវាសនារបស់ប្រទេសជាតិ ទឹកដី ពលរដ្ឋ វប្បធម៌ សង្គម និងសម្បត្តិធម្មជាតិរបស់កម្ពុជាទាំងអស់ មិនមែនជាកម្មសិទ្ធិផ្តាច់មុខរបស់លោក ហ៊ុន សែន ឬរបស់បក្សពួកក្រុមគ្រួសារ

(តទៅទំព័រទី២០)

# ហ៊ុន សែន_ស៊ុមឆាយ ឯកភាពគ្នាមិន ផ្ទុះអាវុធ

**ភ្នំពេញ , ខ្មែរប៉ុស្តិ៍ , ចាន់ កុសល**

••• ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងលោក ស៊ុមឆាយ វង់សាវ៉ាត នាយករដ្ឋមន្ត្រីសៀម បានជួបទល់មុខគ្នាជាលើកដំបូងនៅទីក្រុងប៉េកាំង ប្រទេសចិន កាលពីថ្ងៃ


លោក ស៊ុមឆាយ វង់សាវ៉ាត នាយករដ្ឋមន្ត្រីសៀម


ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា


កិច្ចពិភាក្សាគ្នាមួយរវាងខ្មែរ_សៀម

ទី24 ខែតុលា នៅខាងក្រៅកិច្ចប្រជុំកំពូលអាស៊ុ-អឺរ៉ុប ទាំងពីរនាក់ បានឯកភាពគ្នាទប់ស្កាត់មិនឱ្យមានជម្លោះអាវុធ នៅតាមបណ្តោយព្រំដែនទៀតទេ ។

ចំណែកឯលោក សំពុង អាមនវីវ៉ាត រដ្ឋមន្ត្រីការបរទេសសៀមវិញ ក៏បានប្រាប់អ្នកកាសែតនៅទីក្រុងប៉េកាំងថា "ភាគីទាំងពីរត្រូវប្រាប់ទៅកងទ័ពរបស់ខ្លួនថា កុំឱ្យប្រឈមមុខដាក់គ្នាបន្តទៀត" ។

លោក ហោ ណាំហុង ត្រូវទីភ្នាក់ងារសារ-ព័ត៌មានបរទេសដកស្រង់សម្តីដែលនិយាយថា "យើងកំពុងធ្វើដំណើរឆ្ពោះទៅមុខនៅលើផ្លូវដ៏ល្អមួយ ។ វាមិនត្រឹមតែដោះស្រាយបញ្ហាព្រំ-ដែនរវាងប្រទេសរបស់យើងទេ ប៉ុន្តែ វាថែមទាំងស្ថិតនៅលើផ្លូវដ៏ប្រពៃមួយ ដើម្បីធ្វើឱ្យសហ-ប្រតិបត្តិការ និងភាពជាអ្នកជិតខាងរបស់យើងកាន់តែល្អប្រសើរទៀតផង" ។

នៅឯប្រទេសកម្ពុជាឯណោះវិញ ការចរចារវាងគណៈកម្មាធិការព្រំដែនយោធាភូមិភាគកម្ពុជា-សៀមលើកទី11 នៅខេត្តសៀមរាប ត្រូវបានចាត់ទុកថា ទទួលលទ្ធផលល្អ ដោយភាគទាំងពីរឯកភាពគ្នាធ្វើការអត់ធ្មត់បំផុត នៅក្នុងការទប់ស្កាត់មិនឱ្យមានការផ្ទុះអាវុធ ។

លោកឧត្តមសេនីយ៍ទោ ជា ម៉ន មេបញ្ជាការយោធភូមិភាគទី4 កម្ពុជា បាននិយាយប្រាប់អ្នកកាសែតថា ចំពោះដំណោះស្រាយបញ្ហាតំបន់ប្រាសាទព្រះវិហារ ភាគីទាំងពីរបានឯកភាពគ្នាប្តេជ្ញាធ្វើការអត់ធ្មត់បំផុត ប្រឈមមុខដាក់គ្នាឬក៏ការប៉ះទង្គិចគ្នាដោយយោធា និងបន្តការពិភាក្សារកដំណោះស្រាយបញ្ហានេះប្រកបដោយសន្តិវិធី ។

លោកក៏បាននិយាយដែរថា ភាគីទាំងពីរមានទស្សនៈឯកភាពគ្នាថា កិច្ចសហប្រតិបត្តិការត្រូវធ្វើឡើងដោយស្មើភាពគ្នា គោរពអធិបតេយ្យ-ភាព និងបូរណភាពដែនដីរវាងគ្នានឹងគ្នា ដូចជាការទំនាក់ទំនងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ការថែរក្សាការពារបរិស្ថានតំបន់ព្រំដែន ការចាត់វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗ រួមទាំងការធ្វើសេដ្ឋកិច្ចនៅតាមតំបន់ព្រំដែនរវាងប្រជាជន នៃប្រទេសទាំងពីររស់នៅមានជីវភាពបានសមរម្យ ។

ចំណែកលោកឧត្តមសេនីយ៍សៀម វិប៊ុន សាក់នីផាន់ មេបញ្ជាការយោធភូមិភាគទី2 បាននិយាយស្រដៀងគ្នានេះ ចំពោះលទ្ធផលកិច្ចប្រជុំរយៈពេលពីរថ្ងៃនៅខេត្តសៀមរាប ដែលធ្វើឡើងក្រោមការយាមកាមសន្តិសុខ យ៉ាងតឹងរ៉ឹងដោយមានការដាក់ពង្រាយកម្លាំង ប៉ូលិស និងប៉េអឹមជាច្រើននាក់ ។ លោកបាននិយាយថា កិច្ចប្រជុំបានសម្រេចតាមគោលដៅដែលយើងបាន ។ កិច្ចប្រជុំបានទទួលផលជា ដុំកំភួននៅក្នុងការដោះស្រាយបញ្ហារួមគ្នាដោយសន្តិវិធី ។

នៅក្នុងសេចក្តីប្រកាសព័ត៌មានដោយឡែកមួយនោះ ប្រតិភូសៀមបានស្នើឱ្យប្រទេសកម្ពុជាមានការយោគយល់ចំពោះតម្រូវការ និងនីតិវិធីដែលតម្រូវដោយរដ្ឋធម្មនុញ្ញសៀម ឆ្នាំ2007 ដាក់ជូនរដ្ឋ សភានូវក្របខ័ណ្ឌចរចាសម្រាប់ការរៀបចំជាបណ្តោះអាសន្នទាក់ទងទៅនឹងបញ្ហាប្រាសាទព្រះវិហារ និងក្របខ័ណ្ឌចរចាសម្រាប់ការវាស់វែង និងបោះបង្គោលព្រំដែននៅក្នុងក្របខ័ណ្ឌ នៃគណៈកម្មការព្រំដែនរួមកម្ពុជា-សៀម ស្តីពីការបោះបង្គោលព្រំដែនសម្រាប់ព្រំដែនដីគោក ទៅឱ្យរដ្ឋសភា ដើម្បីធ្វើការ

(តទៅទំព័រទី១៨)

# រំលឹកថ្ងៃទី៩ វិច្ឆិកា ១៩៥៣

**ដោយ : ម៉ម យិន**

ប្រាំបួន វិច្ឆិកា ហាសិបបី
រួចពីទុក្ខទោសបានអំណាច
៩ វិច្ឆិកា ឆ្នាំ៥៣
សប្បាយរីករាយយ៉ាងអស្ចារ្យ
ប្រាំបួន វិច្ឆិកា ហាសិបបី
ជាតិខ្មែរអ្នកជាផុតទុក្ខព្រួយ
៩ វិច្ឆិកា ឆ្នាំ៥៣
ខិតខំប្រឹងប្រែងដោយឱហាត
ប្រាំបួន វិច្ឆិកា ហាសិបបី
រួមគ្នាធ្វើបុណ្យថ្ងៃល្អផ្តាច់
៩ វិច្ឆិកា ឆ្នាំ៥៣
សូមឯករាជ្យខ្មែរមានវាសនា
ប្រាំបួន វិច្ឆិកា ហាសិបបី
មិនគួរឯករាជ្យមិនគង់នៅ
ឱ ឯករាជ្យអើយជាតិខ្មែរស្តាយ
ថាជាតិខ្មែរបាត់អត្តសញ្ញាណ
ឯករាជ្យជាតិខ្មែរសព្វថ្ងៃនេះ
ឯករាជ្យក្លែងក្លាយទេខ្មែរអើយ
៩ វិច្ឆិកា សូន្យប្រាំបី
ជាថ្ងៃជាតិខ្មែរបានតាំងចិត្ត
ប្រាំបួន វិច្ឆិកា សូន្យប្រាំបី
តម្កើងជាតិពិតនាំគ្នាជួយ

ជាតិខ្មែរជោគជ័យបានឯករាជ្យ
សិទ្ធិអង់អាចខ្មែរអ្នកជា ។
ជាតិខ្មែរប្រុសស្រីគ្រប់រូបា
រួបរួមសាមគ្គីខ្មែរតែមួយ ។
ជាតិខ្មែរអរក្រៃខំលើកស្ទួយ
តាំងចិត្តរួមជួយពង្រឹងជាតិ ។
ជាតិខ្មែរប្រពៃចិត្តល្អស្អាត
តាំងចិត្តសង្វាតទ្រឯករាជ្យ ។
ជាតិខ្មែររួមដៃចិត្តអង់អាច
ជាថ្ងៃសម្រេចជោគជ័យា ។
ជាតិខ្មែរលើកដៃតាំងសច្ចា
គង់វង្សគ្រប់គ្រាតរៀងទៅ ។
ជាតិខ្មែរសព្វថ្ងៃស្តាយពេកក្រៃ
ដោយសារសត្រូវចូលឈ្លានពាន ។
ស្រណោះពេកក្រៃមិនទីកស្ថាន
ជាខ្មែរគ្រប់ប្រាណដូច្នេះឡើយ ។
បានស្លាប់របេះបាត់ទៅហើយ
ខ្មែរទុកឥតស្បើយមួយជីវិត ។
ជាតិខ្មែរស្តាយក្រៃថ្ងៃពិសិដ្ឋ
រួមសាមគ្គីពិតខ្មែរតែមួយ ។
ជាថ្ងៃខ្មែរថ្មីខំលើកស្ទួយ
ជាតិខ្មែរផុតព្រួយបានសុខសាន្តអើយ ៕

សូមអរគុណ !


## មជ្ឈមណ្ឌលសំរាប់ព្រឹទ្ធជន គ្រប់សញ្ជាតិ




សូមអញ្ជើញលោកអ្នកមកចូលរួមពិធីជប់លៀងអាហារថ្ងៃត្រង់នាឱកាសបុណ្យ "ថេងគ្គីវីង" Thanksgiving ថ្ងៃ ពុធ ទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ម៉ោង ១០ ដល់ ២:៣០ រសៀល នៅ 4837 N. MALVING St .
Philadelphia . PA 19141
ទូរស័ព្ទ : (215) 324-7554

**យើងសូមស្វាគមន៍ដល់លោកអ្នកទាំងអស់គ្នា**

មជ្ឈមណ្ឌលយើងជាកន្លែងសំរាប់បំរើព្រឹទ្ធជនគ្រប់សញ្ជាតិ ដែលមានវ័យពី ៦០ ឆ្នាំ ឡើងទៅ ។

មណ្ឌលយើងមាននិយាយភាសាអង់គ្លេស-ខ្មែរ ចិន វៀតណាម និង កូរ៉េ ហើយយើងបំរើសេវាដល់ព្រឹទ្ធជន ដូចជា :

ថ្នាក់បង្ហាត់បង្រៀនភាសាអង់គ្លេស ដំណើរកំសាន្ត ការហាត់ប្រាណ ថ្នាក់បង្រៀនពីសិល្បៈ ជូនព័ត៌មានខាងច្បាប់ មានល្បែងលេង ដូចជា : ម្សូត អុក និងសេវាឯទៀតជាច្រើន ។

មជ្ឈមណ្ឌលបើកពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង៩ព្រឹក ដល់ ១ រសៀល
យើងមានទទួលអាហារពេលព្រឹក និងថ្ងៃត្រង់ ដល់គ្រប់គ្នាជាប្រចាំ
ហើយ សេវាយើងទាំងអស់សុទ្ធតែមិនយកកម្រៃ ។

# ONE MAN TEMPLE & ONE MAN CHURCH

## វត្តម្នាក់ឯង ជួបនឹង ឆឺចម្នាក់ឯង




**ដោយៈ ណុប ច័ន្ទតារា**

Long Beach, California

វត្តអញម្នាក់ឯងស្រេចតែចិត្តអញ
អ្នកស្រុកលោកតាហើយនិងលោកយាយ
ស៊ីផាន់បង្វែរបង្វិលលុយវត្ត
គេថាមានឆឺចពួកគ្នាគេស្រាប់
មុខតុលាការ John Ramirez
គ្មានសមាជិកពុំមានអ្នកស្រុក
ត្រូវហើយចំប៉ះវត្តមួយឆឺចមួយ
ចៅក្រមដឹងរឿងបែបលេងកំប្លែង
ជើងចាស់ត្រូវប៉ះជាមួយជើងយូរ
ល្មើសនឹងចៅក្រមចង់យកតែឈ្នះ
ស៊ីផាន់គាត់ភ្លេចអាមេរិកមានច្បាប់
ប្ដឹងគេប្ដឹងឯងពួកអ្នកធ្វើការ
ចៅក្រមបញ្ជាឱ្យក្រុម Marshal
ដោះអាវខ្វាហ៊ៀវដោះទាំងក្រវ៉ាត់
ហើយមានម្នាក់ទៀតឆ្មៀតរត់ទៅពួន
ចូលក្នុងបង្គន់រត់ពួនទាំងថ្ងៃ
ទឹកភ្នែកហូរច្រោកសោកស្ដាយតិចអី
មិត្តអើយចូរចាំកុំឆក់កុំលួច
កុំរៀនបោកព្រះបោកយាយបោកតា
កុំបោកព្រះសង្ឃថាខ្លួនចំណាប់
ឃើញទេស៊ីផាន់ឥឡូវជាប់ឃុំ
បែកកូនប្រពន្ធគ្រួសារឆោឡោ
ធ្លាប់បានស៊ីឆ្ងាញ់ចង់ដឹងធ្វើអី
ព្រះសង្ឃឡើងភ័យស៊ីផាន់កាន់កាប់ ។
រៀបចំពង្រត់បង្វិចឱ្យឆាប់
អ្នកអើយគួរស្ដាប់ឆឺច P.O. Box ។
គេថាឆឺចគេគ្មានកៅអីតុ
ធ្វើការស្រណុកគ្នាតែម្នាក់ឯង ។
បងប្អូនកុំព្រួយវាស្រួលចាត់ចែង
Ramirez ឯងធ្លាប់ដើរបោកប្រាស់ ។
មិនបាច់គិតគូរចូរចាំឱ្យច្បាស់
អត់ស្នាមក្រដាសតាមបង្គាប់ការ ។
ដើរតួចំណាប់ទៅស្រែកឡូឡា
អ្នកស៊ើបប្រាប់ថាជារឿងមិនពិត ។
បន្ទប់កណ្ដាលឱ្យនាំលោកទិត
ដោយប្រុងប្រយ័ត្នរួចដាក់ខ្នោះដៃ ។
ព្រោះគេដឹងខ្លួនបះសក់ផ្អើលថៃ
ប៉ុន្តែមានអីនឹងអាចគេចរួច ។
គុកគ្មានសេរីគ្មានទាំងបង្ហួច
តាំងចិត្តសម្រួចដើរដោយផ្លូវច្បាប់ ។
យកខែលសាសនាខ្ញុំបាទសូមប្រាប់
អ្នកគួរតែគ្រាប់សម្មាជីវោ ។
លែងបានជួបជុំស៊ីទំអាគោរ
គេទះដៃហ៊ោផ្អើលក្រុងឡុងប៊ិច ៕

## មេស្វាររក្សាកូន



**បទពាក្យ ៨ ជាប់ទង**
**ដោយ : គឹម ថាវរូ**
**កាលីហ្វ័រនី, ថ្ងៃអាទិត្យ ទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៧**

- មេស្វាពិត ចិត្តចង ប៉ងថែកូន
  ផ្អោបកូនជាប់ ភ្ជាប់ទ្រូងៗអាត្មា
- ចិត្តជាមេ មេត្តា ការកូនស្ងួន
  កូនផ្អោបជាប់ គាប់ជិត មិត្រិបាញ់
- ទោះឆ្ងាយជិត គិតជាប់ រាប់ចិត្តនឹក
  ទ្រូងកូនឱប ក្ដោមតោង យោងរត់បោល
- ដល់មាត់ទឹក នឹកគិត ពិតចង់ឆ្លង
  កូននៅទ្រូង ប្រួងដល់ ជលយាត្រា
- មើលមេជម្ម[១] ត្រាំចិត្ត គិតមិនដល់
  នៅមិនយល់ ដល់ហេតុ ភេទនោះទេ
- ស្រឡាញ់ពិត ល្ងិតល្ងង់ លង់មិនខាន
  ចេះស្រឡាញ់ ក្រាញ់គិត ពិតមិនស្លាប់

ទៅមកជូន លូនលោត សោតទីលា
ខំរក្សា ការពារ ភ្ជាសំឡាញ់ ។
ទោះជាខ្លួន ជួនតួប ជួបមារផ្ចាញ់
មិនរាចាញ់ ញ៉ាញសោះ បោះកូនចោល ។
កូនពន្លឹក ព្រឹកល្ងាច គៀចមិនចោល
ជាជន្ទោល យោលតាម ដាមវាសនា ។
ផ្អោបកូនផង ប៉ងហែល ខែលជលសា
ឈ្លក់កូនស្វា បាស្លាប់ ក្ដាប់តោងមេ ។
ឥឡូវផល ផ្ដល់ឱ្យ ក្រោយទុក្ខទ្វេ
ខ្លួនជាមេ ត្អេរថៃ បែរកូនស្លាប់ ។
សុខមិនបាន ក្សាន្តអត់ កត់ជាច្បាប់
សូមកុំគ្រាប់ ច្បាប់ស្វា ការពារកូន ។

[១].ជម្ម=មនុស្សស្លាប់គំនិត ធ្វើអ្វីមិនចេះប្រមាណ ។

**ទំព័រវិធីបំភ្លឺជីវិត**

# ជីវិតបានសុខ លុះត្រាតែយល់អ្វីហៅថាទុក្ខ

**ប្រែសម្រួល និងចងក្រងដោយ : អ៊ុំ ឈឿម**

□□□អ្វីដែលនាំឱ្យយើងមានក្ដីសុខ ឬទុក្ខនោះ គឺវាអាស្រ័យទៅលើការគិតគូររបស់ខ្លួនយើងផ្ទាល់ និងអាស្រ័យលើការបដិបត្តិចំពោះខ្លួនយើងតែប៉ណ្ណោះ ។ ចំពោះការគិតគូរនូវអ្វីម្យ៉ាង ដែលស្ថិតនៅក្នុងផ្លូវដ៏ត្រឹមត្រូវ ឬផ្លូវដ៏ល្អមួយនោះ វិថីជីវិតយើងក៏នឹងមានក្ដីសុខទៅតាមនោះដែរ ។

ប្រសិនបើយើងកំពុងប្រឈមមុខទល់នឹងវិបត្តិ ឬបញ្ហាអ្វីមួយ ចូរកុំគិតថា ក្ដីទុក្ខសោករបស់យើងមានទំហំធំជាងអ្នកដទៃឱ្យសោះ ត្រូវគិតថា អ្នកដទៃមានក្ដីទុក្ខសោកលើសយើងទ្វេរដងឯណោះ ។ បើយើងប្រៀបធៀបចំពោះក្ដីទុក្ខកង្វល់របស់យើងជាមួយអ្នកដែលមានក្ដីទុក្ខសោកធំជាងយើងនោះ ក៏ជាប្រយោជន៍ជួយជំរុញឱ្យយើងមានកម្លាំងចិត្តបានមួយចំណែកដែរ ។

អ្វីដែលបានពោលរៀបរាប់មកខាងលើនេះ បានសមស្របទៅនឹងទ្រឹស្ដីរបស់វាគ្មិនទស្សនៈវិទូមួយរូបបានពោលថា : " ខណៈពេលដែលអ្នកកំពុងស្រែកយំ ព្រោះពុំមានស្បែកជើងពាក់នោះ អ្នកត្រូវនឹកឃើញដល់មនុស្សពិការ ដែលគ្មាពុំមានទាំងជើងសម្រាប់ដើរនោះផង ។ ឬបើអ្នកខូចចិត្ត ព្រោះពុំមានជើងនោះ អ្នកត្រូវនឹងឃើញដល់មនុស្សជាច្រើននាក់ ដែលគ្នាពុំមានទាំងជើង ទាំងដៃផង " ។

អត្ថន័យខ្លឹមសារទាំងប៉ុន្មានខាងលើ ជាគំនិតជំនួសស្មារតីក្នុងការពង្រឹងឱ្យយើងមានកម្លាំងចិត្តកម្លាំងកាយជាថ្មី បន្ទាប់ពីបានជួបនូវវិបត្តិ ឬក្ដីទុក្ខណាមួយហើយនោះ ។

ជាការពិតណាស់ បើសិនជាយើងគិតតែពីអង្គុយបៀមទុក្ខសោក ព្រោះដោយសារហេតុផលណាមួយនោះ ទំហំនៃក្ដីទុក្ខសោកកាន់តែរីកសាយភាយទ្វេរដងថែមទៀត ។ ផ្ទុយទៅវិញ យើងគប្បីប្រើប្រាស់នូវសតិបញ្ញាក្នុងការកំចាត់ក្ដីទុក្ខសោកនោះ ឱ្យបានរហ័សបំផុត ។

- ការកើតទុក្ខជ្រុល អង្គតអង្គល មមុលមឹងម៉ាំង
  អ្នកមានប្រាជ្ញា គួរតែប្រឆាំង កុំឱ្យចិត្តតាំង
  ក្នុងក្ដីសោកសៅ ។
- ព្រះពុទ្ធប្រាប់ថា ត្រូវប្រើប្រាជ្ញា ដេញទុក្ខចេញក្រៅ
  ត្រូវកុំប្រមូល ទុក្ខឱ្យក្ដួចក្ដៅ ដេញយូរៗទៅ
  គង់ទុក្ខឃ្លាតប្រាណ ។
- ព្រោះតែក្ដីទុក្ខ តែងដេញក្ដីសុខ ឱ្យឃ្លាតចាកប្រាណ
  សុខនៅពុំកើត ត្បិតទុក្ខរុញច្រាន កំចាត់ឱ្យបាន
  ហៅថាមានសុខ ។

"ចូរកុំនិយាយប្រាប់ខ្ញុំថា បញ្ហានេះ វាលំបាក បើមិនលំបាក វាក៏មិន មែនក្លាយជាបញ្ហាដែរ " ៕






## សេចក្ដីជូនដំណឹង

ក្រុមជំនុំខ្មែរបាប់ទីស្ទ ទីក្រុងហ្វីឡាដែលហ្វីយ៉ា មានកិត្តិយសសូមអញ្ជើញលោក-លោកស្រី មកចូលរួមក្នុងពិធីបុណ្យអរគុណ *Thanksgiving* ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃអាទិត្យ ទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០៨ វេលាម៉ោង៣រសៀល នៅព្រះវិហារខ្មែរបាប់ទីស្ទ ដែលស្ថិតនៅកាច់ជ្រុងផ្លូវលេខ៣ និងផ្លូវស្នាយឌើ ។

ក្រោយកម្មវិធីថ្វាយបង្គំព្រះ នឹងមានការទទួលទានភោជនាហារ និងការប្រកបគ្នា ។

### Invitation

You are cordially invited to the Thanksgiving celebration which will be held at the Cambodian Baptist Church on Sunday, November 23 .2008 at 3p.m. Dinner will be served following Worship Services Cambodian Baptist Church
300 Snyder Avenue
Philadelphia, PA 19148
Tel: (215) 431-9375

*Happy Thanksgiving !*






# ប្រើចំហាយទឹកក្ដៅងមុខដោយខ្លួនឯង



សំរាប់សុភាពស្ត្រីដែលចង់ឱ្យមុខ.ស រលើប រលោងស្រស់ស្អាតនោះ មានច្រើននាក់ណាស់ ដែលនាំគ្នារត់ទៅពីហាងកែសម្ផស្ស ។ ក៏ប៉ុន្តែ ការពិតអ្នកមិនចាំបាច់ចំណាយពេលវេលាខាតបង់នៅឯហាងកែសម្ផស្សក៏បានដែរ ព្រោះអ្នកខ្លួនឯងក៏អាចប្រើប្រាស់វិធីអប់ស្បែកមុខដោយចំណាយទឹកនៅឯផ្ទះដោយខ្លួនឯងបានដូចគ្នា មិនចាំបាច់ចំណាយលុយកាកច្រើណាទៀតផង ។

**វត្ថុត្រៀមបំរុង :**

ទឹកពុះរុក្ខជាតិដែលជាថ្នាំធម្មជាតិចំនួន 2ថង់ (សំរាប់អ្នកស្បែកក្រៀមស្ងួត គួរប្រើតែប្រភេទ កាម៉ូមីល ចំណែកស្បែកខ្លាញ់ គួរតែប្រើ ប៉ិបពើមីន) ។ កន្សែងពោះគោប្រើសំរាប់ឃ្លុំក្បាល ។

**ដំណាក់កាលធ្វើ :**

1. ចាក់ទឹកពុះចំណុះ 500មីល្លីលីត្រ ទៅក្នុងឧបករណ៍មួយដែលធន់នឹងទឹកក្ដៅ រួចបង់ថង់តែទៅក្នុងនោះ ហើយកូរឱ្យរលាយចូលគ្នា ។

2. ប្រើកន្សែងពោះគោទទូរនៅលើក្បាល រួចឈ្ងោកមុខទៅលើឧបករណ៍ដាក់ទឹកក្ដៅ ដោយរក្សាគម្លាតយ៉ាងហោចណាស់ 0.3 ម៉ែត្រ ហើយចាប់ផ្ដើមកម្មវិធីអប់ផ្ទៃមុខតែម្ដង ។

3. ក្រោយពេលឈ្ងោកផ្ទងផ្ទៃមុខមិនតិចជាង 5នាទី បន្ទាប់មកសូមលោកអ្នកប្រើទឹកត្រជាក់លុបលាងស្បែកមុខ រួចប្រើដៃដែលស្អាតទទះថើៗ រហូតដល់ស្បែកស្ងួតល្អ ។ បន្ទាប់មកឆ្លុះមើលស្នាដៃរបស់អ្នក តើមានលទ្ធផលបែបណា ៕

## វិធីក្នុងការពង្រាបសក់បះត្រង់

•••មិនជាការពិបាកទាល់តែសោះ ដោយគ្រាន់តែណែនាំឱ្យសុភាពស្ត្រីទាំងឡាយយកឡកឈិត ឬក្រែមតុបតែងសរសៃរសក់ ដែលកំពុងប្រើប្រាស់បច្ចុប្បន្នមកលាបលើបាតដៃបន្តិចបន្តួច រួចលាបនៅលើសក់ក្បាលឱ្យសព្វ បន្ទាប់មកដំណាក់បន្តសាកល្បងងាកមកប្រើក្រាស់សិតសក់ ដែលផលិតចេញពីធម្មជាតិ ជំនួសឱ្យប្លាស្ទិក មកសិតពង្រាបសក់ ព្រោះវាអាចជួយថ្នមសរសៃសក់ និងស្បែកក្បាលរបស់អ្នកបាន ។

នៅមានចំណុចសំខាន់មួយទៀត ដែលអ្នកគួរចៀសវាងឱ្យបាននោះ គឺកុំប្រើឧបករណ៍ផ្លុំសក់ញឹកញាប់ពេក ព្រោះអាចធ្វើឱ្យសរសៃសក់របស់អ្នកមានសភាពក្រៀមរីងងាយនឹងដាច់បំផុត ៕



សុខភាព

# ត្រៀមរាងកាយទប់ទល់ជាមួយសីតុណ្ហភាព

*•••នៅពេលណាសីតុណ្ហភាពភពផែនដីកើនកំដៅម្ដងៗ មនុស្សមួយភាគធំរមែងមានការកែសម្រួលនូវខ្សែជីវិតរស់នៅរបស់ខ្លួនឯងជាដរាប ។ ក៏ប៉ុន្តែ កត្តាដែលគួរនឹកដល់មុនគេនោះ គឺបញ្ហាសុខភាពរបស់ខ្លួនឯងថា តើបានត្រៀមលក្ខណៈដើម្បី ទប់ទល់នឹងសីតុណ្ហភាពបែបនេះហើយឬនៅ ?*

---------------------------

ខាងក្រោមនេះគឺជាមធ្យោបាយខ្លះសំរាប់ទប់ទល់នឹងអាកាសធាតុក្ដៅ :



**❖ កែសម្រួលសកម្មភាពនៃការទទួលទាន :**

គួរងាកមកទទួលទានបន្លែ ផ្លែឈើ កាត់បន្ថយសាច់សត្វ ដើម្បីឱ្យរាងកាយចៀសវាងការធ្វើការធ្ងន់ក្នុងការរំលាយអាហារ ។

**❖ ស្វែងរកភាពស្រស់ស្រាយ :**

ចំណុចនេះអ្នកមិនចាំបាច់ស្វែងរកមើលនៅទីណាឆ្ងាយនោះទេ ដោយគ្រាន់តែសុំឱ្យទទួលទានទឹកឱ្យបានញឹកញាប់ ឬក៏បែរទៅទទួលទានផ្លែឈើ ដែលមានរសជាតិជូរ ក៏អាចសាងភាពស្រស់ស្រាយឡើងបានដែរ ។ មួយវិញទៀត គួរទទួលទានផ្លែឈើទៅតាមរដូវកាល ព្រោះវាអាចជួយកាត់បន្ថយអាការក្ដៅក្នុងបានយ៉ាងមានប្រសិទ្ធភាពបំផុត ។

**❖ ប្រុងប្រយ័ត្នរឿងបាក់តេរី :**

នៅពេលណាអាកាសធាតុកើនកំដៅខ្ពស់ ពេលនេះច្រើនមានមេរោគលាយឡំនៅក្នុងចំណីអាហារជានិច្ច ។ ចំណុចនេះ សូមណែនាំឱ្យលោកអ្នកព្យាយាមទទួលទានទឹកដោះគោជូរ ឬផ្លែឈើជ្រក់ត្រាំ ព្រោះនៅក្នុងវត្ថុអស់ទាំងនោះមាន ឡេតតូ បាស៊ីឡាស់ អាចជួយបំផ្លាញមេរោគបាក់តេរី ដែលមាននៅក្នុងខ្លួនអ្នកបាន ។

**❖ បំបាត់អាការក្ដៅក្នុងបែបធម្មជាតិ :**

ម៉ាស៊ីនត្រជាក់អាចជួយកាត់បន្ថយក្ដៅបានក៏ពិតមែន តែមធ្យោបាយដែលល្អបំផុតនោះគឺការបើកចំហបង្អួចទ្វារខ្លះ ដើម្បីទទួលយកខ្យល់អាកាសពីខាងក្រៅទើបជាវិធីល្អ ហើយងាយស្រួលថែមទៀតផង ។

អ្វីដែលយើងគួរចងចាំចុងក្រោយគេនោះ គឺកុំបណ្ដែតបណ្ដោយឱ្យសីតុណ្ហភាពក្ដៅមកបំផ្លាញរាងកាយបាន ហើយអ្វីដែលអាចជួយបាននោះ គួរតែព្យាយាមធ្វើ បើមិនដូច្នេះទេ សុខភាពលោកអ្នកពិតជាធ្លាក់យ៉ាប់យ៉ឺនជាមិនខាន ៕

# កម្ពុជាបោះឆ្នោតជាថ្មីម្ដងទៀតនៅឆ្នាំ២០០៩

**ដោយ : ខ្មែរប៉ុស្តិ៍**

ដើម្បីពង្រឹងជំហរនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ប្រមុខរដ្ឋាភិបាលខ្មែរ បានប្រកាសការបោះឆ្នោតក្រុមប្រឹក្សា ឃុំ-សង្កាត់ជាថ្មីម្ដងទៀត នៅឆ្នាំ២០០៩ ។

គឺនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩ ខាងមុខ និងមានការបោះឆ្នោតនៅតាមតំបន់ម្ដងទៀត ដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ។ មាត្រាទី៤ នៃច្បាប់បោះឆ្នោតឃុំសង្កាត់អនុញ្ញាតិឱ្យមានការជ្រើសរើសដោយសមាត់ និងមិនចំពោះនូវមេឃុំ ឬចៅសង្កាត់- ជំទប់ទី១ និងជំទប់ទី២- សមាជិកក្រុមប្រឹក្សាសំរាប់គ្រប់គ្រងឃុំ-សង្កត់ ដោយពលរដ្ឋក្នុងឃុំ-សង្កាត់ដោយខ្លួនឯង ។

ព្រះរាជាណាចក្រកម្ពុជា មានចែកជាខេត្ត និងក្រុង២៤ មានស្រុក និងខណ្ឌ ចំនួន ១៨៥ ហើយមានឃុំ និងសង្កាត់ចំនួន ១៦២១ ។ គឺនៅលើឃុំសង្កាត់ទាំងនោះហើយ ដែលការបោះឆ្នោតកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ បានប្រគល់អំណាចឃុំ-សង្កាត់ ឱ្យគណបក្សប្រជាជន ៧៩៩៣នាក់ ទៅគណបក្សសម រង្ស៊ី ២៦៦០នាក់ គណបក្សនរោត្តម រណឫទ្ធិ ៤២៥នាក់ ទៅគណបក្សហ៊្វុនស៊ិនប៉ិច ២៧៤នាក់ ហើយនឹងទៅគណបក្ស ហង្ស ដារ៉ា បាន៩នាក់ ។

ការបោះឆ្នោតនេះ គឺជាសញ្ញានៃជោគជ័យរបស់កិច្ចព្រមព្រៀងនាទីក្រុងប៉ារីស ឆ្នាំ១៩៩១ សម្រាប់ពង្រឹងលទ្ធភាពនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា គឺទស្សនៈនៃការគ្រប់គ្រងប្រទេសតាមការបង្វែអំណាចឱ្យ " តំបន់ " មានអំណាចជាម្ចាស់ការបាន ដែលគេឱ្យឈ្មោះថា " វិមជ្ឈការ " ។ ពលរដ្ឋនៅបរទេសនៅពេលចង់ជួយកម្ពុជា ឱ្យបានទទួលសេរីភាពពេញលេញ ពុំបានមើលឃើញថា ដំណាក់ការណ៍ " វិមជ្ឈការ " នេះមានសារៈសំខាន់សំរាប់ចម្លងពលរដ្ឋខ្មែរ ពីដំណាក់ការណ៍ " ផ្ដាច់ការនិយម " ទៅដំណាក់ការណ៍ " ប្រជាធិបតេយ្យ " នៅឡើយទេ ៕

## (តមកពីទំព័រទី០៦) ខ្មែរ_អាមេរិកាំងនៅហ្វីឡា...



អ្នកស្រី រ៉ែ សិន

ប្រាប់ខ្មែរប៉ុស្តិ៍ នារសៀលថ្ងៃទី ០៤ វិច្ឆិកា ថា : ឆ្នាំនេះមានពលរដ្ឋខ្មែរ-អាមេរិកាំងរហូតដល់ ៣១៦នាក់ បានទៅចុះឈ្មោះដើម្បីបោះឆ្នោត ដោយក្នុងចំនួននោះ អ្នកស្រីសង្ឃឹមថា : ៩០% នឹងចេញទៅបោះឆ្នោតតាមកាលកំណត់ ហើយមានតែ១០%ប៉ុណ្ណោះ ដែលខកខាន ពុំបានទៅបោះឆ្នោត ។

សូមជម្រាបផងដែរថា : ព្រឹទ្ធសមាជិកមកមពីគណបក្សប្រជាធិបតេយ្យវ័យ៤៧ឆ្នាំ បារ៉ាក់ អូបាម៉ា បានទទួលជ័យជំនះដ៏ត្រចះត្រចង់ក្នុងការប្រកួតប្រជែង តំណែងប្រធានាធិបតីថ្មីលើក ទី៤៤ ជាមួយលោក ចន ម៉ាកេន វ័យ៧២ឆ្នាំ មកពីគណបក្ស សាធារណរដ្ឋកាលពីថ្ងៃ០៤ វិច្ឆិកា កន្លងមកនេះ ។ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ខាងមុខ លោក អូបាម៉ា នឹងស្បថឡើងកាន់តំណែង ជាប្រធានាធិបតីថ្មីលើកទី ៤៤ ។ លោក អូបាម៉ា បានកសាងឯ កត្តកម្មប្រវត្តិសាស្ត្រអាមេរិក ជាប្រធានាធិបតីស្បែកខ្មៅ ឬក៏អាហ្វ្រិក-អាមេរិកាំងលើកដំបូងបំផុត របស់សហរដ្ឋអាមេរិក ៕

New World Travel II

ញូវើលត្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបាន ទិញសំបុត្រជិះនាវាសមុទ្រ-សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

នាទី ប្រវត្តិសាស្ត្រ

## ទំព័រប្រវត្តិសាស្ត្រ ឡាដែលហ្វីយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយ : ពិនសំខុន** ***តពីលេខមុន***

៣០កញ្ញា : រដ្ឋាភិបាលខ្មែរដាក់ពាក្យបណ្ដឹងទៅតុលាការអន្តរជាតិ ក្រុងឡាអេ ដើម្បីទាមទារប្រាសាទព្រះវិហារពីការកាន់កាប់របស់ថៃ ។

ខែតុលា : សឺងងុកថាញ់ ឈរជើងនៅនៃព្រៃនគរ ហើយផ្សព្វផ្សាយពី ចលនាខ្មែរសេរី

១១ តុលា : ចាងហ្វាងកាសែតប្រជាជនឈ្មោះ ណុប បូផាន់ បានត្រូវ គេលបសម្លាប់

២១ វិច្ឆកា : នរោត្តមសីហនុ ស្នើឱ្យមានការធ្វើប្រជាមតិ "ស្ដីពីសមាជខេត្ត" សមាជនេះក៏ត្រូវបញ្ឈប់ ហើយពុំមានឃើញត្រឡប់មកវិញទេ ។

៩មីនា ឆ្នាំ១៩៦០ រដ្ឋាភិបាលយួនខាងត្បូងទាមទារកោះថ្មី-កោះសេះ-កោះអន់តាយ-កោះតាកៀវ និងកោះពស់ ។

២ មេសា : សម្ពោធកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ សង់ឡើងដោយប្រទេសបារាំង ។

៣ មេសា : ព្រះបាទសុរាម្រិត ចូលទីវង្គត់

៩ មេសា : សភាជាតិបានតែងតាំងក្រុមប្រឹក្សារាជសម្បត្តិ នរោត្តម សីហនុ ប្រកែកមិនទទួលគ្រងរាជ្យឡើងវិញទេ ។

១៩ មេសា : រដ្ឋាភិបាលសង្គមថ្មីទី១៥ ដឹកនាំដោយ ផូ ព្រឿង ។

**•រដ្ឋាភិបាល ផូ ព្រឿង (១៩.៤.១៩៦០-២៦.១.១៩៦១)**

- នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីមហាផ្ទៃ និងធម្មការ : ផូ ព្រឿង
- ឧបនាយករដ្ឋមន្ត្រីទី១ រដ្ឋមន្ត្រីផែនការទេសចរណ៍ផលិតកម្ម-សាធារណការ និងទូរគមនាគមន៍ : ញឹក ជូឡុង
- ឧបនាយករដ្ឋមន្ត្រីទី២ រដ្ឋមន្ត្រីការបរទេស : ទេព ផន
- ទេសរដ្ឋមន្ត្រីប្រតិភូអមទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកអប់រំជាតិ : ជា ជិនកុក
- ទេសរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ : លន់ ណុល
- ទេសរដ្ឋមន្ត្រីទទួលបន្ទុកសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស : គូ រុន ។
- រដ្ឋមន្ត្រីយុត្តិធម៌ និងបោសសំអាត ទូទៅ : លឹម គ្រី
- រដ្ឋមន្ត្រីកិច្ចសេដ្ឋកិច្ច និងហិរញ្ញវត្ថុ : ទូច គីម
- រដ្ឋមន្ត្រីព័ត៌មាន : ចៅ សេង
- រដ្ឋលេខាធិការសាធារណសុខាភិបាល : យឹម ឌិត
- រដ្ឋលេខាធិការមហាផ្ទៃ : ព្រុំ ថុស
- រដ្ឋលេខាធិការលេខាធិការកសិកម្ម : ចេង ហេង
- រដ្ឋលេខាធិការការងារនិងសង្គមកិច្ច : អ្នកស្រីពុងប៉េងចេង
- រដ្ឋលេខាធិការអប់រំជាតិ : គន្ធថាវ ជីម៉ុងតេរ៉ូ
- រដ្ឋលេខាធិការសារធារណការ និងទូរគមនាគមន៍ : អ៊ឹង ក្រពុំផ្កា
- អនុរដ្ឋលេខាធិការផែនការ : ឌី បែលឡុង
- អនុរដ្ឋលេខាធិការបោសសំអាតទូទៅ : ឡេង សារ៉ន
- អនុរដ្ឋលេខាធិការកម្មការ-ទទួលបន្ទុកទំនាក់ទំនងជាមួយសភា : ស គឹមកួយ
- អនុរដ្ឋលេខាធិការហិរញ្ញវត្ថុ : អ៊ាប គឹមជន

៧ ឧសភា : សម្ពោធរោងចក្រតម្បាញ អំណោយប្រទេសចិន នៅកំពង់ចាម ។

៥ មិថុនា : សីហនុបានត្រូវជ្រើសតាំងដោយប្រជាមតិឱ្យឡើងជាព្រះប្រមុខរដ្ឋ ១៤មិថុនា សីហនុត្រូវតែងតាំងជាប្រមុខរដ្ឋដោយរដ្ឋសភាជាតិ ។

២០ មិថុនា : សីហនុធ្វើសច្ចាប្រណិធាន ហើយប្រកាសចំពោះរដ្ឋសភាជាតិថា "ព្រះមហាក្សត្រីយានី កុសុមៈ បានក្លាយជាអ្នកគ្រប់គ្រងរាជ្យបល្លង្ក" ។

១៣ កក្កដា : ខៀវសំផន បានត្រូវគេរំលោភធ្វើបាប វាយតប់ធ្វើឱ្យអាម៉ាស់ ដោយសារក្រុមរក្សាសន្តិសុខខ្មែរ ហើយដង្ហែរអាក្រាសទៅតាមផ្លូវនៃក្រុងភ្នំពេញ

១៥ សីហា : ខៀវសំផនត្រូវគេចាប់ខ្លួន ជាមួយមិនភក្ត្រ ១៧រូបទៀត ដែលជាសមាជិកកាសែត ហើយកាសែតប្រឆាំងទាំងបួនត្រូវបិទទ្វារ ។

២៩ សីហា : សម្ពោធមន្ទីរពេទ្យរុស្ស៊ីជាអំណោយរបស់សហភាពសូវៀត ។

២១ កញ្ញា : ខៀវ សំផន និងមិត្តភក្ត្រ បានត្រូវដោះលែងពួកគេបានត្រូវទទួលការសួរចម្លើយ និងទារុណកម្មនៅក្នុងគុក ។

២៨-៣០ កញ្ញា : សមាជលើកទី២ របស់បក្សប្រជាជន ដើម្បីបង្កើតគណបក្សមួយឈ្មោះគណបក្សការងារកម្ពុជា ដែលមានទូសាម៉ុត ជាអគ្គលេខាធិការ និង នួន ជា ជាអគ្គលេខាធិការរង។ ពេលនោះ សាឡុតស និងអៀងសារី បានទទួលតែងតាំងជាសមាជិកគណកម្មាធិការកណ្ដាល ។ ទស្សនៈរបស់ក្រុម ប៉ុល ពត ឬ សាឡុតស គឺជាបញ្ចប់ឥទ្ធិពលពួកវៀតណាមមកលើកម្ពុជា ហើយក៏ជាការរីកចំរើនដ៏សំខាន់មួយរបស់បក្សកុម្មុយនិស្តនៅកម្ពុជា ។

***នៅមានត***

SUNSHINE JEWELRY, INC.

▪ Fine Jewelry
▪ Certified Diamonds & Custom Design





**Holiday Specials!**

▪ Up to 50% of on selected diamond jewelry
▪ SEIKO Watches--25% off on all SEIKO watches
▪ Special Limited Time Holiday Promotion! 3 Months up to 6 months NO INTEREST.

*Offer is subject to credit approved by GE Money Bank. Promotional applies to al l purchase amounts. Promotional begins now through January 31, 2009. See store for details or call.*

**លក់ចុះថ្លៃពិសេសនាឱកាសបុណ្យ**

●អាចបញ្ចុះរហូតដល់ 50% នៅលើពេជ្រដែលជ្រើសរើស
●ចុះថ្លៃ 25% លើគ្រប់នាឡិកា "សៃកូ"
●ចុះថ្លៃពិសេសកំណត់ថ្លៃបុណ្យ ! ពី៣ខែ រហូត ៦ ខែ គ្មានយកការប្រាក់
យើងអាចសុំឱ្យក្រេឌីត នៅ G.E Money Bank បាន សំរាប់គ្រប់ដែលទិញរួមគ្នា ផ្ដើមទៅនេះបញ្ចប់នៅថ្ងៃ ៣១ មករា ឆ្នាំ ២០០៩ សូមទូរស័ព្ទរកយើង បើចង់ដឹងបន្ថែម

702 Washington Avenue Phone: (215) 271-2950
Philadelphia, Pa 19147 Fax: (215) 271-2962
Email: colorofsunshine@yahoo.com

នាទី ព្រះពុទ្ធសាសនា

# សមាធិវិបស្សនា

## ការរីកចំរើននៃព្រះធម៌

***តពីលេខមុន***

**ប្រទេសអូស្ត្រាលី :**

មជ្ឈមណ្ឌលថ្មីជាងគេ ធម្មាលោក (Dhamma Loka) ត្រូវបានសងរួចហើយ នៅរដ្ឋវិចតូរីយ៉ា (Victoria) ជិតទីក្រុងមែនបូន (Melboume) ដែលជាទីលំនៅរបស់សិស្សចាស់មួយក្រុមយ៉ាងមាំ ជាយូរមកហើយ ។ មជ្ឈមណ្ឌលបានធ្វើសកម្មភាពពេញមួយឆ្នាំជាលើកដំបូង នៅឆ្នាំ១៩៩៧។ គេបានថតសម្លេងបញ្ចូលសម្ភារៈសំរាប់បង្រៀនធម្មសិក្សា១០ថ្ងៃជាភាសម៉ុងហ្គោលី (Mongolie) ចិនកង់តុង (cantonais) មរាថី (Marathi) និង ហ្វារសី (parsi) ។

សព្វថ្ងៃនេះ ការចែកខ្សែអាត់ជាអន្តរជាតិត្រូវបានប្រព្រឹត្តធ្វើឡើងនៅមជ្ឈមណ្ឌលនានា នៅសហរដ្ឋអាមេរិក, ប្រទេសបារាំង, ជប៉ុន, អូស្ត្រាលី, និងឥណ្ឌា ។

**ព្រះធម៌ក្នុងអន្តរបណ្ដាញ (Internet) :**

មកទល់សព្វថ្ងៃនេះ ព័ត៌មានស្ថានីយ៍បណ្ដាញ (website) ស្ដីពីវិបស្សនាសំរាប់សិស្សថ្មីត្រូវបានបកប្រែពីភាសាអង់គ្លេសទៅ អេស្ប៉ាញ៉ុល, អាល្លឺម៉ង់, បារាំង, អ៊ីតាលី, ស៊ុយអែដ និង ជប៉ុន។ ជនទូទៅអាចទទួលព័ត៌មានជាភាសាទាំងឡាយនេះតាមរយៈកុំព្យូទ័រ ។ ក្នុងឆ្នាំ១៩៩៨ មានទំព័របណ្ដាញជាភាសាអេប្រ៊ី (Hébreux) និងហិណ្ឌី (Hindi) ដែរ ។ ស្ថានីយ៍អន្តរបណ្ដាញនេះ បានចាប់ផ្ដើមឡើងពីឆ្នាំ១៩៩៥ :

-នៅឆ្នាំ១៩៩៥ មានការពិនិត្យបណ្ដាញចំនួនពី១០០ ទៅ ៣០០ដង ក្នុងមួយថ្ងៃ មកបីប្រទេសនានា ចំនួនជាង១២ប្រទេស ។

នៅឆ្នាំ១៩៩៦ មានការពិនិត្យទំព័របណ្ដាញចំនួនពី ៥០០ ទៅ ១០០០ដង ក្នុងមួយថ្ងៃ មកពីប្រទេសនានាចំនួនពី២០ទៅ៣០ប្រទេស ។

នៅឆ្នាំ១៩៩៧ មានការពិនិត្យទំព័របណ្ដាញចំនួនពី ១០០០ ទៅ ២០០០ដង ក្នុងមួយថ្ងៃ មកពីប្រទេសនានា ជាង៥០ប្រទេសទូទាំងក្នុងសកលលោក ។

ពីមួយទៅមួយខែ មនុស្សកាន់តែច្រើនឡើងៗបានទទួលព័ត៌មានអំពីវិបស្សនាតាមប្រពៃណីយើង ដោយសារស្ថានីយ៍អន្តរជាតិរបស់យើង ។ ការចុះឈ្មោះតាមលិខិតអេឡិចត្រូនិចអ៊ីមេល (Electronic- Mail/e-mail) ក៏បានកើនចំនួនជានិច្ចឡើងដែរ ។ នៅក្នុងអន្តរបណ្ដាញ មានស្ថានីយ៍ពីរសំរាប់វិបស្សនាកម្មដ្ឋាន : ទំព័របណ្ដាញសំរាប់សិស្សថ្មី និងទំព័របណ្ដាញសំរាប់សិស្សចាស់ ។

-សំរាប់សិស្សថ្មី : Http : // www.dhamma.org នៅក្នុងនោះមាន ច្បាប់វិន័យ សិល្បសាស្ត្រនៃការរស់នៅ និងវិបិច្ឆេទនៃធម្មសិក្សា១០ថ្ងៃ និងធម្មសិក្សាអានាបាណនៅប្រទេសនានាក្នុងសកលលោក ។

-សំរាប់សិស្សចាស់ (សំរាប់សិស្សចាស់តែប៉ុណ្ណោះ) : Http://www.dhamma.org/os បន្ទាប់ពីចូលក្នុងទំព័រនេះហើយ ត្រូវបញ្ចូលឈ្មោះអ្នកប្រើ (use name) : oldstudent និងពាក្យសម្ងាត់ (password): be happy ។ នៅក្នុងទំព័រនេះ មានការបរិច្ឆេទនៃធម្មសិក្សាទាំងអស់នៅក្នុងសកលលោក ព្រមទាំងអត្ថបទជាច្រើនដែលមាប្រយោជន៍ចំពោះសិស្សទាំងឡាយនៃប្រពៃណីនេះ ។

**ការចូលរួម និងបំរើក្នុងធម្មសិក្សានៅប្រទេសឥណ្ឌា**

សេចក្ដីណែនាំសង្ខេបចំពោះសិស្សវិបស្សនាដែលមិនមែនជាជនជាតិឥណ្ឌា :

តាមធម្មតាសិស្សចាស់ជាច្រើនចង់មកចំរើនកម្មដ្ឋាននៅប្រទេសឥណ្ឌា-ទឹកដីព្រះពុទ្ធ ។ ចាប់ពីពេលដែលលោក ហ្គោឥនកា បានដឹកនាំធម្មសិក្សាទីមួយនៅប្រទេសឥណ្ឌា ក្នុងឆ្នាំ 1969 មកវិបស្សនាបានរីកចំរើនរហ័សណាស់ ។

សព្វថ្ងៃនេះ នៅប្រទេសឥណ្ឌាមានមជ្ឈម








ណ្ឌលជិត 30ហើយ (រាប់ទាំងសង់រួច និងមិនទាន់រួច) ហើយក្នុងមួយឆ្នាំៗសិស្សជាងពីរម៉ឺន (20.000) នាក់បានចូលរួមក្នុងធម្មសិក្សានៅទីទាំងឡាយនោះ ។ ធម្មសិក្សា 10ថ្ងៃនៅធម្មគីរី ដែលជាមជ្ឈមណ្ឌលសំខាន់ជាងគេ មានកន្លែង 500 សំរាប់ទទួលសិស្ស, (ទីកជ្រោះបានប្រែទៅជាទីកជំនន់), ដោយមានពាក្យសុំចុះឈ្មោះកើនឡើងពីរដង ។

ល្បឿន និងទំហំនៃការរីកចំរើននៃសកម្មភាពរបស់វិបស្សនានេះ នាំឱ្យមានការលំបាកផ្សេងៗដល់អ្នកចំរើនកម្មដ្ឋានមកពីប្រទេសក្រៅ ដែលចង់ចូលរួម ឬបំរើក្នុងធម្មសិក្សានៅប្រទេសឥណ្ឌា ។ សេចក្ដីណែនាំដូចតទៅនេះ បានរៀបចំឡើងដើម្បីណែនាំសិស្សចាស់ទាំងឡាយក្នុងការប្រើប្រាស់ទស្សនកិច្ចរបស់ខ្លួនឱ្យបានប្រសើរបំផុត :

**ការចូលរួមក្នុងធម្មសិក្សា :**

សូមផ្ញើពាក្យសុំមកឱ្យទាន់ពេលតាមការគួរ (មុន 8អាទិត្យ សំរាប់ធម្មគីរី, 2អាទិត្យសំរាប់មជ្ឈមណ្ឌល ឬទីកន្លែងផ្សេងៗទៀត) ។ សូមផ្ទៀងផ្ទាត់មើលកាលបរិច្ឆេទធម្មសិក្សាមុននឹងធ្វើពាក្យសុំ ហើយបញ្ជាក់ឡើងវិញ ព្រោះការប្រែប្រួលក្នុងរយៈពេលយ៉ាងខ្លីកើតមានឡើងជាញឹកញាប់ណាស់ ។

**(នៅមានត)**

# Family remembers Marine killed inAfghanistan

### San Sim, 23, was weeks away from completing his third tour.

**By MICHAEL MELLO**
**THE ORANGE COUNTY REGISTER**

Lance Cpl. San Sim came from a family of pacifists.His birthplace, the Phillipines, was ever a reminder of their journey from the terror of the Khmer Rouge. But after Sept. 11, 2001, Sim decided to fight.

Sim was shot to death while on routine patrol in Afghanistan this week, near the end of his third tour of duty. He was 23.

Seng Sim said his brother was shot Tuesday. He died Wednesday, the Department of Defense reported. A military attaché arrived at the family's home in Santa Ana that same day to notify them, Seng Sim said.

San Sim was part of the 1st Battalion, 7th Marines, 1stMarine Division, I Marine Expeditionary Force, based in Camp Pendleton and Twentynine

Buddhists believe wearing white and keeping candles lit at the house helps to guide Sim's spirit home. They will observe 100 days of remembrance.

Sim's participation in the military clashed some with his family's pacifist beliefs, but he felt strongly about his calling.

"He was proud of what he did," said sister Serene Sim.

"He felt like he was really doing something. After what happen on 9-11, he wanted to go out there and put in his own effort."

"He felt the need," sister Yasmine Sim said, "to serve the country that gave us the opportunity to escape from war."



Palms. They were due to return to the U.S. next month, First Lt. Curtis Williamson said.

Sim, a rifleman, and his unit headed to southwestern Afghanistan in April.

Their mission was security training for the Afghan NationalArmy and Afghan National Police,Williamson said, but "the situation on the ground dictated that they have more of a combat role. He was out there fighting."

Afghanistan was Sim's third tour abroad; he served twice in Iraq. He won commendations during his career, including two purple hearts.

"He thought family was important, but that it was also important to help those who are suffering," said Sim's wife, Karla Sim.

It was that desire, she said, that pushed him to re-enlist after his initial four-year commitment.

"We're really proud of him," Seng Sim said.

Sim's family settled in Santa Ana in 1985, after escaping Cambodia and the Khmer Rouge, and living in a refugee camp in Thailand. San Sim was the youngest of 11 children, born in the Philippines as his family worked to reach the U.S.

Several family members gathered at the Sim's Santa Ana home, wearing white.

Sim was in the process of gaining his citizenship; the rest of his family has already been naturalized. Family members said they will petition the government to award him citizenship posthumously.

Sim was a student at SantaAna Valley High School, where he was a wrestler.

That's where he also met military recruiters and kept in frequent contact with them.

"When he got out of high school, he wanted to do something for his country," Seng Sim said. "Everything else could wait."

Family was a big part of Sim's life, evidenced by a pile of dozens of family photos at the Sim home.

He always seemed to surround himself with children, his sisters said. With 21 nephews and nieces, that wasn't too difficult. In his spare time, he enjoyed fishing.

Sim's body is expected to return stateside sometime next week. The Sim family mourns, but will wait for him to return to California before planning a memorial.

"We came to this country to escape war.And now he's died in war," Yasmine Sim said. "Our thoughts, prayers and wishes go out to the troops still out there."

Contact the writer: **714-704-3796** or **mmello@ocregister.com**

# (តមកទំព័រទី០១) ការស្រមៃក្លាយជាការពិតនៅ...

មនុស្សមានទាំងសំណើច មានទាំងសម្រែក មានទាំងទឹកភ្នែក...គឺព្រលឹងរបស់ ម៉ាតាំ លូទ័រឃីង បានត្រូវគេទឹកដល់នារាត្រីថ្ងៃទី០៤ នោះឯង ។



**លទ្ធផលនៃការបោះឆ្នោត :**

លទ្ធផលនៃសន្លឹកឆ្នោត បានចែកចេញជា : ៦៥.៦លាននាក់ បោះឆ្នោតឱ្យ បារ៉ាក់ អូបាម៉ា ហើយ ៥៦.៨លាននាក់ បោះឆ្នោតឱ្យ ចន ម៉ាកេន គឺបាន ៥៣% អូបាម៉ា និង ៤៦% ចន ម៉ាកេន ។

**រីឯលទ្ធផលតាមចំនួនប្រតិភូវិញ :**

៣៤៩សម្លេងគាំទ្រ អូបាម៉ា ទល់នឹង ចន ម៉ាកេន ១៦៣ សម្លេង (CNN) ។

ផែនទីសហរដ្ឋអាមេរិកតំបន់នានាជាពីពណ៌: ពណ៌ខ្មៅ ជាពណ៌ដែល អូបាម៉ា ឈ្នះ រីឯតំបន់ពណ៌ប្រផេះ ជាតំបន់ដែល ម៉ាកេន ឈ្នះ ។




**តើសហគមន៍ខ្មែរបោះឆ្នោតរបៀបណា?**

នៅហ្វីឡាដែលហ្វីយ៉ា គឺជារដ្ឋគន្លឹះដ៏សំខាន់មួយ ដែលគេនិយាយថា បើបេក្ខជនណាយករដ្ឋនេះបាន មុខជានឹងឈ្នះឆ្នោត ។ ម្លោះហើយខ្មែរយើងបានចែកជាពីរនិន្នាការ គេឃើញយុវជន និងស្ត្រីជាច្រើនធ្វើសកម្មភាព ដើម្បី បារ៉ាក់ អូបា-ម៉ា ។ រីឯមនុស្សចាស់ច្រើនគាំទ្រលោក ចន ម៉ាកេន ពីព្រោះគេជឿថា ពួកសាធារណរដ្ឋ មាននយោបាយក្រៅប្រទេសរឹងមាំអាចជួយដល់កម្ពុជាបាន តែក្រុមចុងក្រោយនេះ ពុំមានធ្វើសកម្មភាពអ្វីគួរឱ្យគត់សំគាល់នោះទេ ។

នៅក្នុងចំណោមខ្មែរប្រមាណជា២ម៉ឺន៥ពាន់នាក់ អ្នកដែលមានសញ្ជាតិអាមេរិកាំងប្រមាណ ១០%តែប៉ុណ្ណោះ ។ នៅក្នុងចំនួននោះ អ្នកចេញទៅបោះឆ្នោតជាទូទៅ ពុំមានជំនឿថា ឆ្នោតរបស់ខ្លួននឹងមានឥទ្ធិពលទៅលើនយោបាយរបស់អាមេរិកាំងនោះទេ ។

**ប្រភេទនៃសន្លឹកឆ្នោត**

ចំនួនអ្នកចុះឈ្មោះទៅបោះឆ្នោតមានប្រមាណ ១៣០លាននាក់ រីឯចំនួនមនុស្សថ្មី ដែលបោះឆ្នោតលើកទី១ មានជិត៩លាននាក់ ដែលជាចំនួនច្រើនលើសលប់ពុំដែលមាន ។ នេះមកពីលក្ខណៈថ្មីពិសេសពីរយ៉ាង ដែលបញ្ចូលព្រឹត្តិការណ៍បោះឆ្នោតប្រធានាធិបតីលើកនេះ ក្លាយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្របាន គឺ ទី១ មានពលរដ្ឋស្បែកខ្មៅឈរជាបេក្ខជនប្រធានាធិបតីលើកដំបូងបង្អស់ ហើយម្យ៉ាងទៀត មានពលរដ្ឋស្ត្រីភេទឈរឈ្មោះជាបេក្ខជនអនុប្រធានាធិបតីដំបូងបង្អស់ដូចគ្នា ។

ដោយសារសេដ្ឋកិច្ចចុះដុនដាប ហើយជីវភាពប្រជាពលរដ្ឋ កំពុងតែខូចខាតយ៉ាងដំណំបន្ថែមពីលើនោះ មានគ្រោះធម្មជាតិច្រើនសារផងនោះ ពលរដ្ឋអាមេរិកាំងទាំងស ទាំងខ្មៅ ទាំងលឿង ទាំងក្រហម បានបន្ថយការស្វែងរកជ័យជំនះពីសង្គ្រាម ដើម្បីជួសជុលកិត្តិយសមកបង្កើនការគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីជួសជុលសេដ្ឋកិច្ចទៅវិញ ។ នៅក្នុងបញ្ហាសេដ្ឋកិច្ចនេះ គណបក្សប្រជាធិបតេយ្យរបស់ អូបាម៉ា បានផ្តល់ចម្លើយគួរឱ្យគាំទ្រជាងលោក ម៉ាកេន ។

អូបាម៉ា មិនត្រឹមតែទទួលការគាំទ្រពីវីរៈជនធំៗ ដូចជា: ប៊ិល និង ហ៊ីឡារី គ្លីងតុន ពីព្រឹទ្ធសមា-ជិក កេណឺឌី ទេ លោក ផូវែល អតីតនាយកសេនាធិការកងទ័ពជាតិ និងជាអតីតរដ្ឋមន្ត្រីការបរទេស គណបក្សសាធារណរដ្ឋក៏គាំទ្រ អូបាម៉ា ដែរ ដែលបន្ទាប់មកគេឃើញពលរដ្ឋស្បែកខ្មៅ ឬជនភាគតិច ឬយុវជន បានបាក់ទៅគាំទ្រ អូបាម៉ា ស្ទើរតែទាំងអស់ ៕

**ប័ណ្ណបញ្ជាកាសែតខ្មែរប៉ុស្តិ៍**

ខ្ញុំចង់ឱ្យ "ខ្មែរប៉ុស្តិ៍" ផ្ញើរកាសែតជាភាសាខ្មែរ ដែលសំបូរដោយព័ត៌មានក្នុងសហគមន៍ខ្មែរនៅបរទេស មកឱ្យខ្ញុំជាប្រចាំ រៀងរាល់ពេល ដែលកាសែតនេះចេញផ្សាយ មួយខែពីរដង ។

ឈ្មោះ និងអាស័យដ្ឋានរបស់ខ្ញុំ :

ឈ្មោះ :.......................................................
អាស័យដ្ឋាន :.................................................
...............................................................U.S.A.
ទូរស័ព្ទ :......................................................
អ៊ីមែល :......................................................

ខ្ញុំផ្ញើរភ្ជាប់ជាមួយនូវ សែក ឬ មានីអដ័រ មក U.A.M.G ចំនួន មួយខែតម្លៃ ៥ ដុល្លារ ×........(ចំនួនមួយខែ) =..................

U.A.M.G 5730Rising Sun Avenue Philadelphia,PA 19120
**Phone : (215) 722-2226**

# ប្រធានាធិបតីនៃសហរដ្ឋអាមេរិក






លោក
បារ៉ាក់
អូបាម៉ា
ប្រធានា
ធិបតីថ្មី
ទី៤៤
ឆ្នាំ២០០៨

Barak Obama

# ទស្សនៈរបស់នាយចយនៅឡុងប៊ិចជុំវិញ ដំណើរការនានានៅវត្តអាយរ៉ាប់ និងនាយ ទិត ស៊ីផាន់




•••ចយខ្ញុំមិនចង់ធ្វើការបរិយាយនោះទេ តែអ្វីៗ ដែលកើតឡើងជុំវិញបញ្ហានៅវត្តអាយ-រ៉ាប់ វាធ្វើខ្ញុំទើសភ្នែកខ្លាំងពេក។ នាយចយឆ្ងល់ណាស់ ថាតើហេតុអ្វីបានជាលោក ទិត ស៊ីផាន់ និងបក្សពួករបស់គាត់ដើរប្ដឹងគេ ប្ដឹងឯងជាច្រើនគ្នា មិនថាអ្នកណាជាអ្នកណា ឱ្យតែអ្នកនោះចង់ស្វែងរកនូវយុត្តិធម៌ប្រគេនព្រះសង្ឃ និងប្រជា-ពលរដ្ឋខ្មែរយើង។

រយៈពេល11ឆ្នាំកន្លងមក រឿងរ៉ាវនៅវត្តអាយរ៉ាប់ហាក់បីដូចជាស្ថិតនៅក្រោមការត្រួតពិនិត្យដើម្បីកេងយកនូវកំរៃសម្រាប់តែបុគ្គលឯកជនទៅវិញ តែបច្ចុប្បន្ននេះយើងមិនអាចដឹងថា លុយកាក់ទាំងឡាយនោះវាលាក់ទុកនៅទីណានោះឡើយ សូម្បីតែចៅក្រមក៏ត្រូវវង្វេងទៅលើពាក្យសំដីរបស់លោក ទិត សុផាន់ ទៀតផង ។

លោក ទិត ស៊ីផាន់ ជាអ្នកដើមចោទ មិនគួរត្រូវគេវៃខ្នោះដាក់មន្ទីរឃុំឃាំងនោះទេ នេះប្រហែលជាគាត់យល់ថា ឱ្យតែអ្នកដើមបណ្ដឹងគឺពិតជាអាចទទួលនូវជ័យជំនះ ហើយនឹងអាចបន្តដំណើរការលាក់ប្រាក់ចំណូលរបស់វត្តតាមតែចំណង់ដែលគេអាចធ្វើទៅបាន ។ ចៅក្រមគ្រាន់តែចង់បានក្រដាសស្នាមឱ្យពិតប្រាកដសេចក្ដីស្មោះត្រង់ឱ្យពិតប្រាកដតែប៉ុណ្ណោះ ចុះហេតុអ្វីក៏លោក ទិត ស៊ីផាន់ មិនព្រមធ្វើទៅតាមបញ្ជាតុលាការ ស៊ូប្ដូរខ្លួនពូនសម្ងំក្នុងមន្ទីរឃុំឃាំងទៅវិញ ?

នៅសហរដ្ឋ ច្បាប់តុលាការ នាយចយខ្ញុំមិនចេះទេ តែគ្រាន់តែដឹងថា មន្ទីរឃុំឃាំងគេធ្វើសម្រាប់ដាក់ជនល្មើសតែប៉ុណ្ណោះ ។ ជនល្មើសគឺជាជនដែលមិនគោរពនូវបទបញ្ជា ឬច្បាប់នៅក្នុងប្រទេសនីមួយៗ ហើយសហរដ្ឋអាមេរិកគឺជាប្រទេសមួយដែលមានយុត្តិធម៌ ជាងគេបង្អស់ក្នុងពិភពលោកខាងផ្នែកតុលាការ ដោយគ្មានការសូកប៉ាន់ ។

នៅថ្ងៃទី20 ខែតុលា ឆ្នាំ2008 នាយចយខ្ញុំឮថាមានសមាគមខ្លះ បក្ខពួកខ្លះបានខិតខំទៅលោះលោក ទិត ស៊ីផាន់ ឱ្យចេញក្រៅឃុំ តែមិនបានសម្រេចនោះទេ ។ សួរថាពួកទាំងនោះវាជានរណា ? ហេតុអីក៏គេខិតខំខ្លាំងម្ល៉េះ ? ឬមួយក៏ព្រោះតែពួកគេបានទទួលលាភមកពីញើសឈាមនៃពុទ្ធសាសនិកជន ? នាយចយហាក់ដូចជាលែងយល់ ។

លោក ទិត ស៊ីផាន់ ចំពោះមុខតុលាការបានខិតខំប្រមូលសមាជិករបស់ខ្លួនឱ្យចុះឈ្មោះធ្វើជាគណៈកម្មការទាំងមិនដឹងខ្លួន ហើយអ្នកទាំងនោះត្រូវបានចុះក្នុងបញ្ជីដោយមានឈ្មោះនិងអាស័យដ្ឋានតាមសេចក្ដីបង្គាប់ការរបស់ចៅក្រម ។ ខ្ញុំចេះតែបារម្ភជំនួសដល់អ្នកទាំងនោះ ព្រោះថាមានអ្នកខ្លះដែលគ្រាន់តែទៅមើលការកាត់សេចក្ដី ក៏ត្រូវមានឈ្មោះភ្លាមៗដើម្បីគម្រប់ចំនួន ។ នេះមិនខុសពីពាក្យថាស្លាប់ដូចពស់ រស់ដូចកង្កែប ឬស្វាយកបាយលាបមាត់ពពែ ។

ល្បៀងៗនាយចយឮថាក្រុមនាយ ទិត ស៊ីផាន់ ដើរសុំហត្ថលេខាពីប្រជាជននៅឡុងប៊ិចដើម្បីសុំសិទ្ធិរស់ក្រៅឃុំ ដោយមានទាំងចុះនិងលេខទូរស័ព្ទទៀតផង ។ នាយចយខ្ញុំចេះតែឆ្ងល់ ហើយចេះចង់តែប្រាប់ខ្មែរ សូមឱ្យបានជ្រាបទៅចុះថា តើនៅចាំរឿង Yes No Yes No អស់ធ្មេញដែរឬទេ ? ចំណែកលោក ទិត ស៊ីផាន់ ជាប់ទោស ព្រោះរឿងអ្វីដែរ ? ព្រោះលោក ទិត ស៊ីផាន់ ជាអ្នកដើមចោទ ហើយហេតុអ្វីក៏ត្រូវជាប់ខ្នោះចូលឃុំដូច្នេះ បើសាច់មិនបានស៊ី កុំយកឆ្អឹងព្យួរកធ្វើអី ។

ប៉ុន្តែវាហួសពេលទៅហើយ ចំពោះអ្នកខ្លះដែលតុលាការបានកត់ឈ្មោះចូលបញ្ជី តែនាយចយខ្ញុំសូមជំរាបទៅចុះថា សហរដ្ឋគេធ្វើគុកសម្រាប់មនុស្សខូច ឬជនពាលអាវ៉ាសែតែប៉ុណ្ណោះទេ ៕

FreeLife
The Himalayan Goji Company®




the World´s Most Powerful
Anti-Aging Food

ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក
គឺទឹកផ្លែឈើ "គោជី" នៃព្រៃហេមពាន្ត

HIMALYAN GOJI
Juice

ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្ដេចតាំងឆ្នាំ ៨00 គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្ដូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្ដិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបឥឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។



បើចង់បាន Goji មកពិសារសូំជាវតាម www.forever.freelife.com
ឬក៏ទូរស័ព្ទលេខ : (267) 253-3947

TIME Magazine wrote :
" this year´s breakout (Superfruit ) was the Himalyan Goji Berry, said to be a source of energy and longevity ". To order, please visit the website at : www.forever.freelife.com
Or please call (267) 253-3947 to order

# អ្នករស់នៅជាយដែន 60% រត់ភៀសខ្លួនពីលំនៅឋាន

**ព្រះវិហារ, ខ្មែរប៉ុស្តិ៍ : ស៊ុម សុភាឫទ្ធិ**

•••បន្ទាប់ពីបានផ្ទុះអាវុធដាក់គ្នានៅចំណុចវាលឥន្ទ្រីយ៍ កាលពីថ្ងៃទី 15 តុលានោះ បានបណ្តាលឱ្យទាហានខ្មែរ-សៀម របួស និងស្លាប់ទាំងសងខាង ។ ចំណែកឯប្រជាពលរដ្ឋខ្មែរដែលរស់នៅក្បែរតំបន់ជំលោះនោះ មានការភ័យខ្លាចពីបញ្ហាសុវត្ថិភាពផ្ទាល់ខ្លួន ក៏បានធ្វើការភៀសខ្លួនចាក់ចេញពីផ្ទះសម្បែងជាបន្តបន្ទាប់ប្រមាណ 60% ។

អ្នកស្រុកដែលរស់នៅក្បែរតំបន់ប្រាសាទសឹងតែជាអ្នកចំណូលថ្មី មកពីបណ្តាខេត្ត-ក្រុងនានាទូទាំងប្រទេស ។

រហូតមកដល់ថ្ងៃទី 22 តុលា សាលារៀនចំនួន 159 កន្លែង ដែលបានបិទទ្វារ នៅខេត្តជាប់ព្រំដែនពីរ បានបើកឡើងវិញចំនួន 113 កន្លែង តែមានចំនួនសិស្សតិចតួចប៉ុណ្ណោះ ។

លោក អ៊ឹង បូរ៉ាត់ ប្រធានមន្ទីរពេទ្យអប់រំយុវជន និងកីឡា ខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ក្នុងចំណោមសាលារៀន 50 កន្លែង ដែលបានបិទទ្វារនោះ គឺមាន8កន្លែងបានបើកទ្វារឡើងវិញហើយ ប៉ុន្តែសិស្សមករៀនមិនច្រើននោះទេ ។



ប្រជាពលរដ្ឋនៅក្បែរតំបន់ប្រាសាទព្រះវិហារភៀសខ្លួនទៅរកតំបន់សុវត្ថិភាព

ព្រះវិហារទាំងនោះ រួមមានភូមិប្រាសាទ ភូមិ គ1 និងភូមិស្វាយជ្រំ ស្ថិតនៅក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត បានបង្ខំចិត្តចាកចេញពីលំនៅឋានរបស់ខ្លួនទៅរស់នៅតំបន់មានសុវត្ថិភាពបណ្តោះអាសន្ន ។

យោងតាមរបាយការណ៍របស់ប្រជាពលរដ្ឋទាំង3ភូមិ មានប្រមាណជាង 2000 នាក់ ក្នុងនោះមានស្ត្រី 1524 នាក់ បានវេចបង្វេចទៅស្នាក់នៅតំបន់ផ្សេងៗជាបណ្តោះអាសន្ន ដែលភាគច្រើនឆ្ពោះទៅស្រុកត្បែងមានជ័យ និងខេត្ត-សៀមរាម ។

លោក ទួន តាំងឃី រស់នៅភូមិប្រាសាទបានប្រាប់ខ្មែរប៉ុស្តិ៍ឱ្យដឹងថា ក្នុងព្រឹត្តិការណ៍បង្ហូរឈាមគ្នាមួយចំអិនកំពីស កាលពីថ្ងៃទី 15 តុលាកន្លងមកនេះ អ្នកស្រុកដែលរស់នៅក្បែរនោះបានបិទទ្វារផ្ទះចោលរួចចាកចេញទៅកាន់តំបន់ផ្សេងៗយ៉ាងតក់ក្រហល់បំផុត ដោយពុំបានយករបស់អ្វីសំខាន់ទៅជាមួយនោះទេ ។

លោក ទួន តាំងឃី បានបន្តថា ការរត់ភៀសខ្លួននេះ វាមិនត្រឹមតែធ្វើឱ្យពួកគាត់បាត់បង់មុខរបរ និងទីជំរកនោះទេ គឺវាធ្វើឱ្យកូនចៅរបស់គាត់ខានបានរៀនសូត្រថែមទៀតផង ។

លោក ប្រាក់ ភី ប្រធានភូមិស្រងម បានឱ្យដឹងថា អ្នកស្រុកដែលរស់នៅក្បែរតំបន់ប្រាសាទព្រះវិហារ បានទៅតាំងទីលំនៅតាំងពីឆ្នាំ2000 ម្ល៉េះ ហើយក្នុងចំណោមពួកគាត់ទាំងនោះ សុទ្ធ

ចំណែកលោក ប្លែង សារ៉ុត ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តបន្ទាយមានជ័យបានឱ្យដឹងថា ក្នុងព្រឹត្តិការណ៍កាលពីថ្ងៃទី 15 តុលានោះ សាលារៀន 89 កន្លែង ដែលបានបិទទ្វារជាបណ្តោះអាសន្ននោះ បានដំណើរការឡើងវិញហើយ ប៉ុន្តែវាពុំទាន់ដំណើរការបានល្អនៅឡើយនោះទេ ។

ព្រឹត្តិការណ៍បង្ហូរឈាមនៅចំណុចវាលឥន្ទ្រីតំបន់ប្រាសាទព្រះវិហារនេះ បានបង្កនូវគ្រោះមហន្តរាយដល់កងទ័ព និងប្រជាពលរដ្ឋរស់នៅក្នុងសភាពភ័យខ្លាចបានបង្ខំចិត្តរត់គេចពីសង្គ្រាមដូចអំឡុងឆ្នាំ 1980 អីចឹង ។

អ្នកវិភាគនយោបាយបានបញ្ចេញទស្សនៈថា ព្រឹត្តិការណ៍ផ្ទុះអាវុធនៅតំបន់ប្រាសាទព្រះវិហារ និងតំបន់ផ្សេងៗទៀត អាចនឹងកើតមានម្តងទៀត ក្នុងទ្រង់ទ្រាយតូច ឬធំ ពីព្រោះការចរចាទ្វេភាគីវាគ្មានផលចំណេញអ្វីនោះទេសំរាប់ខ្មែរ ។

ប្រភពខាងលើបានបន្តថា ភាពរីករវរនៅតាមព្រំដែនខ្មែរ-សៀមនេះ វាបណ្តាលមកពីមេដឹកនាំខ្មែរ ហ៊ុន សែន មិនព្រមប្តឹងទៅសមាគមន៍អាស៊ាន និងប្តឹងទៅអង្គការសហប្រជាជាតិឱ្យជួយដោះស្រាយ ហើយ គិតតែពីកចរចាទ្វេភាគីធេ្វឱ្យសៀម មើលងាយបែបនេះ ៕

## (តមកពីទំព័រទី០១) ជម្លោះវត្ត IRAP ឈានដល់ការ...

បញ្ជាចាប់ខ្លួនដាក់គុក កាលពីថ្ងៃទី២០ ខែតុលា ពីបទល្មើស ទៅនឹងបទបញ្ជារបស់តុលាការ ក្នុងការបដិសេធមិនអនុវត្តតាមសាលក្រមតុលាការកំពូលរបស់រដ្ឋ California ក្នុងការប្រគល់ឯកសារពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិ និងថវិការបស់វត្ត IRAP បានកើតមានរយៈពេលជិតមួយឆ្នាំមកហើយ រវាងភាគីពុទ្ធបរិស័ទ ព្រះសង្ឃ និងគណៈ-កម្មការវត្តចាស់របស់លោក ពៅ ស៊ីវន, ទិត្យ ស៊ីផាន់ ដែលចោទប្រកាន់ថា គណៈកម្មការនេះដឹកគណៈកម្មការចាស់របស់អ្នកទាំងពីរជាដើមចោទ ចំណែកក្រុមព្រះសង្ឃ និងពុទ្ធបរិស័ទ ដែលជាគណៈកម្មការថ្មី ចេញពីការបោះឆ្នោតកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៨ ដែលគ្មានការទទួលស្គាល់ពីក្រុមគណៈកម្មការចាស់នោះ គឺជាចុងចោទនៅក្នុងផ្លូវច្បាប់តុលាការជាច្រើនលើកច្រើនសារ រហូតមកដល់ខែវិច្ឆិកានេះ មិនទាន់ត្រូវបានបញ្ចប់ទាំងស្រុងទេ ។

ប៉ុន្តែនៅក្នុងការកាត់ក្តីដោយសុភវិនិច្ឆ័យ



ទិត្យ ស៊ីផាន់ (រូបថត ឯល ម៉ាន់ថា)

នាំវត្តខុសច្បាប់មិនមានការបោះឆ្នោតមក១១ឆ្នាំ ផ្ទុយពីលក្ខន្តិកៈសមាគមវត្តវិបស្សនារាម និងរំលោភបំពានដល់សិទ្ធិព្រះសង្ឃ យាយជី ជាដើម ដោយរួមទាំងការចាយវាយនូវថវិកានៃចំណូលចំណាយលាក់លៀមមិនឱ្យព្រះចៅអធិការវត្តដឹងឮជារបាយការណ៍អ្វីឡើយ ។ ប៉ុន្តែការចោទប្រកាន់នេះត្រូវបានក្រុម ពៅ ស៊ីវន និង ទិត្យ ស៊ីផាន់ បដិសេធបន្តរហូតដល់មានការប្តឹងបុ្តល់គ្នា ដែលតុលាការចៅក្រមបានមើលឃើញថា ដោយមិនចង់ឃើញថា ភាគីខាងណាជាអ្នកឈ្នះ-អ្នកចាញ់ ចៅក្រមក៏សម្រេចឱ្យមានគណៈកម្មការកណ្តាល ដើម្បីគ្រប់គ្រងវត្តជាបណ្តោះអាសន្ន ក្នុងការឈានទៅរកការបោះឆ្នោតជ្រើសរើសគណៈ-កម្មការវត្តថ្មី ដោយមានតំណាង3នាក់ពីភាគីជម្លោះ និងម្នាក់ចាត់តាំងដោយតុលាការក្នុង

(តទៅទំព័រទី២១)


**ANGKOR AUTO SERVICE, INC.**

**ហាងជួសជុលរថយន្ត "អង្គរ"**

4835 N. 16th Street.
Philadelphia, Pa 19141

Tel : (215) 455-7810
Ricky : (215) 485-1425

Specializing in Body Kit and Custom Paint

ជំនាញខាងជួសជុលតួរថយន្ត និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រ វាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនសូរិន បានផង យើងផ្តល់សេវាគ្រប់យ៉ាង :

-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C









បើកពីម៉ោង ៩ ព្រឹក ដល់ម៉ោង៥ល្ងាច ពីថ្ងៃ ច័ន្ទ ដល់ ថ្ងៃ សៅរ៍

ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

## នាទីអប់រំ ១០ប្រការដើម្បីឱ្យក្លាយជាមាតាបិតាដ៏ប្រសើរ

១- ត្រូវឱ្យគំរូល្អ- កូនអ្នកនឹងរៀនចេះពីគំរូល្អនោះ ។

២- បង្ហាញថាយើងគោរពដល់អារម្មណ៍ គំនិតនិងផ្តល់យោបល់របស់កូនដែរ ។

៣- ធ្វើអ្វីឱ្យកូនយល់ថា ម្តាយឪពុកស្រឡាញ់គេដោយពាក្យកោតសរសើរ និងដោយការឱបថើបកូន ។

៤- ឱ្យទប់សម្តី-បើជាភ្លាត់ឱ្យសុំទោស ហើយលើកដំកើងកូនឡើងវិញ ។

៥- លើកទឹកចិត្តកូនឱ្យបង្កើតអ្វីផ្សេងៗ តាំងសំនួរដើម្បីបង្កើនការចង់ដឹង ឬការមានគំនិតថ្មី ។

៦-បង្ហាត់ឱ្យកូនទុកចិត្តខ្លួនឯង បង្ហាញការពេញចិត្តទៅលើការខិតខំអ្វីមួយ ដែលកូនធ្វើបានប្រសើរ ។

៧- ទៅចូលរួមជាប្រចាំ ត្រូវដឹងពីអ្វីដែលកើតឡើងក្នុងជីវិតកូន ទាំងនៅសាលា និងនៅជាមួយមិត្តភ័ក្រ

៨- ដាក់វិន័យឱ្យកូនដោយយុត្តិធម៌ ដោយតឹងតែង និងដោយស្រឡាញ់ពិនិត្យលើចរិតឬកពារ តែមិនពិនិត្យនៅលើកូនទេ ។

៩- បង្កបង្កើតឱ្យមានទម្លាប់គ្រួសារមួយ ហើយឱ្យមានពេលលេងសើចជាមួយកូនផង ។

១០-ត្រូវគិតឱ្យវិជ្ជមាន ដោយសង្ឃឹមលើអ្វីដែលប្រសើរជាងគេអ្នកនឹងផ្តល់ថាមពលដល់ខ្លួន និងដល់កូន ដើម្បីដោះស្រាយបញ្ហា និងដើម្បីឱ្យទៅដល់វត្ថុបំណង ។

មាតាបិតានៅសហរដ្ឋអាមេរិកនេះ គួរពិនិត្យការអនុវត្តន៍វប្បធម៌ប្រដៅកូនចៅឡើងវិញ ដើម្បីឱ្យការប្រៀនប្រដៅរបស់លោកអ្នកអាចឱ្យកូនចៅទទួលយកទៅប្រើបាន ៕




## (តមកពីទំព័រទី១០) ហ៊ុន សែន_ស៊ុមឆាយ ឯកភាព...

អនុម័តមុនពេលប្រទេសសៀមចាប់ផ្តើមនូវការចរចាជាមួយកម្ពុជា ។ សេចក្តីប្រកាសព័ត៌មាននោះ បានបន្ថែមទៀតថា ភាគីកម្ពុជាបានទទួលស្គាល់នូវបញ្ហាទាំងឡាយដែលភាគីសៀមត្រូវធ្វើ ។ ភាគីសៀមនឹងពិចារណាទៅលើក្របខ័ណទាំងនោះ នៅថ្ងៃទី28 ខែតុលា ។ បើយោងទៅតាមសេចក្តីប្រកាសព័ត៌មាននេះ ការចរចាបន្ថែមទៀតនោះនឹងមិនអាចធ្វើទៅបានឡើយ ដរាបណាមិនមានការអនុម័តពីសភាសៀម ។

ទោះបីជាមេដឹកនាំកម្ពុជា និងសៀម ព្រមទាំងកងទ័ពនៃប្រទេសទាំងពីរបានបង្ហាញពីឆន្ទៈនៅក្នុងនៅក្នុងការទប់ស្កាត់មិនឱ្យមានការផ្ទុះអាវុធបន្តទៀតក្តី ហើយការចរចានៅខេត្តសៀមរាប មិនបានឈានដល់ទៅការដកទ័ពចេញពីតំបន់ជម្លោះឡើយ ។

ឯកសារដែលចុះហត្ថលេខា ដោយ លោក ជា ម៉ន និងលោក ក៏បានបង្ហាញពីការសាទរចំពោះរួមសហការគ្នា ដោះស្រាយបន្ធូរបន្ថយស្ថានការណ៍នៅបរិវេណភូមិសាស្ត្រប្រាសាទតាមាន់ និងប្រាសាទតាក្របី ដោយសន្តិវិធី ។

**កម្ពុជាចេញកំណត់ទូតបញ្ជាក់ថា "ផ្ទះរួមចិត្ត" ស្ថិតនៅខាងក្នុងដីខ្មែរ :**

នៅថ្ងៃទី23 ខែតុលា ក្រសួងការបរទេសកម្ពុជា បានចេញកំណត់ទូតមួយផ្ញើជូនក្រសួងការបរទេសសៀមអះអាងបញ្ជាក់ពីអធិបតេយ្យភាពរបស់កម្ពុជាលើ "ផ្ទះរួមចិត្ត" នាតំបន់ត្រី-កោណមរតក ដែលសៀមចោទថា ជាតំបន់មិនច្បាស់លាស់ ហើយទាហានកម្ពុជាចូលកាន់កាប់ ។

ក្នុងកំណត់ទូតនោះ ក្រសួងការបរទេសកម្ពុជាបញ្ជាក់ថា "ផ្ទះរួមចិត្ត គឺស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកទៅតាមនិយមការទីតាំងផ្ទះនេះ ដៅនៅលើផែនទីខ្នាត 1/50.000 សេរី I-708 (ដូចមាន ជូនភ្ជាប់មកជាមួយ ) ដែលឯកភាពយកមកប្រើប្រាស់ដោយក្រុមបច្ចេកទេសកម្ពុជា-សៀម សម្រាប់បេសកកម្មរុករក និងស្វែងយល់ពីស្ថានភាព និងទីតាំងបង្គោលព្រំដែនគោកទាំង 73 ក្នុងជំនួបពិភាក្សាលើកទី1 របស់មន្ត្រីបច្ចេកទេសកម្ពុជា-សៀម នៅភ្នំពេញ កាលពីថ្ងៃទី 29 ថ្ងៃទី30 ខែកញ្ញា 2003" ។

កំណត់ការទូតបានបន្ថែមថា "ដូចបានបញ្ជាក់ម្តងហើយ ម្តងទៀត កន្លងមកកម្ពុជានៅតែប្តេជ្ញាចិត្តមុតមាំថា មិនទន្ទ្រានចូលទឹកដីសៀម សូម្បីតែមួយចំណិតណាឡើយ ហើយកម្ពុជាពិតជារីករាយណាស់ ប្រសិនបើប្រទេសសៀមឆ្លើយតបដោយការប្តេជ្ញាចិត្តដូចគ្នា ក្នុងពេលរង់ចាំការកំណត់សីមាព្រំដែនពីគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោគកម្ពុជា-សៀម" ។

គួររំលឹកថា កាលពីថ្ងៃទី21 ខែតុលា ក្រសួងការបរទេសសៀមបានធ្វើការតវ៉ានៅស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកថា ទាហានកម្ពុជាបានទៅកាន់កាប់ដោយខុសច្បាប់ទៅលើ "ផ្ទះរួមចិត្ត" នោះ ។

ប្រភពយោធាបាននិយាយថា ក្រោយឆ្នាំ 1979 ទីនោះកាន់កាប់ដោយខ្មែរក្រហម ហើយក្នុងសម័យដើមទស្សវត្សរ៍ឆ្នាំ1990 កងទ័ពកម្ពុជាបានវាយកាន់កាប់ទីនោះពីពួកខ្មែរក្រហមរឹបអូសបានអាវុធជាច្រើនតោន ៕

**Reasons Why You Want to Put**
The Advertisement with the Khmer Post
In Philadelphia

**បុព្វហេតុដែលនាំឱ្យលោកអ្នកផ្សាយពាណិជ្ជកម្មនៅ "ខ្មែរប៉ុស្តិ៍"**

The Khmer Post is the only Cambodian media that available to reach out over 30,000 Cambodian readers who live in Philadelphia.




"ខ្មែរប៉ុស្តិ៍" គឺជាប្រព័ន្ធផ្សព្វផ្សាយខ្មែរតែមួយ ដែលចែកផ្សាយដល់អ្នកអានខ្មែរប្រមាណ ៣ ម៉ឺននាក់ កំពុងរស់នៅហ្វីឡាដែលហ្វីយ៉ា

One phone call away to grow your business, 20% discount when you sign up for a contract of year by calling this number (267) 253-3947.

លេខទូរស័ព្ទដែលធ្វើឱ្យពាណិជ្ជកម្មលោកអ្នករីកដុះដាល គឺ :
**(267) 253-3947**
យើងខ្ញុំចុះថ្លៃជូន ២០ % បើលោកអ្នកផ្សាយ ១ ឆ្នាំ

**Growing your business. Advertise yourself.**

# (តមកពីទំព័រទី០៩) ឥទ្ធិពលអន្តរជាតិនាំឱ្យខ្មែរ...

របស់លោក ហ៊ុន សែន ទេ គឺវាជាកម្មសិទ្ធិរបស់ពលរដ្ឋខ្មែរមួយប្រទេស ដោយការសម្រេចអ្វីៗទាំងអស់ គឺត្រូវតែបំរើផលប្រយោជន៍ខ្មែរ ។ ដូច្នេះកិច្ចព្រមព្រៀងក្រុងប៉ារីសគេធ្វើឡើង ដើម្បីបំរើផលប្រយោជន៍ខ្មែរ ដែលកម្ពុជាមានឯកសារខជាអាវុធក្នុងការចរចាជាមួយប្រទេសសៀមយ៉ាងមានប្រសិទ្ធិភាពឈ្នះដោយយុត្តិធមិឈ្នះដោយភាពល្បាញល្បី ដោយសន្តិវិធីឈ្នះដោយមិនប្រើកាណុងអាវុធ តាមកិច្ចព្រមព្រៀងនៃសន្ធិសញ្ញាបារាំង-សៀមឆ្នាំ ១៩០៤-១៩០៧ សាល ក្រមនៃតុលាការក្រុងឡាអេ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលសៀមជាប្រទេសចុះហត្ថលេខីនៃកិច្ចព្រមព្រៀងនោះផងដែរ ។

លោកឧបនាយករដ្ឋមន្ត្រីកម្ពុជា ហោ ណាំហុង ធ្លាប់បានប្រាប់ដល់អ្នកកាសែតថា ប្រសិនបើការចរចាណាមួយជាមួយភាគីសៀមមិនឈានទៅរកការត្រូវគ្នាទេ កម្ពុជានឹងប្តឹងទៅអង្គការសហប្រជាជាតិ និងតុលាការក្រុងឡាអេ ប៉ុន្តែមិនបានកំណត់លក្ខខ័ណ្ឌនៃកាលបរិច្ឆេទណាមួយឱ្យប្រាកដប្រជានៅឡើយទេ ។

ក្រោយពីការរំលោភបំពានពីសំណាក់កងទ័ពសៀម រដ្ឋាភិបាលកម្ពុជាបានធ្លាប់ដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិម្តងមកហើយ ប៉ុន្តែបណ្តឹងនោះក៏ត្រូវបានដកចេញវិញ ដោយគ្មានមូលហេតុបញ្ជាក់។

ការដកបណ្តឹងដោយមិនប្តឹងទៅអង្គការសហប្រជាជាតិរបស់លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ត្រូវបានរងការចោទប្រកាន់ពីមតិមហាជនខ្មែរ និងបរទេសអះអាងថា ហ៊ុន សែន ទំនងជាមានអាថិកំបាំងណាមួយក្នុងកិច្ចព្រមព្រៀងជាមួយអតីតនាយករដ្ឋមន្ត្រីសៀម ថាក់ស៊ីន ក្នុងផលប្រយោជន៍រួម រកស៊ីនៃទីផ្សារភាគហ៊ុនជាមួយគ្នា ក្នុងការបង្កើតទីក្រុងរណបនៅលើទឹកដីកោះកុង និងវិស័យទេសចរណ៍ នៅប្រាសាទព្រះវិហារបានជាព្យាយាមស្វែងរកការចរចាទ្វេភាគី ដោយមិនពឹងផ្អែកអន្តរជាតិ និងច្បាប់ដែលមានជាគោលមកហើយនោះមកធ្វើការចរចា Sic ។

+ពួកអ្នកវិភាគនយោបាយមួយចំនួនបានគិតថា សៀមមិនមានឆន្ទៈចង់ឱ្យមានការចរចាណាមួយជាលក្ខណៈការចរចា និងដោះស្រាយដោយអន្តរជាតិឡើយ ។ គ្រប់យ៉ាងគេធ្វើនយោបាយការទូតជាមួយកម្ពុជាក្នុងការចរចាជាទ្វេភាគីដើម្បីពន្យាពេលការរំលោភបំពានមកលើទឹកដីខ្មែរតាមរយៈកម្លាំងប្រដាប់អាវុធក្នុងយថាហេតុណាមួយ ដែលអាចធ្វើទៅបានក្នុងខណៈពេលបច្ចុប្បន្ន ដែលកងទ័ពសៀមកំពុងតែពង្រឹងកម្លាំងយោធាអាវុធយុទ្ធភ័ណ្ឌតាមបណ្តោយព្រំដែនដីជាង៧០០គីឡូម៉ែត្រ ។

### +ការប្រៀបធៀបកម្លាំងទ័ព និង អាវុធ រវាងភាគីសៀម និងខ្មែរ :

ប្រភពពីមន្ត្រីចារកិច្ចយោធាអាមេរិក D.I.A សុំមិនបញ្ចេញឈ្មោះ ដែលឈរជើងនៅទីក្រុងបាងកក បានប្រាប់ខ្មែរប៉ុស្តិ៍ឱ្យដឹងថា ក្នុងរបាយការណ៍ពីស្ថិតិកងទ័ពសៀម និងសំភារៈសឹករបស់សៀម ក្នុងឆ្នាំ២០០៨ សៀមមានកម្លាំងទ័ពសកម្ម និងបំរុងជិត៣២ម៉ឺននាក់បំពាក់ដោយអាវុធយុទ្ធភ័ណ្ឌទំនើបៗ ដែលខាងផ្នែកកងទ័ពជើងគោកមានអាវុធធន់ធ្ងន់ជិត៣០០០គ្រឿង អាវុធធុនស្រាលរាប់មិនអស់ រថក្រោះ រទេះតង់ រថពាសដែកទំនើបៗ ជាង១៣០០គ្រឿង ។ ចំណែកសំភារៈយោធាផ្នែកជើងទឹក មានកប៉ាលចម្បាំងតូច-ធំ នាវាមុជទឹក កប៉ាល់ដោះមីនក្នុងបាតសមុទ្រ កប៉ាល់ដឹកជញ្ជូនទ័ព យន្តហោះ ចម្បាំងជាង១០០គ្រឿង បំពាក់ដោយអាវុធទំនើបៗ និងសំភារៈទ័ពអាកាសមានយន្តហោះចម្បាំងគ្រប់ធុនបំពាក់ដោយគ្រាប់មីស៊ីលផងនោះ និងយន្តហោះដឹកជញ្ជូនទ័ពដែលសរុបទាំងអស់ជិត ៥០០គ្រឿង ។

+តាមស្ថិតិនេះមន្ត្រីចារកម្មយោធាអាមេរិករូបនោះបានសួរថា បើសិនជាមានសង្គ្រាមចម្បាំងជាមួយសៀមរឿងបញ្ហាព្រំដែន ឬបញ្ហាប្រាសាទនោះ តើកងទ័ពខ្មែរមានកម្លាំងមានអាវុធយុទ្ធភ័ណ្ឌទំនើបគ្រប់គ្រាន់ដើម្បីយកជ័យជំនះបានឬទេ ?

យោងតាមស្ថិតិពីរដ្ឋាភិបាលកម្ពុជាពីឆ្នាំ២០០១ពីការពិនិត្យមើលសំភារៈសឹកក្នុងកងយោធពលខេមរភូមិន្ទ ដែលផ្សាយដោយកាសែតភ្នំពេញប៉ុស្តិ៍ បង្ហាញថា កម្ពុជាមានកងទ័ព១៤ម៉ឺននាក់ កាំភ្លើងតូច-ធំ មានរ៉ុកកែត បេ៤០ បេ៤១ កាំភ្លើងត្បាល់ កាំភ្លើងអាកា ៤៧ជាដើម ។ល។ ដែលភាគច្រើនផលិតនៅស្រុកចិន និងរុស្ស៊ី ដែលនៅសេសសល់ពីសម័យសង្គ្រាម ។

ជាមួយយន្តហោះចម្បាំង មិច១៧ ឬមិច២១ ទិញពីអតីតសហភាពសូវៀត ចូលសំចតនៅវាលពោចិនតុង មានខ្លះបែកកង់ ខ្លះកំពិតតួ ។ ចំណែករថក្រោះ និងរថពាសដែកមួយចំនួនផលិតក្រោយសម័យសង្គ្រាមលោកលើកទី២ ចុងទសវត្សឆ្នាំ១៩៤០ រួមនឹងកាំជ្រួចបាញ់យន្តហោះប្រភេទសាំ៧ (SAM-7) ដែលទាហានអាចបាញ់ពីលើស្មា ។ ប៉ុន្តែគេនៅចាំបានថា កាំជ្រួចទាំងនោះបានដុតបំផ្លាញអស់ខ្លះទៅ ហើយកាលពីប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានការចូលរួមជាសាក្សីពីអតីតឯកអគ្គរដ្ឋទូតអាមេរិក ប្រចាំកម្ពុជាជំនាន់លោក ឆារ៉េ នៅខេត្តកំពង់ស្ពឺ ។

+យោងតាមប្រភពមិនច្បាស់ការថា កម្ពុជាមានជំនួយយន្តហោះចម្បាំងថ្មីៗ និងរថក្រោះមកពីប្រទេសចិន ។ រហូតដល់មានការអះអាងថា កងទ័ពកម្ពុជាបានចល័តដោយដឹកជញ្ជូនទៅកាន់តំបន់ជម្លោះទៀតផង ។ នេះបើតាមការអះអាងរបស់អ្នករាយការណ៍ព័ត៌មានពិសេសរបស់កាសែតខ្មែរប៉ុស្តិ៍ ដែលបានឃើញផ្ទាល់នឹងភ្នែកនៅតំបន់អន្លង់វែង និងតំបន់ជើងភ្នំប្រាសាទព្រះវិហារ ។

តាមកញ្ចក់ទូរទស្សន៍ជាតិ និងទូរទស្សន៍ CTN កន្លងមកបានបញ្ចាំងរូបភាពទាហានប្រចាំការនៅតំបន់ប្រាសាទទាំងអស់ មិនសូវមានស្បៀងអាហារសំភារៈសឹកគ្រឿងប្រដាប់ការពារជម្ងឺឱ្យបានគ្រប់គ្រាន់ឡើយ ហើយមានទាហានខ្លះគ្មានឯកសណ្ឋានទ័ពគ្រប់គ្រាន់ឡើយពាក់ទៅដោយស្បែកជើងផ្ទាត់ ជ្រកក្នុងខ្ទមរងាញ័រញាក់នៅពេលភ្លៀងធ្លាក់ និងគេងចងអង្រឹងក្រោមដើមឈើដូចជា ទ័ពព្រៃក្នុងខណៈដែលកងទ័ពសៀមចម្រុះទៅដោយឯកសណ្ឋានយោធាគ្រប់គ្រាន់ជាមួយសំភារៈយោធាសឹកគ្រប់យ៉ាងសំរាប់ការច្បាំងនោះ ។ ប៉ុន្តែទោះបីជាយ៉ាងនោះក៏ដោយកងទ័ពខ្មែរនៅតែសំដែងភាពអង់អាចក្លាហានក្នុងវីរភាពប្រយុទ្ធប្រឆាំងជាមួយកងទ័ពសៀមនៅពេលដែលមានការរំលោភបំពានយកទឹកដី កម្ពុជាដោយមិនតក់ស្លុតជាមួយសេចក្តីស្លាប់ឡើយ ៕



យន្តហោះចម្បាំងរបស់កម្ពុជាចតនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ





យន្តហោះរបស់សៀម




## (តមកពីទំព័រទី០៩) មរណភាព ហុក ឡុងឌី ...

មនុស្សនៅកម្ពុជាជាបន្តបន្ទាប់ ។

ចំណែកប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញមួយចំនួនហាក់ដូចជា មានអារម្មណ៍ធម្មតា ហើយអ្នកខ្លះទៀត និយាយថា យើងសូមជូនពរឱ្យលោកបានសេចក្តីសុខទៅចុះ ពីព្រោះលោក ហុក ឡុងឌី បានធ្វើឱ្យមនុស្សមួយចំនួនស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់ ។

ប្រភពខាងលើបាននិយាយទាំងកំហឹងថា ពួកគាត់ពីដំបូងឡើយមិនជឿថា លោកនាយប៉ូលិសរូបនេះ ហ៊ានប្រព្រឹត្តអំពើអាក្រក់ដាក់ជនស្លូតត្រង់ដូចការលើកឡើងរបស់អ្នកកាសែត និងសកម្មជននយោបាយមួយចំនួននោះទេ ។ ប៉ុន្តែ នៅពេលដែល ហេង ពៅ អតីតស្នងការ ប៉ូលិសក្រុងភ្នំពេញ បានឆ្លើយសារភាពប្រាប់ដល់សាធារណជនពីទង្វើអាក្រក់របស់ ហុក ឡុងឌី ដែលបានរៀបគំរោងការសម្លាប់អ្នកនយោបាយ សិល្បការិនី និងសកម្មជនសិទ្ធិមនុស្សមួយចំនួនទៀត ធ្វើឱ្យពួកគាត់មានការឆ្អែតចិត្តយ៉ាងខ្លាំង ។

ប្រភពខាងលើបានបន្តទៀតថា ហុក ឡុងឌី គាត់មានអំណាច មានលុយ ដូច្នេះគ្មានអ្នកណាហ៊ានក្អកជាមួយគាត់ទេ គឺមានតែទេវតា ទើបហ៊ាន ហើយការស្លាប់បាត់បង់ជីវិតរបស់គាត់នេះ ប្រហែលពីកម្មពាររបស់គាត់ទេ ។

តាមប្រភពព័ត៌មានក្រៅផ្លូវការដែលខ្មែរប៉ុស្តិ៍ទទួលបានបញ្ជាក់ថា លោក ហុក ឡុងឌី ធ្លាប់បានរៀបគំរោងការបោកគ្រាប់បែកនៅមុខរដ្ឋសភា ថ្ងៃទី ៣០ មីនា ឆ្នាំ ១៩៩៧ ធ្វើឃាតទៅលើ លោក ឱម រដ្ឋសាឌី តំណាងរាស្ត្រគណបក្ស ហ៊្វុនស៊ិនប៉ិច ធ្វើឃាត លោក ជា វិជ្ជា តំណាងសហជីពសេរីកម្មករកម្ពុជា អ្នកកាសែតមនសិការ លោក ឃឹម សំបូរ និងកូនប្រុស សិល្បការិនី ពិសិដ្ឋពិលីកា តារាចំរៀង ទូច ស៊ុននិច.... ។

គួរបញ្ជាក់ថា លោក ហុក ឡុងឌី កាលនៅរស់មានគំនំស្រួចស្រាវជាមួយលោក ជា សុផារ៉ា អតីតអភិបាលក្រុងភ្នំពេញ ។

លោក ហូរ សុខ រដ្ឋលេខាធិការក្រសួងមហាផ្ទៃមកពីគណបក្សហ៊្វុនស៊ិនប៉ិច រហូតទៅដល់មានឃាតកបាញ់សម្លាប់លោក ហូរ សុខ ក្នុងមន្ទីរឃុំឃាំងរកមុខមិនឃើញរហូតដល់សព្វថ្ងៃ

មរណភាពរបស់លោក ហុក ឡុងឌី មិនបានធ្វើឱ្យប្រជាពលរដ្ឋមានការសោកស្តាយដូចឥស្សរជននយោបាយ និងអ្នកដឹកនាំមួយចំនួននោះទេ ប៉ុន្តែ ប្រជាពលរដ្ឋមួយចំនួនបែរជាដាក់បណ្តាសារ និងបន់ស្រន់ឱ្យលោក ហុក ឡុងឌី ស្លាប់ទៅវិញ ពីព្រោះពួកគាត់មិនចង់ឃើញអ្នកដឹកនាំដែលមានបាតដៃប្រឡាក់ឈាមនោះទេ ៕

អត់ពីលោកអ្នកទៅ តើបាននរណាជួយថែរក្សាកូនចៅលោកអ្នក ?

NEW YORK LIFE

១-ទិញការធានារ៉ាប់រងសម្រាប់ជីវិត (Life Insurance)
២-សន្សំលុយសំរាប់ចូលនិវត្តន៍ (Retirement Planning)
៣-សន្សំលុយសម្រាប់កូនចូលរៀនមហាវិទ្យាល័យ (College Saving)
៤-រៀបចំទ្រព្យសម្បត្តិទុកឱ្យកូនចៅ (Estate Planning)



ខ្ញុំអាចជួយពន្យល់ដល់បងប្អូនដោយមិនយកកម្រៃ

WUTHA CHIN MBA,
Agent New York Life
P. (610) 660 5897, Cell. P (267) 736 0445
wchin@ft.newyorklife.com



# TWO APARTMENTS FOR SALE!
Only $63,000 per apartment !



Location: 641 & 643 Mercy St. South Philly. In each apartment has: two, Bedroom 1 bathroom ,1living room and kitchen. One apartment has 1 store front, and next apartment has 1 garage. Formerly was the fish market. Sell by owner; please call Mr. Sebastian (Seb) Feeney for showings.

**215-760-2101**

លក់ផ្ទះ (Apartment) : តម្លៃ $63.000/ ផ្ទះមួយ នៅហ្វីឡាខាងត្បូង ផ្ទះនីមួយៗមាន បន្ទប់ដេក២ បន្ទប់ទឹក ១ បន្ទប់ទទួលភ្ញៀវ និងផ្ទះបាយ ផ្ទះទី ១ មានហាងខាងមុខ ផ្ទះទី២ មានចំណតរថយន្ត (ពីមុខជាផ្សារលក់ត្រី) លក់ដោយម្ចាស់ផ្ទះ សូមទូរស័ព្ទទៅ "សេបាស្ទៀន" **(215) 760-2101**



# ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត
Fast and Friendly Service

- Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ



*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.



# លក់សាឡនថែរសម្ផស្សមានបីជាន់
BEAUTY SALON FOR SALE



Three-story Beauty Salon, locates on 2nd & South Street. Business is Currently Active. Price: 1.5 Million (negotiable). Please call 215-940-0681for showings.

ស្ថិតនៅលើផ្លូវ ២nd នឹង South Street ហ្វីឡាដែលហ្មៀ ជាហាងដែលកំពុងដំណើរការនាពេលនេះ តម្លៃលក់ ១.៥ Million (ក្នុងតថ្លៃ)
សូមណាត់ជួបគ្នា ដើម្បីបង្ហាញ សាឡន នោះ
ព័ត៌មានបន្ថែម សូមអញ្ជើញទូរស័ព្ទ (២១៥) ៩៤០-០៦៨១



ផ្កាយព្រឹក វីដេអូ
PKAY PREK VIDEO
(215) 455-2762
4935 OLD YORK RD. PHILADELPHIA, PA 19141



ជួលកុន_លក់ឌីវីឌី និង ស៊ីឌី
MOVIE RENTAL
DVD & CD SALES
CAMBODIAN FORMAL DRESSES
WOMEN & BABY CASUAL WEARS





# ក្រុមហ៊ុន ទេសចរណ៍
CENTURY TRAVEL & SERVICE CENTER

904 South 8th Street. Philadelphia, Pa 19147
Tel. 215.625.2889 – Fax. 215.625.9395
Cell: 267.934.9888 – email: centuryphl@yahoo.com

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនឹងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

Serve all Airlines
National & International flights
Tour Guides Arrangements
Khmer Passport Extension
Immigration
Tourist Visa
Money Transfer
Notary Public

We speak Khmer, Chinese Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន វៀតណាម



# បន្ទូរបរិយាកាស
សូមពិសាភេសជ្ជៈមួយកែវ
នៅបារ TIPSY
ជាហាងកូនខ្មែរធំនើបបំផុត នៅតំបន់ហ្វីឡាខាងជើង
ពិបស៊ី មាន "បារ" មាន "ឡោន"
ទទួលភ្ញៀវនឹងរាំកំសាន្តយ៉ាងសប្បាយរីករាយ



ពិបស៊ី នឹងនាំឱ្យលោកអ្នកចង់រាំកំសាន្ត
Live D.J. every Fri & Sat night from 9 p.m. – 2 p.m. (pool table)
Serve Chinese and American food open for Lunch and Dinner
មានក្រុមតន្ត្រីសម័យ ឬ DJចាក់ចម្រៀងពិរោះៗឱ្យស្តាប់ រៀងរាល់រាត្រី ថ្ងៃសុក្រ-ថ្ងៃសៅរ៍ ពីម៉ោង ៩ យប់ ដល់ម៉ោង ២ ភ្លឺ
មានតុបុកប៊ីយ៉ាទៀតផង

Ralph Rinn
Tel: 215.305.5763
Cell: 267.968.3413
Michael Lay (General Manager)
215.409.4772
Email: tipsybar@gmail.com

Sun-Thu: 10 – 12 a.m.
Fri & Sat: 10 – 2 a.m.
Kitchen Open Daily
Sun-Sat: 10 – 11 p.m.
3904 Frankford Ave.
Philadelphia, Pa 19124







សូមគោរពអញ្ជើញមកចូលរួម
អបអរសាទរនៅឱកាសបុណ្យ
**THANKS GIVING.**

ស្តាប់ភ្លេង និងច្រៀង ដោយក្រុម
តន្ត្រី H2O BAND និងមនោរម្យតន្ត្រី
ដែលធ្លាប់មានឈ្មោះល្បី ព្រមទាំងមាន
ការចូលរួមដោយក្រុមអ្នកចម្រៀងមកពី
ប្រទេសកម្ពុជាផងដែរ ។

**សូមកុំភ្លេច !!!**

- ថ្ងៃសុក្រ ទី២៨ វិច្ឆិកា ២០០៨
នៅភោជនីយដ្ឋាន SAIGON MAXIM.
វេលាម៉ោង៧យប់ ។
- ថ្ងៃសៅរ៍ ទី២៩ វិច្ឆិកា ឆ្នាំ២០០៨
នៅភោជនីយដ្ឋាន HAI TIEN វេលា
ម៉ោង៧យប់ ។

ក្រុមតន្ត្រីយើងខ្ញុំនឹងត្រឡប់មកកំដរ
លោកអ្នកនៅឱកាសចូលឆ្នាំថ្មីខាងមុខជា
មួយការសំដែងថ្មីៗទៀត មិនឱ្យលោកអ្នក
មានការខកចិត្តឡើយ ។

ដានី ទូរស័ព្ទ : ២៦៧_៧៨៤ ៩៨៣៩.

## AMERICAN LEGION POST 153 PRESENTS



**FRANTIC**
DJ FRIDAY AND SATURDAY
FROM 9 P.M. – 3 A.M.
MEMBERS ONLY
SMOKING PERMITTED

សូមអញ្ជើញមកកំសាន្ត រីករាយ ពិសារគេសជ្ជៈ រាំកំសាន្តនៅ "ក្រុងទឹក"

2514 S. 24TH ST.
PHILA., PA 19145
215-551-1950

**បន្ទប់បរិយាកាសយ៉ាងត្រជាក់ចិត្ត បន្ទាប់ពីធ្វើការងារហត់នឿយ !**

- កន្លែងកំសាន្តធំទូលាយ-ស្តាប់ភ្លេងយ៉ាងពិរោះអស្ចារ្យ ឬក៏បុកប៊ីយ៉ា ក៏មានជូនកំសាន្តដែរ ។
- យើងខ្ញុំរីករាយណាស់នឹងឃើញលោក-អ្នកអញ្ជើញមក !
- ថ្ងៃសុក្រ-សៅរ៍ ពីម៉ោង ៩ ដល់ម៉ោង ៣ ព្រឹក
- **DJ** នឹងបំណ្តែតអារម្មណ៍លោក-អ្នកតាមតន្ត្រីសំរាំងថ្មីៗ





**ចង់ជួលសាល ឬចង់បានម្ហូបជប់លៀង យើងធ្វើជូនបាន !**

HALL RENTAL & CATERING
AVALIABLEREASONABLE PRICE

# Nationwide

Insurance & Financial Service
**សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ**
We offer Cheap Price for Every Client
**យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប**

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រង សុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147